00941461



**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**
Trial Chamber
Chambre de Premiere instance

**ឯកសារដើម**
**ORIGINAL/ORIGINAL**
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jul-2013, 10:47
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣**

**ម៉ោង ០៩: ០៣នាទី**

**សវនាការលើកទី២១១**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តារា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ហ្វៃហ្សា ស៊ូអាគ្រី
*(Ms.Faiza ZOUAKRI)*

លោក ឌុច ផារី

លោកស្រី មីរាម ម៉ាហ្វេសសាន់ទិ
*(Ms.Miriam MAFESSANTI)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ឃីត រេយ៍ន័រ *(Mr. RAYNOR Keith)*

កញ្ញា សុង ឆវន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក វ៉ិចទ័រ កូប៉េ *(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSÉ)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ស៊ីន សុវ៉ន

លោក សំ សុគង់

លោក ហុង គីមសួន

លោក ឡៃ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ឃីត រេយ៍ន័រ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក រ៉ិចទ័រ កូប៉េ | អង់គ្លេស |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ស្ទីវ ហេដឌ័រ (TCE-33) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស្ទីវ ហេដឌ័រ** (TCE-33)

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី៖ ................................................................ទំព័រ ៤

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស្ទីវ ហេដឌ័រ ដែលនឹងសួរដេញដោយក្រុមមេធាវីការពារក្តី។

លោក ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន។ សម្រាប់សវនាការថ្ងៃនេះ គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមកត់សម្គាល់ថា ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនដែលនៅពីក្រោមបន្ទប់សវនាការតាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយមូលហេតុបញ្ហាសុខភាព។

សាក្សីលោក ស្ទីវ ហេដឌ័រ ដែលត្រូវផ្តល់សក្ខីកម្មបន្តថ្ងៃនេះមានវត្តមាននៅក្នុងបន្ទប់សវនាការ។ សូមអរគុណលោកប្រធាន។

[០៩:០៤:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយនៅពេលនេះ មុននឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសូមបញ្ជាក់ឡើងវិញ ដោយផ្ទាល់មាត់ចំពោះសេចក្តីសម្រេចផ្ទាល់មាត់ដែលរបស់ខ្លួន ដែលបានធ្វើនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ពាក់ព័ន្ធនឹងការសម្រេចចិត្តឡើងវិញរបស់ជនជាប់ចោទ ក្នុងការរក្សាសិទ្ធិនៅស្ងៀមមិនឆ្លើយតបតាមការជ្រើសរើសរបស់ខ្លួន។

តាមសំណើចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៣ និងដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងនៅថ្ងៃចន្ទ ទី០៨ ខែកក្កដា ឆ្នាំ២០១៣ ក្រុមមេធាវីការពារក្តី ខៀវ សំផន បានជូនដំណឹងដល់អង្គជំនុំជម្រះ និងភាគី ថាជនជាប់ចោទ ខៀវ សំផន នឹងមិនឆ្លើយតបទៅនឹងសំណួរទាំងឡាយនៅចំពោះមុខអង្គជំនុំជម្រះទៀតឡើយ។

[០៩:០៥:៤៧]

ការឆ្លើយតប ជាការឆ្លើយតបសហព្រះរាជអាជ្ញាបានលើកឡើងជាសំណើដែលមានលក្ខណៈជាការសម្បទានមួយចំនួនក្នុងគោលបំណង ដើម្បីសម្រួលដល់ការរៀបចំរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន សម្រាប់សួរកូនក្តីរបស់ខ្លួន។ ប្រសិនបើមិនដូច្នោះទេ សហព្រះរាជអាជ្ញាស្នើសុំឲ្យអង្គជំនុំជម្រះរំឭកដល់ជនជាប់ចោទ ខៀវ សំផន អំពីផលវិបាកនានានៃការសម្រេចចិត្តរបស់គាត់ក្នុងការមិនឆ្លើយសំណួរនៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះបានសម្រេចស្របតាមសំណើនេះថា អង្គជំនុំជម្រះត្រូវរំឭកនូវសេចក្តីសម្រេចផ្ទាល់មាត់កាលពីលើកមុនអំពីបញ្ហានេះ ដែលបានសម្រេចនៅថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២។

បាទ ជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។

**លោក វ៉ិចទ័រ កូប៉េះ**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។ សូមជម្រាបសួរលោកមេធាវី ហើយជាពិសេសសូមជម្រាបសួរលោក ហេដឌ័រ។

លោកប្រធាន មុនពេលដែលខ្ញុំចាប់ផ្តើម ខ្ញុំមិនចង់ឲ្យបានចម្លើយភ្លាមៗទេ ប៉ុន្តែអាចនៅពេលក្រោយក៏បានដែរ។ ដូច្នេះជាដំបូង ខ្ញុំចង់ឲ្យអង្គជំនុំជម្រះចាប់អារម្មណ៍ទៅលើបញ្ហាដែលថា ព្រះរាជ-អាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីបានសួរសាក្សីប្រហែលជារយៈពេល៣ថ្ងៃ លើសខ្វះតិចតួច។ ហេតុដូច្នេះហើយ គឺវាគឺថាខាងមេធាវីយើងខ្ញុំចង់ស្នើសុំសួរសាក្សីប្រហែលជាច្រើនជាង១ថ្ងៃទៅទៀត នៅក្នុងការសាកសួរនេះ។

ហេតុដូច្នេះហើយ ខ្ញុំសង្ឃឹមថា ខ្ញុំអាចនឹងមានឱកាសបន្ថែមដើម្បីសាកសួររហូតទៅដល់ថ្ងៃស្អែកប្រហែលជា១ម៉ោងកន្លះ នៅព្រឹកស្អែកតទៅទៀត។ ដូច្នេះនេះគឺជាការជូនដំណឹងទុកជាមុនអំពីខាងមេធាវីយើងខ្ញុំ ថាតើយើងខ្ញុំអាចនឹងមានសំណើនៅថ្ងៃស្អែក ឬក៏អត់ទាក់ទងទៅនឹងការស្នើសុំពេលម៉ោងបន្ថែមនេះ។

[០៩:០៨:២៣]

**កញ្ញា អង់តា ហ្គីសសេះ**

ជម្រាបសួរលោកប្រធាន អស់លោក លោកស្រីចៅក្រម និងភាគីទាំងអស់ជាទីគោរព។ ខ្ញុំសូម

ជម្រាបជូនថា ក្រុម ខៀវ សំផន ចំពោះពេលវេលា២ថ្ងៃដែលផ្តល់ឲ្យខាងការពារក្តីនេះ មិនគ្រប់គ្រាន់ទេ ដើម្បីនិយាយអំពីអង្គហេតុទាំងអស់នៅក្នុងការចោទសំណួរទៅសាក្សី។ ខុសពីការអនុវត្តរបស់អង្គជំនុំ រហូតដល់ពេលនេះ ក្នុងការបែងចែកពេលវេលាស្មើគ្នារវាងភាគីទាំងអស់។ ប៉ុន្តែចំពោះលោក ស្ទីវ ហេដឌ័រ នេះ ខាងការពារក្តីមានពេលវេលាតែ២ថ្ងៃនោះទេ។ តែបើតាមពេលវេលាដែលផ្តល់ជូនទៅខាង សហព្រះរាជអាជ្ញា យើងយល់ឃើញថា ចំពោះខាងការពារក្តីក៏ត្រូវការពេលវេលាច្រើនដែរ ដោយសារ ឯកសារច្រើនណាស់។

អ៊ីចឹងយើងនឹងត្រឡប់មកនិយាយឯកសារជាច្រើន ហើយវាស៊ីពេលវេលា ហើយដោយហេតុថា ខាងការពារក្តីនេះសួរក្រោយគេ អ៊ីចឹងខ្ញុំសូមជម្រាបជូនតុលាការថា យើងនឹងត្រូវការពេលវេលាពេញ១ ថ្ងៃ ហើយនិងសូម១ម៉ោងកន្លះបន្ថែមទៀត។

[០៩:០៩:៥០]

ដូច្នេះ បើនិយាយឲ្យចំទៅ គឺថាខាងភាគីការពារក្តីទាំងពីរភាគីនេះ គឺត្រូវការពេលវេលា១ថ្ងៃ កន្លះ។ អ៊ីចឹងសូមកុំឲ្យអង្គជំនុំជម្រះមានការភ្ញាក់ផ្អើលក្នុងការសុំបន្ថែមពេលវេលានេះ លោកប្រធាន។ អ៊ីចឹងសូមកុំឲ្យអង្គជំនុំជម្រះមានការភ្ញាក់ផ្អើលក្នុងការសុំបន្ថែមពេលវេលានេះលោកប្រធាន។ អ៊ីចឹងសូម ជម្រាបជូនជាមុនយ៉ាងដូច្នេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះនឹងពិនិត្យពិចារណាសម្រេចតាមស្ថានភាពជាក់ស្តែង ឲ្យតែសំណួរដែលសួរ នោះគឺមានភាពពាក់ព័ន្ធ ហើយមិនមែនសំណួរច្រំដែល។ និយាយរួមគឺឲ្យការប្រើប្រាស់ពេលវេលាដែល បានបែងចែកជូននេះឲ្យមានប្រសិទ្ធភាព ហើយបើមានចាំបាច់នូវការតាំងសំណួរដែលមានភាពពាក់ព័ន្ធ សំខាន់ ដែលអង្គជំនុំជម្រះមានភាពចាំបាច់ក្នុងការស្តាប់នូវសក្ខីកម្មនោះ អង្គជំនុំជម្រះនឹងពិនិត្យពិចារ- ណាទៅតាមសំណើសុំនេះនៅពេលក្រោយ។

សូមអញ្ជើញ!

[០៩:១០:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វិុចទ័រ កូប៉េះ៖**

**ស៖** សូមជម្រាបសួរលោក ហេងឆ័រ ជាថ្មីម្តងទៀត។ លោកបានចូលរួមសវនាការ៣ថ្ងៃ ហើយស្តាប់នូវការសួរពីខាងព្រះរាជអាជ្ញា និងដើមបណ្តឹងរដ្ឋប្បវេណីអស់រយៈពេល៣ថ្ងៃមកហើយ។ សំណួរទាំងអស់បានចោទសួរលោក ក្នុងនាមលោកជាសាក្សី។ ហើយលោកបានឮនូវការជំទាស់មួយចំនួនពីខាងមេធាវីការពារក្តីនូវពេលដែលយើងគិតថា គេស្នើសុំឱ្យលោកបញ្ចេញមតិក្នុងនាមជាអ្នកជំនាញនោះ។

ប៉ុន្តែខ្ញុំគិតថាមានសំណួរជាច្រើនដែលគេគួរតែសួរលោក ប៉ុន្តែគេមិនទាន់បានសួរលោកនៅឡើយ។ ហើយក្នុងនាមលោកជាសាក្សី ខ្ញុំដឹងថាលោកបដិសេធមិនចូលខ្លួនក្នុងនាមជាអ្នកជំនាញនោះទេ។ ខ្ញុំគិតថាអង្គជំនុំជម្រះបានពិចារណាចាត់ទុកលោកថាជាអ្នកជំនាញ ប៉ុន្តែលោកមិនទទួលយក។ ប៉ុន្តែតាមព្រះរាជអាជ្ញា គឺគេចាត់ទុកថាលោកគឺជាអ្នកសិក្សាស្រាវជ្រាវឈានមុខគេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អំពីរបបកម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំចង់សួរលោកថា ហេតុអ្វីបានជាលោកមិនចង់បង្ហាញខ្លួនក្នុងនាមជាអ្នកជំនាញទៅវិញ?

[០៩:១២:២៧]

**លោក ស្ទីវ ហេងឆ័រ៖**

**ឆ៖** ខ្ញុំមានហេតុផលពាក់ព័ន្ធគ្នាច្រើនទៅលើបញ្ហានេះ តាមពិតទៅតាមដែលខ្ញុំយល់ ប្រសិនបើខ្ញុំយល់មិនខុសទេ គឺថាអង្គជំនុំជម្រះចាត់ទុកខ្ញុំ ពិចារណាចាត់ទុកខ្ញុំថាជាអ្នកជំនាញ ហើយខ្ញុំគិតថាខាងមេធាវីការពារក្តីក៏យល់ឃើញដូច្នេះដែរ។ ក៏ប៉ុន្តែនៅពេលដែលគេចាត់តាំងខ្ញុំឱ្យធ្វើការងារនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ខ្ញុំមិនទៅចាត់ទុកជាអ្នកជំនាញនោះទេ។ ចៅក្រម ឡឺម៉ុងដ៍ គាត់និយាយថា ខ្ញុំជាអ្នកជំនាញ ប៉ុន្តែអានេះជាទស្សនៈរបស់ចៅក្រម ឡឺម៉ុងដ៍ ទេ។

ដូច្នេះតាមគំនិតរបស់ខ្ញុំដែលមិនមែនជាអ្នកជំនាញ គឺការខ្ញុំជំទាស់ទៅលើបញ្ហាទាំងអស់នេះ។ ខ្ញុំអាចឆ្លើយក្នុងនាមខ្ញុំជាអ្នកសិក្សាស្រាវជ្រាវ ជាអ្នកសិក្សា ប៉ុន្តែវាខុសគ្នានឹងឈ្មោះជាអ្នកជំនាញ។ គឺថាវាមិនមានហេតុការណ៍ ឬក៏មានព្រឹត្តិការណ៍ណាមួយដែលថាអ្នកសិក្សាស្រាវជ្រាវភាគច្រើនគាត់ត្រូវបង្ហាញខ្លួនថាជាអ្នកជំនាញនៅក្នុងកំណត់ត្រានោះទេ។

[០៩:១៤:០៣]

ខ្ញុំមិនចង់និយាយអំពីរឿងរ៉ាវផ្សេងៗដែលស្មុគស្មាញច្រើននោះទេ។ ប៉ុន្តែប្រសិនបើយើងនិយាយ

អំពីការសិក្សាស្រាវជ្រាវ គឺយើងគ្រាន់តែបោះពុម្ពឯកសារតែប៉ុណ្ណោះ។ ហេតុដូច្នេះហើយ គឺវាមានការបោះពុម្ពផ្សាយនូវឯកសារ សៀវភៅ គឺថាលោកអាន លោកសរសេរ ហើយបន្ទាប់មកយើងពិនិត្យទៅលើឯកសារទាំងអស់ហ្នឹង យើងពិនិត្យទៅលើឯកសារម្តងហើយម្តងទៀតទៅ។ បន្ទាប់មកទៀត គឺយើងបញ្ជូនទៅដល់អ្នកនិពន្ធ ឬក៏អ្នកដទៃទៀតដែលយើងទុកចិត្តបាន ឬក៏ដែលយើងគិតថាល្អជាមួយយើងអាចនឹងជួយយើងក្នុងការផ្តល់ជាមតិយោបល់ ក៏ដូចជាស្នើបន្ថែមថាតើយើងត្រូវធ្វើអ្វីបន្ថែមទៀត។

ហើយពួកគាត់អាចបញ្ជាក់ថាតើចំណុចណាល្អ ចំណុចណាមិនល្អ។ ហើយបន្ទាប់មកយើងបញ្ជូនឯកសារទាំងអស់ហ្នឹង ទៅធ្វើការបោះពុម្ពផ្សាយ។ ហើយបន្ទាប់មកយើងអាចនឹងឲ្យអ្នកដទៃទៀតដើម្បីពិនិត្យបន្ថែម។ នេះគឺជាអ្វីដែលយើងត្រូវធ្វើ មុនយើងបោះពុម្ពឯកសារ។ ហើយចុងក្រោយគឺថាការបោះពុម្ពហ្នឹងវាចំណាយពេលប្រហែលជារាប់ខែ ប្រសិនបើមិនយូររហូតដល់រាប់ឆ្នាំទេនោះ។ នៅក្នុងផ្នែកហ្នឹងគឺថាឯកសារហ្នឹងវាត្រូវទទួលរងនូវការ ពិភាក្សាដេញដោលតាមវិធីសាស្ត្រផ្សេងៗដោយអ្នកសិក្សាស្រាវជ្រាវនានា។ នេះគឺជាដំណើរការនៃការសរសេរឯកសារ។

[០៩:១៥:៣១]

ចំពោះខ្ញុំវិញ ខ្ញុំគិតថាទម្រង់ដ៏ត្រឹមត្រូវនៃការសិក្សាស្រាវជ្រាវ ឬក៏អ្នកស្រាវជ្រាវហ្នឹង គឺមិនមែនស្ថិតក្នុងស្ថានភាពដូចដែលខ្ញុំត្រូវគេចោទសួរនៅទីនេះទេ គឺនៅក្នុងតុលាការនេះទេ។ ដូច្នេះ ប្រសិនបើខ្ញុំមានទស្សនៈជាអ្នកជំនាញ ខ្ញុំនឹងអាចបញ្ចេញទស្សនៈជាអ្នកជំនាញ ប៉ុន្តែខ្ញុំបញ្ចេញនៅក្នុងលក្ខណៈជាអ្នកស្រាវជ្រាវទៅវិញ។

ដូច្នេះទោះបីជាមានការពិភាក្សាដេញដោលទៅលើខ្លឹមសារ ក៏ដូចជាលទ្ធផលនៃឯកសារដែលខ្ញុំបានសរសេរ ដែលខ្ញុំបាននិពន្ធក៏ដោយ គឺថាអ្នកនិពន្ធមួយចំនួនដូចជា ក្រេក អេតធេសាន់ ក៏ដូចជាអ្នកនិពន្ធដទៃទៀត គឺគាត់មានគោលគំនិតដូចគ្នានេះ គឺថាមានគេសួរដេញដោលគាត់អំពីអ្វីដែល គាត់បានសរសេរអំពីអ្វីដែលគាត់បាននិពន្ធ គឺថាគាត់ត្រូវសរសេរហើយសរសេរទៀត គាត់ព្រាងម្តងហើយម្តងទៀតមុននឹងពេលគាត់ចេញធ្វើការបោះពុម្ពផ្សាយ។ ដូច្នេះផ្អែកទៅលើអ្វីដែលគាត់សរសេរ គឺថាគេត្រូវសួរគាត់ទៅលើបញ្ហាទាំងអស់នេះ។ ដូច្នេះហើយទើបពេលនុ៎ងដែលគេត្រូវសួរពួកគាត់អំពីទស្សនៈជាអ្នកជំនាញ។

[០៩:១៧:០៨]

ឥឡូវនេះខ្ញុំចង់លើកពីចំណុចទី២ របស់ខ្ញុំ គឺថាដំណើរការនោះវាចំណាយពេល ប្រសិនបើខ្ញុំត្រូវ

ធ្វើបែបនេះ ខ្ញុំត្រូវការពេលវេលារាប់ខែដើម្បីធ្វើរបាយការណ៍របស់ខ្ញុំ។ ប្រសិនបើខ្ញុំត្រូវធ្វើរបាយការណ៍ ខ្ញុំគិតថាខ្ញុំត្រូវចំណាយពេលរាប់ខែដើម្បីធ្វើរបាយការណ៍។ ដោយសារហេតុផលនេះ ហើយទើបខ្ញុំឈានទៅដល់មូលហេតុទី៣ គឺថានៅក្នុងឆ្នាំ២០១១ ខ្ញុំសម្រេចចិត្តថា ខ្ញុំមិនចង់ផ្តោតយកចិត្តទុកដាក់ទៅលើបញ្ហាខ្មែរក្រហមតទៅទៀតនោះទេ។

នៅពេលដែលខ្ញុំចាប់ផ្តើមនៅក្នុងឆ្នាំ៧៣ គឺខ្ញុំចាប់អារម្មណ៍អំពីបញ្ហាខ្មែរក្រហម អំពីប្រទេសនានានៅអាស៊ីអាគ្នេយ៍ជាដើមនេះ។ ហើយបន្ទាប់មក គឺវាមានការប្រែប្រួលនៅពេលខ្មែរក្រហមឡើងកាន់អំណាច។ ហើយខ្ញុំក៏ចាប់ផ្តើមអារម្មណ៍ក៏ដូចជាមានការយកចិត្តទុកដាក់ទៅលើបញ្ហានេះ។ ប៉ុន្តែរហូតមកដល់ឆ្នាំ២០១១វិញ គឺខ្ញុំសម្រេចចិត្តថាខ្ញុំលែងត្រូវការខ្មែរក្រហម លែងចង់គិតពីខ្មែរក្រហមទៀតហើយ។

ហេតុដូច្នេះហើយគឺខ្ញុំសម្រេចចិត្តថា ឈប់ខ្វល់ពីអង្គជំនុំជម្រះខ្មែរក្រហមនឹងទៀត។ ព្រោះថាខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវទៅលើបញ្ហាផ្សេង ហើយប្រសិនបើលោក លោកស្រីពិនិត្យមើល ទៅលើការស្រាវជ្រាវរបស់ខ្ញុំក្នុងពេលថ្មីៗនេះ គឺខ្ញុំផ្តោតទៅលើគោលនយោបាយនៅប្រទេសអាស៊ីអាគ្នេយ៍ក្នុងពេលថ្មីៗនេះ។ ដោយសារហេតុផលទាំងពីរ ទាំងបីដែលខ្ញុំបានបញ្ជាក់ខាងលើនោះហើយ ដូចដែលខ្ញុំបានជម្រាបនៅក្នុងអ៊ីម៉ែលផងដែរ នេះគឺជាហេតុផលដែលខ្ញុំបដិសេធមិនមកបង្ហាញខ្លួនជាអ្នកជំនាញ។

[០៩:១៩:០០]

**ស៖** សូមអរគុណលោកចំពោះចម្លើយដ៏វែងបែបនេះ។ ឥឡូវនេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់បន្តិចទៅលើអ្វីដែលលោកបានឆ្លើយដំបូង គឺនៅក្នុងឃ្លាដំបូងដែលលោកឆ្លើយ។ នៅពេលដែលលោកចៅក្រមឡឺម៉ុងដ៍ និយាយថា លោកគឺជាអ្នកជំនាញប៉ុន្តែលោកថាមិនមែនទេ។

**ឆ៖** បាទ ខ្ញុំអាចឆ្លើយថាបាទ បាន។ វាមិនមែនជាកម្រិតជ្រៅជ្រះនោះទេ ប៉ុន្តែកម្រិតហ្នឹង គឺវាបានពន្យល់នៅក្នុងទស្សនៈរបស់គាត់ ដែលថាវាមិនមែនជាការត្រឹមត្រូវដែលថាអ្នកណាម្នាក់ជាអ្នកសិក្សាស្រាវជ្រាវ ហើយជាអ្នកជំនាញយកមកធ្វើការនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេតនោះទេ។ ប៉ុន្តែក្នុងពេលជាមួយគ្នាហ្នឹងគឺថាអ្នកដែលធ្វើការហ្នឹងក្លាយជាអ្នកជំនាញ។

ដូច្នេះបើតាមដែលខ្ញុំចាំ គឺថាទៅតាមទំនៀមទម្លាប់ គឺថានេះគឺជាហេតុផលនៅតាមផ្លូវច្បាប់។ ប៉ុន្តែយើងមានគោលគំនិតយល់ឃើញច្បាស់បែបនេះ។ សូម្បីតែលោក រ៉ូប៊ឺត ពេទីត ក៏និយាយថា ខ្ញុំជាអ្នក -- ជាព្រះរាជអាជ្ញា ឬក៏អត់។ ហេតុដូច្នេះហើយគឺជាអ្វីដែលខ្ញុំចង់បញ្ជាក់។ ខ្ញុំមិនដឹងថាយ៉ាងម៉េចទេ ដូច្នេះខ្ញុំមិនមែនជាមេធាវី ហើយខ្ញុំក៏មិនមែនជាអ្នកច្បាប់ ខ្ញុំមិនអាចសម្រេចទៅលើបញ្ហានេះទេ ប៉ុន្តែ

ខ្ញុំមានចំណុចមួយទៀត។ ខ្ញុំគិតអំពីអ្វីដែលបានកើតឡើងនៅពេលនោះ គឺកើតឡើងរវាងខាងមេធាវីការពារក្ដីជាមួយព្រះរាជអាជ្ញានិងដើមបណ្ដឹងរដ្ឋប្បវេណី ខ្ញុំគិតក្នុងលក្ខណៈជាអ្នកសិក្សាស្រាវជ្រាវវិញ។

[០៩:២១:០៦]

ចំពោះខ្ញុំគឺវាហាក់ដូចជាពួកអស់លោកនៅប៉ូលពីរផ្សេងគ្នា។ គឺថាពួកអស់លោកចាត់ទុកពួកខ្ញុំម្នាក់ចាត់ទុកខ្ញុំជាសាក្សី ម្ខាងទៀតចាត់ទុកខ្ញុំជាអ្នកជំនាញ។ ហេតុដូច្នេះហើយពួកលោកគឺប៉ូលពីរដាច់ពីគ្នា ហេតុដូច្នេះហើយទើបវាមានសំណួរទាំងអស់នេះកើតឡើងនៅពេលព្រឹកនេះ--

**ប្រធានអង្គជំនុំ៖**

បានហើយលោកសាក្សី! លោកដូចជាមិនចូលនៅក្នុងភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលអង្គជំនុំជម្រះមានបំណងចង់ស្ដាប់នោះទេ។ សូមមេធាវីតាំងសំណួរចូលទៅនឹងសំណួរទាំងឡាយដែលពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ដើម្បីបង្ហាញថាលោកបានប្រើប្រាស់ពេលវេលាដែលបានចែកឲ្យមានប្រសិទ្ធភាព។ យើងបានជម្រាបហើយឲ្យតែសំណួរមានការពាក់ព័ន្ធ ហើយសំណួរហ្នឹងកុំច្រំដែល។ ប៉ុន្តែយើងឃើញពីរសំណួរនេះ ស្ដាប់ទៅឃើញថាមិនមានការពាក់ព័ន្ធទៅនឹងអ្វីដែលអង្គជំនុំជម្រះចង់ស្ដាប់យកទៅពិចារណា ដើម្បីសម្រេចសេចក្ដីនេះទេ។

សូមលោកតម្រង់នូវសំណួររបស់លោកឲ្យបានចំនូវបញ្ហាដែលអង្គជំនុំជម្រះកំណត់។ បញ្ហា និងអង្គហេតុសម្រាប់ធ្វើសវនាការ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមសួរមួយចំនួនបន្ថែមទៀតទៅលើចំណុចនេះផងដែរ។

[០៩:២២:៤២]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ បានសរសេរនៅលើសៀវភៅរបស់លោកអំពីបញ្ហាមួយ គឺកុម្មុយនីស្ត ហើយគាត់បង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះជាសាក្សីអ្នកជំនាញ។ ហើយគាត់បង្ហាញខ្លួនក្នុងនាមជាអ្នកជំនាញ ដោយពិចារណា។ ប៉ុន្តែលោកមិនមែនមកក្នុងនាមទីនេះក្នុងនាមជាអ្នកជំនាញ តើហេតុអ្វីដែរ?

**ប្រធានអង្គជំនុំ៖**

សំណួរនេះមិនពាក់ព័ន្ធទេ សាក្សីមិនបាច់ឆ្លើយតបទេ! យើងបានរំឭកហើយអំមិញ។

[០៩:២៣:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំចង់ធ្វើការសាកសួរទៅលោកប្រធាន ថាហេតុអ្វីបានជាដូច្នេះលោកប្រធាន? គឺខ្ញុំគ្រាន់តែចង់សួរអំពីភាពជឿទុកចិត្ត ក៏ដូចភាពអាចទុកបានរបស់សាក្សីរូបនេះ។ ដូច្នេះ ខ្ញុំចង់ដឹងថាតើផ្អែកទៅលើមូលហេតុអី? ប៉ុន្តែយ៉ាងណាក៏ដោយឥឡូវនេះខ្ញុំសូមបន្តទៅមុខទៀតទៅចុះ។ ហើយខ្ញុំសួរសំណួរក្នុងលក្ខណៈផ្សេងមួយទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេដឌ័រ ថាតាមការស្រាវជ្រាវរបស់លោក តាមការសម្ភាសរបស់លោក ក៏ដូចជាផ្អែកទៅលើអត្ថបទនានាដែលលោកបានសរសេរ។ ប្រសិនបើលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ជាអ្នកជំនាញឈានមុខគេមួយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហេតុអ្វី?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[០៩:២៤:២៩]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំជំទាស់ទៅលើសំណួរនេះ។ អ្វីដែលជាបញ្ហាគឺថាទស្សនៈរបស់គាត់ គឺទស្សនៈរបស់អ្នកសាក្សីអំពីបញ្ហាលោក ឆេនដ៍ល័រ គឺជាបញ្ហាមួយផ្សេង។ លោកមេធាវីការពារក្តីអាចលើកយកផ្នែកមួយរបស់សៀវភៅលោកសាក្សីយកមកសួរ ហើយនិយាយអំពីលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ បាន។ ប៉ុន្តែយ៉ាងណាក៏ដោយគឺមានការនិយាយយោងជាច្រើននៅក្នុងសៀវភៅរបស់ ហេដឌ័រ ទៅលើសៀវភៅដែលសរសេរដោយលោក ដេវីដ ឆេនដ៍ល័រ។ ដូច្នេះ ប្រសិនបើយើងលើកសំណួរដែលជាក់ច្បាស់នៅក្នុងសៀវភៅរបស់លោក ហេដឌ័រ មកតែម្តងគឺថាមិនអាចនោះបានទេ។ ប៉ុន្តែប្រសិនគាត់លើកជាទូទៅបែបនេះ វាជាគឺជាសំណួរដែលស្នើសុំឲ្យបញ្ចេញមតិ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមកែសំណួររបស់ខ្ញុំទៅចុះ។

[០៩:២៥:២៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោក ហេងឌ័រ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា "កុម្មុយនីស្ត" គឺមាននូវអារម្ភកថា ដែលសរសេរឡើងដោយឡើងដោយលោក ដេវីដ ឆេនដ៍ល័រ។ តើលោកប្រាប់ខ្ញុំបានទេថា ហេតុអ្វីបានជាលោក ឆេនដ៍ល័រ ជាអ្នកសរសេរអារម្ភកថាទៅក្នុងសៀវភៅរបស់លោកទៅវិញ?

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនអាចនិយាយឲ្យបានច្បាស់ទេ ប៉ុន្តែអានេះជាទស្សនៈរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំមិនដឹងថាទស្សនៈរបស់អ្នកសិក្សាស្រាវជ្រាវដទៃទៀត ក៏ដូចអ្នកប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ដទៃទៀតយ៉ាងម៉េចនោះទេ។ ដូច្នេះមិនមានខ្លឹមសារ ឬក៏ខ្ញុំមិនមានការទាក់ទងអ្វីច្រើនទាក់ទងទៅនឹងបញ្ហានេះទេ។ អ្នកណាក៏ដោយ ដែលក្លាយជាអ្នកប្រវត្តិសាស្ត្ររបស់អាស៊ីអាគ្នេយ៍ គឺអាចសុទ្ធតែជាអ្នកសរសេរប្រើប្រាស់ភាសាបារាំង ឬក៏ភាសាអង់គ្លេស។ ឧទាហរណ៍ ដូចជាអ្នកសិក្សាស្រាវជ្រាវអំពីប្រវត្តិសាស្ត្រសម័យទំនើប ឬក៏សម័យបុរាណនៅក្នុងប្រទេសកម្ពុជា។ ដូច្នេះហើយអ្នកណាក៏ម្នាក់ក៏អាចស្នើបានដែរថាដើម្បីឲ្យមានភាពជឿទុកចិត្តបានក្នុងលក្ខណៈជាអ្នកប្រវត្តិសាស្ត្រអាស៊ីអាគ្នេយ៍ គឺគួរតែមានការទទួលស្គាល់ពីលោក ដេវីដ ឆេនដ៍ល័រ។ នេះគឺជាមូលហេតុដែលគាត់សរសេរនៅលើសៀវភៅរបស់ខ្ញុំ។

[០៩:២៦:៥៦]

**ស៖** នៅក្នុងឯកសារដែលលោកបានអានទាំងអស់ អំពីលោកសាស្ត្រាចារ្យ ប៉ែន ឃៀរនិន តើលោកយល់ឃើញដូចគ្នាទាក់ទងទៅនឹងបញ្ហាហ្នឹង ដូចដែលលោកនិយាយអំពីលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ដែរឬទេ?

**ឆ៖** អត់ទេ មិនទេ។ មិនមែននៅក្នុងសហគមន៍អ្នកសិក្សាស្រាវជ្រាវដែលខ្ញុំតែងតែចូលរួមជា-មួយនោះទេ។ ប្រហែលជាគាត់ជាផ្នែកមួយនៃសហគមន៍នុ៎ងដែរ ព្រោះថាយ៉ាងណាក៏ដោយវាមានការបែងចែកគំនិតគ្នារវាងអ្នកសិក្សាស្រាវជ្រាវផ្សេងៗគ្នា។ គឺថាក្រុមគាត់ របស់ក្រុមខ្ញុំអាចមានលក្ខណៈផ្សេងពីគ្នា គឺថាខ្ញុំមានគំនិតផ្សេងរបស់ខ្ញុំ។ ចំណែកគំនិតរបស់គាត់គឺផ្សេងពីនេះ ទៅខាងផ្សេងមួយក្រុមទៀត។

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ តើលោកតែងតែរិះគន់អំពីការងាររបស់លោក ប៉ែន ឃៀរនិន នៅក្នុងសៀវភៅរបស់លោក តើមែនទេ?

[០៩:២៨:០៧]

**ឆ៖** បាទ។ ហើយដូចគ្នា ប៉ែន ឃៀរនិន ក៏រិះគន់អំពីការពាររបស់ខ្ញុំផងដែរ។ បាទនេះគឺជាផ្នែកនៃការសិក្សាស្រាវជ្រាវដែលយើងត្រូវតែមានការរិះគន់គ្នាទៅវិញទៅមកបែបនេះ។**ស៖** តើលោកធ្លាប់អានសៀវភៅរបស់ ប៉ែន ឃៀរនិន ទាំងអស់ដែរឬទេ?

**ឆ៖** ទោះបីថាយ៉ាងណាក៏ដោយ គឺថាគាត់ហាក់ដូចជាសរសេរបានច្រើន សរសេរបានវែងជាងខ្ញុំ។ ទោះបីថាខ្ញុំមិនបានអានឲ្យបានលម្អិតទាំងអស់ ប៉ុន្តែខ្ញុំបានអានគ្រប់ទំព័រនៃសៀវភៅរបស់គាត់ ដែលសរសេរអំពីកម្ពុជា។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអំពីខ្លួនលោកផ្ទាល់ ទាំង ប៉ែន ឃៀរនិន ទាំងលោក ដេវីដ ឆេនដ៍ល័រ គឺជាសាស្ត្រាចារ្យ ប៉ុន្តែលោកអត់មានតួនាទីជាសាស្ត្រាចារ្យនោះទេ។ តើលោកអាចពន្យល់បានដែរឬទេថា ហេតុអ្វីបានជាលោកមិនមានតួនាទីជាសាស្ត្រាចារ្យនៅក្នុងផ្នែកវិទ្យាសាស្ត្រនយោបាយ ឬក៏មិនមានឋានៈជាសាស្ត្រាចារ្យបែបនេះ?

[០៩:២៩:៣៤]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍ន័រ៖**

ខ្ញុំជំទាស់ទៅលើសំណួរនេះ ដោយសារតែមូលដ្ឋានមិនមានភាពពាក់ព័ន្ធ។ ខ្ញុំមិនដឹងថាតើសំណួរបែបនេះ មានភាពពាក់ព័ន្ធបែបណានោះទេ។ មានតែភស្តុតាងដែលអាចទទួលយកបានទេ ដែលពាក់ព័ន្ធ។ ចំពោះខ្ញុំៗយល់ថាសំណួរបែបនេះគឺគ្មានភាពពាក់ព័ន្ធទាក់តែសោះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយ នេះគឺជាសំណួរដែលពាក់ព័ន្ធព្រោះថាជាសំណួរទាក់ទងទៅនឹងសាក្សីនេះ។

[០៩:៣០:០៧]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មានមូលហេតុ និងសំអាងហេតុត្រឹមត្រូវ សំណួរនេះមិនមានភាពពាក់ព័ន្ធទេ។ ដូច្នេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេងឌ័រ តើលោកមានបានធ្លាប់មើលខ្សែវីដេអូ ដែលមានចំណងជើងថា "ថ្ងៃមួយនៅទួលពោធិ៍ជ្រៃ" ទេ?

**លោក ស៊្មីរ ហេងឌ័រ៖**

**ឆ៖** អត់ទេ។

[០៩:៣០:៥៤]

**ស៖** ប្រសិនបើផ្អែកទៅលើការស្រាវជ្រាវរបស់លោក ឬក៏ការងារសិក្សារបស់លោក តើលោកអាចនិយាយ -- តើលោកអាចឆ្លើយអ្វីបានខ្លះទាក់ទងទៅនឹងលោក ចេត សម្បត្តិ និង វ៉ាប់ លីមគិន បានដែរឬទេ?

**ឆ៖** ខ្ញុំមិនអាចនិយាយអ្វីបានច្រើននោះទេ។ ខ្ញុំធ្លាប់ជួបពួកគាត់ទាំងពីរនាក់បានមួយភ្លែត ប៉ុន្តែខ្ញុំមិន -- ខ្ញុំអាចនិយាយបានថា ខ្ញុំមិនដែលនិយាយគ្នាឱ្យបានលម្អិត ឱ្យបានច្រើននោះទេ។ ខ្ញុំធ្លាប់មើលខ្សែវីដេអូទី១ ដែលពួកគេបានផលិត។ ប៉ុន្តែខ្ញុំដូចជាមិនមានភាពចំណាប់អារម្មណ៍ខ្លាំងក្លាចំពោះខ្សែភាពយន្តនោះទេ។ ប៉ុន្តែខ្សែភាពយន្តនេះ គឺត្រូវបានផលិតក្នុងពេលជាមួយគ្នានឹងខ្សែភាពយន្តដែលផលិតឡើងដោយ ប៊ី.ប៊ី.ស៊ី ហើយខ្ញុំចាប់អារម្មណ៍ខ្លាំងទៅលើបញ្ហាទាំងអស់នោះ។ ប៉ុន្តែដោយសារតែមិនឯកសារនៅចំពោះមុខខ្ញុំ ទាក់ទងទៅនឹងខ្សែភាពយន្តនេះ ខ្ញុំមិនដឹងថា ខ្ញុំអាចនិយាយអ្វីឱ្យបានលម្អិតនោះទេ។

**ស៖** សំណួរមួយទៀតដែលខ្ញុំចង់សួរលោកសាក្សី គឺខ្ញុំចង់និយាយយោងទៅដល់សៀវភៅបោះពុម្ពរបស់លោក ដែលនិយាយអំពី ឡេនីន-ម៉ាក្សស៊ីស គឺអំពី -- គឺឯកសារ E -- គឺឯកសារ 131/1/131.3 ភាសាអង់គ្លេស -- ភាសា--

**អ្នកបកប្រែ៖**

លោកប្រធានស្នើសុំឱ្យមេធាវីអាននៅលេខ ERN សាជាថ្មី!

**ប្រធានអង្គជំនុំ៖**

លោក វ៉ិចទ័រ កូប៉េ អានលេខឯកសារ និងលេខ ERN នៃឯកសារសាជាថ្មី ព្រោះអ្នកបកប្រែបកប្រែភាសារបស់លោកមិនទាន់ទេ! ហើយសូមឱ្យយឺតបន្តិច។

[០៩:៣៣:១៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** គឺឯកសារ E131/1/13.3 ភាសាអង់គ្លេសមានលេខ 00773700, ភាសាបារាំងមានលេខ 00802800 និងភាសាខ្មែរមានលេខ 00844550។ នៅក្នុងទំព័រទី១ នៃអត្ថបទនោះ នៅត្រង់ជើងទំព័រ គឺលោកបានសរសេរថា "លោកចង់ លោកសូមថ្លែងអំណរគុណចំពោះបុគ្គលមួយចំនួនដែលបានចូលរួមចំណែកដល់ការបោះពុម្ពផ្សាយមួយនេះ។ ហើយលោកបានបញ្ជាក់ក្នុងនោះដូចជា ដេវីដ ឆេនដ៍ល័រ ហើយក្នុងចំណោមអ្នកដទៃទៀតគឺ ឡូរ៉ា សាំមី"។ តើលោកអាចបញ្ជាក់បានដែរឬទេ តើ ឡូរ៉ា សាំមី ហ្នឹងជាអ្នកណា ដែលលោកនិយាយយោងនៅក្នុងការថ្លែងអំណរគុណនេះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ឡូរ៉ា សាំមី គឺជាមនុស្សម្នាក់ដែលជានិស្សិតខាងបណ្ឌិតនៅខូរណែល នៅពេលដែលខ្ញុំជានិស្សិតបរិញ្ញាបត្រនៅទីនោះ គឺនៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ៧០ គឺមុនពេលដែលខ្ញុំមកប្រទេសកម្ពុជានៅក្នុងឆ្នាំ៧៣។ ហើយក្រោយមកទៀត ឡូរ៉ា សាំមី គាត់ទៅបង្រៀននៅសាកលវិទ្យាល័យជាច្រើននៅប្រទេសអង់គ្លេស។

[០៩:៣៤:៥៦]

ដូច្នេះគាត់នៅក្នុង -- គឺថាគាត់ទៅត្រឡប់ទៅមកៗ ក្នុងប្រទេសអង់គ្លេស។ ហើយនៅពេលដែលខ្ញុំចាប់ផ្តើមសរសេរ គឺថាគាត់សរសេរសារណាបណ្ឌិតរបស់គាត់អំពីប្រទេសកម្ពុជា ដែលគាត់សម្ភាសជាមួយ គាត់ផ្អែកទៅលើសារណាបណ្ឌិតរបស់លោក ខៀវ សំផន ផងដែរ។ ដូច្នេះគឺថាគាត់ផ្តោតសំខាន់ទៅលើវិទ្យាសាស្ត្រនយោបាយ ប្រវត្តិសាស្ត្រនយោបាយ គាត់គឺជាអ្នកសិក្សាស្រាវជ្រាវដ៏ល្អមួយ។

**ស៖** ខ្ញុំស្តាប់លោកឮហើយ លោកថាឥឡូវនេះគាត់ចូលនិវត្តន៍ហើយ។ ខ្ញុំសូមត្រឡប់ទៅសំណួរអំពីប្រវត្តិផ្ទាល់ខ្លួនរបស់លោកវិញម្តងលោក ហេដឌ័រ។ ម្សិលមិញ ក៏ដូចជាពីថ្ងៃមុនលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាដែលតែងតែយោងទៅលើឯកសារ ឬក៏ព័ត៌មានដែលលោកទទួលបានចន្លោះពី៧៣ ទៅ៧៥ ពីសេនានុព័ន្ធយោធាអមស្ថានទូតអាមេរិក ឬក៏អមកុងស៊ុលអាមេរិក។ តើលោកអាចពន្យល់ឲ្យបានទូលាយបន្តិចទេនៅអំឡុងពេលហ្នឹង ដែលលោកទាក់ទងជាមួយនឹងសេនានុព័ន្ធយោធានោះ?

[០៩:៣៦:៣៩]

**ឆ៖** បើខ្ញុំចាំមិនច្រឡំទេ ទំនាក់ទំនងជាមួយស្ថានទូតអាមេរិកហ្នឹងគឺគេហៅថា "មេដ ថេច" គឺខ្ញុំ

ភ្លេចហើយថាគាត់ទទួលផ្នែកស្អីហើយ។ ក៏ប៉ុន្តែយោងតាមច្បាប់អាមេរិកទាហានអាមេរិកពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា គឺត្រូវតែមានវិន័យហ្នឹង គឺថាតឹងរ៉ឹង គឺមានការពាក់ព័ន្ធហ្នឹង គឺថាមានការតឹងរ៉ឹងណាស់។ មិនមានទ័ពជើងគោកណាមួយ ឬក៏ទ័ពណាមួយមានមូលដ្ឋាននៅកម្ពុជាទេ។ ជាពិសេសទាក់ទងទៅនឹងការផ្តល់ជាយោបល់ណាមួយ ឬក៏ការផ្តល់ជំនួយណាមួយដោយសារថាមិនមានទីប្រឹក្សាយោធា ឬក៏ទីប្រឹក្សា -- ទីប្រឹក្សាយោធា ឬយោធានៅ ប៉ុន្តែ មេដ ថេច នៅអមទៅនឹងស្ថានទូតសហរដ្ឋអាមេរិក។ គឺគោលការណ៍ហ្នឹង គឺដើម្បីពិនិត្យមើលអំពីជំនួយផ្នែកយោធាណាមួយ។ ហើយក្នុងនេះផងដែរ គឺថាគ្រប់ជនជាតិអាមេរិកាំងទាំងអស់ គឺមានក្បាលម៉ាស៊ីន គេមានភ្នាក់ងារស៊ើបការណ៍សម្ងាត់ដូចជា មេដ ថេច ហ្នឹងគាត់ធ្វើការជាមន្ត្រីយោធារបស់អាមេរិក។

[០៩:៣៨:១៣]

ដូច្នេះខ្ញុំបានទាក់ទងមនុស្សខ្លះក្នុងចំណោមហ្នឹង ក្នុងនោះមានក៏ដូចប្រធានសេនានុព័ន្ធយោធា ក៏ដូចជាប្រធានភ្នាក់ងារស៊ើបការណ៍សម្ងាត់ដោយយើងពិភាក្សាគ្នាអំពីស្ថានភាពយោធា ហើយដែលពេលខ្លះ គឺថាខ្ញុំទទួលបានឯកសារពីអ្នកទាំងនោះមក។ បើសិនជាលោកសួរខ្ញុំថា អ្នកទាំងនោះជាអ្នកណា? ខ្ញុំកំពុងគិតហ្នឹង វាអត់ចាំ អត់ចាំឈ្មោះអ្នកទាំងនោះទេ។ ខ្ញុំកំពុងតែរំឭកឈ្មោះអ្នកទាំងអស់នោះដែរ តែអត់ចាំ។ ខ្ញុំនឹកមិនឃើញរួមទាំងឈ្មោះរបស់សេនានុព័ន្ធយោធាជប៉ុនផងដែរ។

**ស៖** បើខ្ញុំចាំសក្ខីកម្មរបស់លោកមិនច្រឡំទេ លោកមកដល់កម្ពុជាហ្នឹងនៅឆ្នាំ៧៣ លោកធ្វើការជាអ្នកសារព័ត៌មាន។ តើលោកអាចប្រៀបធៀបខ្លួនលោកជាមួយនឹងអ្នកសារព័ត៌មានដទៃទៀតបានទេនៅពេលហ្នឹងទាក់ទងទៅនឹងលទ្ធភាពរបស់លោកក្នុងការទទួល ក្នុងការទំនាក់ទំនងជាមួយនឹងសេនានុព័ន្ធយោធាអាមេរិកនេះ? ថាតើលោកមានទំនាក់ទំនងច្រើនជាងអ្នកកាសែតដទៃទៀត ឬយ៉ាងណា?

[០៩:៣៩:៣៦]

**ឆ៖** ខ្ញុំគិតថាជាមធ្យម បាទទំនាក់ទំនងហ្នឹង ខ្ញុំធ្វើបានជាមធ្យម។ អ្នកខ្លះជាអ្នកសារព័ត៌មានហ្នឹងគឺថាជាន់ខ្ពស់ជាងខ្ញុំ មានបទពិសោធន៍ច្រើនជាងខ្ញុំ ហើយមានការវិវត្តនៅក្នុងបរិបទកម្ពុជាហ្នឹង គឺថាក៏ច្រើន នៅក្នុងរដ្ឋាភិបាលអាមេរិកក៏ច្រើន។ ដូច្នេះគឺពួកគាត់ទាំងនោះខ្លះ គឺថាមានលទ្ធភាពទទួលបានទំនាក់ទំនងឯកសារហ្នឹង គឺថាគ្រាន់បើជាងខ្ញុំទៅទៀត។ ខ្ញុំអត់មានមានទំនាក់ទំនងលទ្ធភាពពិសេសអីជាងអ្នកទាំងអស់នោះ ឬក៏លទ្ធភាពដាច់មុខក្នុងការទំនាក់ទំនងជាមួយមន្ត្រីអាមេរិកនោះទេ។

**ស៖** លោកចាំទេនៅពេលនោះ ក្នុងការនិយាយស្តី ឬក៏ទំនាក់ទំនងក្តីជាមួយនឹងអ្នកកាសែតដែល

មានបទពិសោធន៍តិចជាងលោកឈ្មោះ ស៊ីដនី ស្តេនប៊ឹក នោះលោកស្គាល់ទេ?

**ធ៖** ស៊ីដនី នោះគាត់រស់នៅពេញអំឡុងពេលនៅក្នុងទីក្រុងភ្នំពេញ ខ្ញុំមានទំនាក់ទំនងជាមួយគាត់ដែរ ប៉ុន្តែមិនជាច្រើនទេជាមួយ ស៊ីដនី នេះ។

**ស៖** ដូច្នេះមានន័យថាតាមការចងចាំរបស់លោក ថាតើគាត់មានទំនាក់ទំនងដូចលោក ឬក៏ច្រើនជាងលោកជាមួយនឹងសេនានុព័ន្ធយោធាអាមេរិកនោះ?

[០៩:៤១:១៦]

**ធ៖** ទំនាក់ទំនងរវាងខ្ញុំនិង ស៊ីដនី គឺថា យើងមិនបានចែករំលែកព័ត៌មានពីខាងហ្នឹងនោះទេ។

**ស៖** នៅក្នុងអំឡុងប៉ុន្មានឆ្នាំនោះលោក ហេដឌ័រ តើគេមានដែលជួយលោក ឬជ្រើសរើសឲ្យលោកធ្វើជាភ្នាក់ងារសម្ងាត់អាមេរិកដែរឬទេ ក្នុងពេលនុ៎ង?

**ធ៖** ខ្លីទេគឺអត់ទេ។

**ស៖** ចុះចម្លើយវែងវិញ?

**ធ៖** ចម្លើយវែងគឺថា ចន្លោះពី៧៥ ទៅឆ្នាំ៨៤ ខ្ញុំមានគេហៅថា មូលនិធិសិក្សាស្រាវជ្រាវមួយមកពីសម្រាប់កិច្ចការស្រាវជ្រាវផ្ទៃក្នុងសម្រាប់ការិយាល័យភ្នាក់ងារសម្ងាត់នៃក្រសួងការពារជាតិអាមេរិក និងគឺយើងយោងទៅលើមូលដ្ឋាន ឬទៅលើលក្ខខណ្ឌនៃកិច្ចសន្យា។ ចំណុចមួយគឺគេជួល ត្រូវបានក្រសួងការពារជាតិអាមេរិកជួលខ្ញុំ ដោយសារខ្ញុំត្រូវកាត់ពន្ធដោយអាមេរិក ហើយនិងអង់គ្លេស។ ដូច្នេះខ្ញុំត្រូវគិត។

[០៩:៤៣:៥៧]

បាទ ឥឡូវនេះខ្ញុំច្បាស់ហើយគឺថា មិនត្រូវយល់ថា ហ្នឹងគឺថាការជ្រើសជួលខ្ញុំទេ។ មូលនិធិនេះជាមូលនិធិដែលគេផ្តល់មក ដើម្បីធ្វើការសិក្សាស្រាវជ្រាវក្នុងឋានៈជាអ្នកជំនាញ មិនមែនជាបែបកិច្ចសន្យាអីណានោះទេ។ វាដូចគ្នាទៅនឹងស្ថានភាពដែលខ្ញុំរៀបរាប់អំពីថវិកាសម្រាប់សិក្សាស្រាវ ជ្រាវមកចូលស្ថាប័នសិក្សាណាមួយសិន។ ហើយបន្ទាប់មកគេនឹងស្ថាប័នសិក្សានោះនឹងចំណាយទៅតាមហ្នឹង។ វាជាចំណូល ក៏ប៉ុន្តែមិនមែនជាប្រាក់បៀវត្សរ៍ វាជាមូលនិធិមួយ ប៉ុន្តែមិនមែនជាការជ្រើស រើសបែបកិច្ចសន្យាណាមួយទេ។ បាទជាថវិកាសាធារណៈ ទាំងប្រភពធនធាន តាំងពីទិន្នផលថវិកាហ្នឹង សម្រាប់សាធារណៈហើយ។ ដូច្នេះវាមានរដ្ឋាភិបាលអាមេរិកមួយដែលខ្ញុំទទួលបានថវិកាហ្នឹង ខ្ញុំក៏ទទួលបានថវិកាពីរដ្ឋាភិបាល អង់គ្លេស សម្រាប់ការសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយក្នុងហ្នឹង

ដោយសារដូចខ្ញុំជម្រាបអ៊ីចឹងមូលនិធិ មិនមែនជាកុងត្រាទេ។ យើងខ្ញុំក៏បានទទួលបាន ថវិកាខាងរដ្ឋាភិបាលថៃ។ ដូច្នេះចម្លើយជាបច្ចេកទេសគឺអត់ទេ។

[០៩:៤៤:៤៥]

**ស៖** តើមានពេលណាមួយនោះនៅក្នុងឆ្នាំ២០០៣ លោកមានដាក់សំណើសុំសៀវភៅមួយ និយាយអំពី "អំពើប្រល័យពូជសាសន៍ខ្លួនឯង និងការកាប់សម្លាប់ចន្លោះពី៧៥ទៅ៧៨" ដែរឬទេ?

**ឆ៖** ខ្ញុំបានដាក់សំណើសុំបោះពុម្ពសៀវភៅជាច្រើន ប៉ុន្តែខ្ញុំមិនដឹងថាសៀវភៅមួយនេះក្នុងចំណោមសៀវភៅទាំងនោះឬក៏អត់ទេ វាអាច។

**ស៖** តើសំណើសុំបោះពុម្ពសៀវភៅនុ៎ង មានធ្វើកំណត់ត្រាបញ្ជាក់ផងដែរទេ ដែលថាលោកសិក្សាស្រាវជ្រាវអំពីបក្សកុម្មុយនីស្តកម្ពុជាហ្នឹងរហូតទៅដល់៣០ឆ្នាំឯណោះជាដើម?

**ឆ៖** ទម្រង់តាមធម្មតាវាជាការវិភាគបែបអ្នកយកព័ត៌មាន គឺជាការវិភាគបែបព័ត៌មានសម្ងាត់។ ខ្ញុំគិតថាឃើញថាមូលនិធិនុ៎ង គឺប្រហែលជាខ្ញុំបាត់ដានឯកសារហ្នឹង។ នៅក្នុងបរិបទនេះគឺថាគឺសម្រាប់ការសិក្សាស្រាវជ្រាវផ្ទៃក្នុង សម្រាប់ដែលសហរដ្ឋអាមេរិកបានផ្តល់ថវិកាមកតាមរយៈក្រសួងការពារជាតិ។ មិនមែនតែសិក្សា -- មិនមែនសិក្សាសម្រាប់ពេលខ្មែរក្រហមនៅក្នុងអំណាចទេ។ គឺសិក្សាស្រាវជ្រាវនេះអំឡុងពេលដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះ គឺនិយាយអំពីស្ថានភាពទូទៅនៅក្នុងប្រទេសកម្ពុជាក្រោយឆ្នាំ១៩៧៩ គឺថាវាជាឯកសារសិក្សាស្រាវជ្រាវហើយ។

[០៩:៤៦:៥៩]

**ស៖** តើលោកស្គាល់សៀវភៅមួយក្បាលរបស់ ប៉ែន ឃៀវនិន ដែលមានចំណងជើងថា "នាំខ្មែរក្រហមយកមកកាត់ទោស"ទេ? ឬក៏អាចជាជំពូកណាមួយដែលមានចំណងជើង "ការនាំយកខ្មែរក្រហមយកមកកាត់ទោស"?

**ឆ៖** បើសិនណាជាខ្ញុំឃើញការបោះពុម្ពផ្សាយហ្នឹង ប្រហែលជាខ្ញុំអាចនឹងចាំបាន។

**លោក ឃីត វេយ៍ន័រ៖**

យើងខ្ញុំសូមឲ្យមានការបញ្ជាក់ផង ថាតើជំពូកណាទៅដល់ជំពូកណា? ហើយស្ថិតនៅក្នុងសៀវភៅមានចំណងជើងឈ្មោះថាម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំយោងទៅឯកសារ D269/5.1 ទំព័រ២២៥ លេខយោងជើងទំព័រ១៦ លេខយោង១៦។

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៤៨:១៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេងឆ័រ--

**ប្រធានអង្គជំនុំ៖**

ឈប់បន្តិចសិនលោកមេធាវី!

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ វាជាបញ្ហាបច្ចេកទេស លោក កូប៉េ ឯកសារនេះមាន D វាមានជាអក្សរជា D លេខ D ថាតើមានដាក់នៅក្នុងចំពោះមុខអង្គជំនុំជម្រះហើយ?

**លោក វ៉ិចទ័រ កូប៉េ៖**

បានដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយ ខ្ញុំព្យាយាមរកលេខ ERN ផងដែរ។ ខ្ញុំគិតថា ERN 00489660 ជាឯកសារដែលមានលេខ D ភ្ជាប់ទៅជាមួយនឹងឯកសារនេះ មាននៅក្នុងសំណុំរឿង ហើយលោកស្រីចៅក្រម។ ខ្ញុំមាន ERN គឺ 00488360។

[០៩:៤៩:២៥]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ថាតើមានដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយ ហើយមានចំណងជើងថាម៉េចដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណងជើងថា "ប៉ែន យៀរនិន អំពើប្រល័យពូជសាសន៍ និងប្រវត្តិសាស្ត្រនៅអាស៊ីអាគ្នេយ៍"។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

តើឯកសារនេះដាក់នៅចំពោះមុខអង្គជំនុំជម្រះហើយឬនៅ?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទលោកស្រីចៅក្រម ខ្ញុំនឹងជម្រាបជូននៅពេលក្រោយ។ បើដូច្នេះគឺថាសូមចូលទៅចំណុចផ្សេងបាទ។ ខ្ញុំនឹងរៀបសំណួរឡើងវិញក្នុងលក្ខណៈជាទូទៅមួយ។

[០៩:៥០:០៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោក ហេងឆ័រ តើលោកបានជ្រាបទេ ដែលថា ប៉ែន យៀវនិន បានផ្តល់គុណវុឌ្ឍិកំណត់ថាអ៊ីចេះ លោកគឺជាភ្នាក់ងារសម្ងាត់?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ខ្ញុំមិនចាំ មិនបានកត់ត្រាប្រហែលជាអាចអ៊ីចឹងដែរ។ គឺដោយសារតែមូលដ្ឋាននៃការយល់ច្រឡំទំនាក់ទំនងរវាងខ្ញុំ និង ដាយអាណា ដែលខ្ញុំបានពន្យល់ហើយថា វាជាការយល់ច្រឡំរវាងកិច្ចសន្យាដែលកំណត់ខ្ញុំនោះ ថាជានិយោជករបស់សហរដ្ឋអាមេរិក។ ក៏ដូចជាការយល់ច្រឡំរវាងបានមូលនិធិពីស្ថានទូតអង់គ្លេសប្រចាំនៅស្ថានទូតអង់គ្លេសនៅប្រចាំ ក៏ដូចជាយូនីស្កូដែលបានពីនៅក្នុងប្រទេសថៃដែលរដ្ឋាភិបាលថៃគេផ្តល់កិច្ចសន្យាមកឲ្យខ្ញុំ។ ដូចខ្ញុំបានជម្រាបហើយទាក់ទងទៅនឹងកិច្ចការរបស់ខ្ញុំនេះ កិច្ចសន្យាដែលខ្ញុំបានទទួលនេះ គឺខ្ញុំប្រមូលព័ត៌មានសម្ងាត់ និងវិភាគព័ត៌មានសម្ងាត់មែន។ ប៉ុន្តែគេអាចអ្នកៗខ្លះ កាលណាឃើញការងារបែបនេះ អាចនិយាយហើយថាជាភ្នាក់ងារសម្ងាត់ហើយ។

[០៩:៥១:២៩]

**ស៖** លោក ហេងឆ័រ ខ្ញុំសូមចូលទៅចម្លើយដែលលោកបានឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាកាលពីសប្តាហ៍មុន តាំងពីដើមដំបូងមកម្ល៉េះ។ លោកបានផ្តល់សក្ខីកម្មថា លោកបានដាក់ពាក្យធ្វើការនៅអង្គការសហប្រជាជាតិនៃសាលាក្តីខ្មែរក្រហមនេះ ជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ហើយក្រោយលោកទទួលបានតួនាទីនេះមក គឺនៅក្នុង២០០៦ ហើយពេលនោះលោកក៏បានផ្តាច់ខ្លួនចេញមកតាមសំណើរបស់សហព្រះរាជអាជ្ញានៅពេលនោះ លោក រ៉ូប៊ឺត ពើទីត ស្នើសុំឲ្យលោកចូលមកធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញា។ តើខ្ញុំសង្ខេបបែបនេះត្រឹមត្រូវទេ?

**ឆ៖** បាទ ត្រូវហើយ។

**ស៖** ពេលដែលគេខ្ចីលោកឲ្យធ្វើការជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា ហើយក្រោយមកលោកមានត្រឡប់ទៅធ្វើការជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតវិញទេ?

**ឆ៖** វាច្បាស់ហើយចំពោះចៅក្រម ឡឺម៉ុងដ៏ ហើយខ្ញុំគិតថាសហព្រះរាជអាជ្ញា រ៉ូប៊ឺត ពើទីត ក៏មានផែនការ ឬសង្ស័យថា ខ្ញុំហ្នឹងគឺថាវាអាចនឹងមានបញ្ហានៅក្នុងការងារក្នុងកន្លែងទាំងពីរហ្នឹង គេអាចនឹង--។

[០៩:៥៣:១៩]

**ស៖** ទាក់ទងទៅនឹងសេចក្តីសម្រេចដោយច្បាស់ហ្នឹង ឬក៏សេចក្តីសម្រេចណាមួយពីចៅក្រម ឡឺម៉ុងដ៍ និយាយអំពីលទ្ធភាពនៃៗទំនាស់ផលប្រយោជន៍ដែរឬទេ រវាងចន្លោះកន្លែងទាំងពីរហ្នឹង?

**ឆ៖** បើៗខ្ញុំចាំមិនច្រឡំទេ ខាងអង់ក្លូសាក់សុងអាចគិតថាអ៊ីចេះ ប៉ុន្តែខាងអង់ក្លូសាក់សុងក៏អាចខុសដែរ។

**ស៖** ថាតើលោកចាំទេ លោកមានធ្វើការជំទាស់ក្នុងការជួយគាំទ្រទៅដល់ខាងតួនាទីរបស់លោកនេះទេ?

**ឆ៖** និយាយដោយត្រង់ទៅ ចៅក្រម ឡឺម៉ុងដ៍ មិនបានពន្យល់អំពីសេចក្តីសម្រេចរបស់គាត់ទៅនឹងបុគ្គលិកទាំងអស់ទាក់ទងទៅនឹងទឡ្ហីករណ៍ផ្នែកច្បាប់ណាមួយនោះទេ។

**ស៖** ពេលដែលលោកធ្វើការឲ្យសហព្រះរាជអាជ្ញាក្នុងឆ្នាំ២០០៦ មុននឹងលោកត្រឡប់មកវិញ ថាតើលោកមានធ្វើ មានបានផ្តល់អនុសាសន៍ណាមួយថាតើអ្នកណាត្រូវសម្ភាស អ្នកណាមិនត្រូវសម្ភាសអីដែរទេ?

[០៩:៥៤:៤៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត សេយ្យ័នរ៖**

ខ្ញុំសូមជំទាស់ ប៉ុន្តែមិនជំទាស់ទៅនឹងសំណួរមុនៗទេ សំណួរនេះតែម្តង។ គឺថាមានសេចក្តីសម្រេចជាច្រើនអំពីវិសាលភាពនៃសំណួរពាក់ព័ន្ធទៅនឹងកិច្ចដំណើរការនីតិវិធី។ ខ្ញុំមានសេចក្តីសម្រេចពីថ្ងៃ០៧ ខែធ្នូ ២០១២ ក្របខ័ណ្ឌគតិយុត្តរបស់ អ.វ.ត.ក មាននិយាយអំពីភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី នៃកិច្ចដំណើរកិច្ចការស៊ើបសួរដែលនៅក្នុងការទទួលបានកំណត់ហេតុស្តាប់ចម្លើយហើយ។ គឺថាយើងមានលក្ខណៈខុសៗគ្នា ហើយដូចលោកស្រីចៅក្រម ខាតវ៉ាយថ៍ លើកឡើងនៅថ្ងៃទី០១ នៃការសួរចម្លើយលោក ហេដឌ័រ ហើយថា សំណើរបស់ខ្ញុំៗគិតថា យើងកំពុងតែឈានចូលទៅលើយុត្តាធិការដែលលោកស្រីចៅក្រម ខាតវ៉ាយថ៍ គាត់បានលើកឡើងរួចមកហើយ។ ហើយឥឡូវនេះគឺថាកំពុងតែឈានចូលដល់ចំណុចនេះហើយ ខ្ញុំសូមជំទាស់តែម្តង។

[០៩:៥៦:០៧]

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំសូមឆ្លើយលោកប្រធាន ខ្ញុំដឹងអំពីសេចក្តីសម្រេចទៅលើបញ្ហានុ៎ង មិនមែនជាចេតនារបស់ខ្ញុំក្នុងការសួរលម្អិតទៅលើសកម្មភាព ឬកិច្ចការរបស់សាក្សីរូបនេះទេ។ នៅពេលដែលគាត់ធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំមានសំណួរទូទៅ បាទ គឺកិច្ចការទូទៅរបស់គាត់តែប៉ុណ្ណោះ។ បើសិនជាមិនសួរជាក់លាក់ណាមួយដូចជាឈ្មោះសាក្សីជាដើម ដើម្បីឲ្យខ្ញុំយល់អំពីកិច្ចការរបស់គាត់ក្នុងលក្ខណៈទូទៅ ដែលគាត់ធ្វើការ ខ្ញុំសួរតែទូទៅតែប៉ុណ្ណោះ ពេលដែលគាត់ធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញា។

[០៩:៥៦:៥៥]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៥៨:០៣]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយ ដែលសួរឡើងដោយមេធាវីការពារក្តីលោក នួន ជា ចំពោះសាក្សីរូបនេះ គឺសេចក្តីជំទាស់នេះ គឺមានប្រសិទ្ធភាព ដោយសារមានសំអាងហេតុត្រឹមត្រូវ។ ហើយអង្គជំនុំជម្រះសូមជម្រាបថា បញ្ហាទំនាស់ផលប្រយោជន៍នៅក្នុងកិច្ចដំណើរការនីតិវិធីកន្លងមក ត្រូវបានដោះស្រាយដោយអង្គបុរេជំនុំជម្រះរួចហើយលើបញ្ហានេះ។ ហើយសូមឲ្យមេធាវីបន្តការតាំងសំណួរសារធាតុដែលមានប្រយោជន៍នៅក្នុងការពិភាក្សា -- ពិចារណាស្វែងរកការពិតក្នុងរឿងក្តីនេះ។

**លោក វ៉ិចទ័រ កូប៉េះ**

គឺសូម -- ដើម្បីប្រតិចារឹក ថាតើខ្ញុំសូមសួរសំណួរបីបួនដែលខ្ញុំបានសួរហើយ ហើយដែលមិនអនុញ្ញាតឲ្យខ្ញុំ -- មិនអនុញ្ញាតឲ្យសាក្សីឆ្លើយ ដើម្បីជាប្រតិចារឹក គឺថាសំណួរទាំងនេះ គឺត្រូវអង្គជំនុំជម្រះបដិសេធ ឬក៏យ៉ាងណា?

[០៩:៥៩:២៥]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចបដិសេធថា សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា មានសំអាងហេតុត្រឹមត្រូវ ដូច្នេះសេចក្តីជំទាស់នេះមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរ

នេះទេ។ សូមឲ្យលោកមេធាវីបន្តការតាំងសំណួរសារធាតុ ដែលពាក់ព័ន្ធទៅនឹងអង្គហេតុអង្គជំនុំជម្រះកំណត់ធ្វើសវនាការ ដើម្បីជាប្រយោជន៍សម្រាប់អង្គជំនុំជម្រះយកទៅមកពិចារណាសម្រេចនៅក្នុងផ្នែកសំណុំរឿង ០០២/០១ ដែលអង្គជំនុំជម្រះកំណត់ធ្វើសវនាការនាពេលនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន! ខ្ញុំសូមញែកឲ្យដាច់ពីគ្នាក្នុងការតាំងសំណួរជាមួយសាក្សីរូបនេះ អំពីការដឹងឮរបស់គាត់នៅក្នុងតួនាទីផ្សេងៗដែលគាត់បានបំពេញនៅក្នុងជីវិតរបស់គាត់នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយមួយទាក់ទងជាមួយការងាររបស់គាត់ជាមួយការិល័យសហចៅក្រមស៊ើបអង្កេត។ តើចៅក្រម ឡឺមុងដ៍ ដែលសួរលោកឲ្យស្វែងរកតែភស្តុតាងដាក់បន្ទុក ដោយមិនឲ្យរកភស្តុតាងដោះបន្ទុកទេ ឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១០:០០:៥៧]

**លោក ឃីត រេយ៉ន័រ៖**

ការជំទាស់ដូចតែគ្នា ហើយសំអាងទៅលើមូលហេតុដូចគ្នា។

**ប្រធានអង្គជំនុំ៖**

បាទ បើមិនមានអីឆ្លើយតបទេ អង្គជំនុំជម្រះសម្រេចថា សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា គឺសមស្រប។ ដូច្នេះ សេចក្តីជំទាស់ហ្នឹងមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរចុងក្រោយនេះ របស់មេធាវីការពារក្តីទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដូច្នេះ ខ្ញុំត្រូវសួរសំណួរនេះឡើងវិញ ហើយខ្ញុំគឺថាខ្ញុំមានសិទ្ធិដើម្បីសួរសំណួរនេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើចៅក្រម ឡឺមុងដ៍ ធ្លាប់សុំលោកឲ្យប្រមូលតែភស្តុតាងដាក់បន្ទុក ដោយមិនរកភស្តុតាងដោះបន្ទុកដែរឬទេ? ហើយខ្ញុំគិតថា ដោយសារតែមានការជំទាស់ទៀត ប៉ុន្តែយ៉ាងណា

ខ្ញុំបញ្ជាក់ថា ការជំទាស់សំណើរបស់ខ្ញុំគឺមានមូលដ្ឋានត្រឹមត្រូវ។

**លោក ឃីត រេយ៍ន័រ៖**

គឺថាខ្ញុំសូមជំទាស់សាជាថ្មីម្ដងទៀត គឺការជំទាស់ដដែល មានមូលដ្ឋានដដែល។

[១០:០២:០៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ។ សាក្សីមិនបាច់ឆ្លើយតបទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោក ហេងឌ័រ ខ្ញុំសូមបន្តទៅមុខទៀត។ គឺវានៅពាក់ព័ន្ធនឹងដំណាក់កាល២០០៦ដដែល ប៉ុន្តែឥឡូវនេះ ខ្ញុំចង់ផ្ដោតទៅលើឯកសាររបស់លោកវិញ។ លោកបានផ្ដល់សក្ខីកម្មពីពេលមុនថា នៅឆ្នាំ ២០០៦ និងក្រោយបន្តមកទៀតហ្នឹង គឺលោកមាននូវឯកសារច្បាប់ដើម។ គឺឯកសារបក្សកុម្មុយនីស្ត កម្ពុជាច្បាប់ដើម ដូចជាទស្សនាវដ្ដីទង់បដិវត្ត ហើយប្រហែលជាសារទូរលេខ ឬក៏ឯកសារច្បាប់ដើម ដទៃៗ ទៀត។ តើលោកអាចប្រាប់យើងខ្ញុំដែរបានឬទេ នៅពេលដែលលោកចូលបម្រើការងារនៅក្នុង អង្គជំនុំជម្រះនៅឆ្នាំ២០០៦នោះ លោកបានប្រគល់នូវឯកសារច្បាប់ដើមទាំងអស់ជូនទៅអង្គជំនុំជម្រះ ជូនទៅសហចៅក្រមស៊ើបអង្កេតដែរឬទេ?

**លោក ស៊្មីរ ហេងឌ័រ៖**

**ឆ៖** គឺថាខ្ញុំប្រគល់ជូនទាំងអស់ ហើយខ្ញុំឲ្យទៅគេទាំងអស់តែម្ដង។ ខ្ញុំប្រគល់នូវឯកសារទាំង អស់ដែលខ្ញុំមាន។ ដូច្នេះ ដូចជាមិនមែនអ្វីដែលនៅសល់ទេ។

[១០:០៣:៤៧]

**ស៖** តើលោកផ្ដល់នូវឯកសារច្បាប់ដើម គឺឯកសារទស្សនាវដ្ដីទង់បដិវត្តច្បាប់ដើមប្រគល់ជូន ទាំងអស់ដែរឬទេ? តើលោកចាំថាលោកប្រគល់ឯកសារច្បាប់ដើមនេះជូនទៅសហចៅក្រមស៊ើបអង្កេត ដែរឬទេ?

**ឆ៖** បាទ ខ្ញុំបានប្រគល់។

**ស៖** តើលោកដឹងដែរឬទេ ថាតើឯកសារច្បាប់ដើម គឺទស្សនាវដ្ដីទង់បដិវត្តច្បាប់ដើមហ្នឹងនៅ កន្លែងណាឥឡូវនេះ? គឺថាឯកសារដែលលោកបានប្រគល់ជូនហ្នឹង ឥឡូវច្បាប់ដើមហ្នឹងនៅកន្លែងណា?

**ឆ៖** ខ្ញុំមិនមែនប្រគល់ទេ ខ្ញុំគ្រាន់តែស្នើសុំប្រគល់ ប៉ុន្តែគេបដិសេធមិនទទួលយក។ ប៉ុន្តែឥឡូវ

ហ្នឹងនៅខ្ញុំ។ ដូច្នេះឯកសារទាំងអស់នេះ ត្រូវបានស្នើដោយខ្ញុំ គឺខ្ញុំស្នើសុំប្រគល់ជូនទៅអង្គជំនុំជម្រះទៅសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែគេបដិសេធមិនទទួលយក។ ដូច្នេះខ្ញុំក៏យកទៅក្រុងឡុងដុងដ៍ ប៉ុន្តែនៅពេលដែលអង្គជំនុំជម្រះសាលាដំបូងស្នើសុំ ខ្ញុំក៏ប្រគល់ជូន។

[១០:០៤:៥៨]

**ស៖** ហេតុផលដែលខ្ញុំសួរលោកទាំងអស់នេះ គឺខ្ញុំមានមូលដ្ឋានដូចតទៅនេះ។ កូនក្តីរបស់ខ្ញុំគឺលោក នួន ជា គឺថាគាត់ចង់កាន់ដោយផ្ទាល់ដៃនូវឯកសារច្បាប់ដើមនៃទស្សនាវដ្តីទង់បដិវត្តនោះ។ ហើយលោកក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ជាអ្នកសិក្សាក្នុងរយៈពេលនោះបានលម្អិត តើលោកអាចប្រាប់យើងបានឬទេថា ទស្សនាវដ្តីទង់បដិវត្តច្បាប់ដើមនោះ ប្រសិនបើយើងដាក់នៅបង្ហាញនៅចំពោះមុខនៅពេលនេះ តើលោកអាចបង្ហាញពីភាពត្រឹមត្រូវ ឬក៏ភាព -- ដូច្នេះផ្អែកទៅតាមជំនាញរបស់លោកផ្អែកទៅតាម បទពិសោធន៍របស់លោក តើលោកអាចបង្ហាញអំពីយថាភាពនៃឯកសារទស្សនាវដ្តីទង់បដិវត្តហ្នឹងបាន ដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាល់ឆ្លើយតប!

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១០:០៦:២០]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំយល់ថាវាដូចជាមិនត្រឹមត្រូវនោះទេ ដែលថាឯកសារហ្នឹងគឺយើងបានបង្ហាញ ពីម្សិលមិញហើយ គឺឯកសារជាពណ៌ក្រហម ហើយខ្ញុំផ្តល់ជាលេខឯកសាររួចអស់ទៅហើយ។ ខ្ញុំមិនយល់ថាហេតុអ្វីបានជាមេធាវីការពារក្តីឥឡូវហ្នឹងមកសួរពីសំណួរទាំងអស់នេះ។ គឺថាទស្សនាវដ្តីទង់បដិវត្តពណ៌ក្រហម ទង់ក្រហមហ្នឹងគឺមាននៅក្នុងសំណុំរឿងរួចស្រេចទៅហើយ។ ខ្ញុំមិនយល់ថាហេតុអ្វីក៏លោក នួន ជា មិនអាចចូលទៅបាន គ្រាន់តែចុចទៅលើកុំព្យូទ័រ ចុចតែប៊ូតុងមួយទៅឃើញបាត់ទៅហើយ វាគ្មានអីពិបាកនោះទេ។

**លោក វ៉ិចទ័រ កូប៉េះ៖**

លោកប្រធានខ្ញុំគ្រាន់តែចង់ឲ្យសាក្សីគាត់យល់អំពីមូលដ្ឋាននៃការសួររបស់ខ្ញុំ។ មូលដ្ឋានដែលខ្ញុំសួរហ្នឹងគឺ ថាបែបនេះ។

[១០:០៧:០៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវខ្ញុំនិយាយនេះវិញ លោកសាក្សីតើលោកអាចពន្យល់បានដែរឬទេ តាមការស្រាវជ្រាវរបស់លោក ក៏ដូចជាការសរសេរអត្ថបទរបស់លោក គឺថាលោកបានឯកសារច្បាប់ដើមទាំងអស់នេះដោយរបៀបណា?

**លោក ស៊ីវ ហេងឆ័រ៖**

**ឆ៖** ខ្ញុំគិតថាខ្ញុំបានពន្យល់រួចទៅហើយ។ នៅពេលដែលខ្ញុំទៅដល់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង គឺនៅក្នុងចុងទសវត្សរ៍៨០ គឺនៅចុងឆ្នាំ៨០ ហើយមកមួយសាទៀតឆ្នាំ៨១ គឺ នៅពេលនោះពួកខាងបណ្ណសារគេបានបង្ហាញខ្ញុំនូវទស្សនាវដ្ដីទង់បដិវត្ត គឺទង់បដិវត្តច្បាប់ដើម ព្រមទាំងទស្សនាវដ្ដីយុវជន-យុវនារីបដិវត្ត ព្រមទាំងឯកសារច្បាប់ដើមរបស់បក្សកុម្មុយនីស្តកម្ពុជាដទៃទៀត។ ហើយនៅពេលនុ៎ងដោយសារតែមិនមានម៉ាស៊ីនហ្វូតូកូពី ដើម្បីអាចកូពីបាន។ ដូច្នេះពួកគាត់ ក៏សម្រេចចិត្តប្រគល់ឲ្យខ្ញុំនូវឯកសារច្បាប់ដើមទាំងអស់នេះ។ ហើយវាមានឯកសារច្បាប់ដើមដទៃទៀត គេរក្សាទុក។

[១០:០៨:២៦]

ដូច្នេះហើយទើបគេប្រគល់នូវឯកសារច្បាប់ដើមមកឲ្យខ្ញុំ ហើយនៅក្នុងឆ្នាំ៨១ និងនៅពេលក្រោយៗមកទៀត ខ្ញុំបានត្រឡប់ទៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងហ្នឹងខ្ញុំ ធ្វើការ ថតចម្លង គឺថាខ្ញុំធ្វើការថតចម្លងឯកសារនៅពេលដែលមានម៉ាស៊ីនហ្វូតូកូពីនៅទីនោះ។

ហេតុដូច្នេះ ហើយទើបខ្ញុំមានទស្សនាវដ្ដីទង់បដិវត្ត ទស្សនាវដ្ដីយុវជន យុវនារីបដិវត្ត ដែលគេបានរក្សាទុកនៅក្នុងបណ្ណសារនោះ។ ហើយខ្ញុំមានឯកសារខ្លះជាឯកសារហ្វូតូកូពី។ ហើយឯកសារថតចម្លងទស្សនាវដ្ដីទង់បដិវត្ត យុវជន យុវនារីបដិវត្តមួយចំនួន ខ្ញុំបានប្រគល់ជូនទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ដូច្នេះខ្ញុំមានទាំងច្បាប់ដើមទាំងច្បាប់ហ្វូតូកូពី។ ទាំងអស់នេះគឺជាឯកសារដែលខ្ញុំបានប្រគល់ជូនទៅ មជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ។ ហើយបន្ទាប់មកទៀត អង្គជំនុំជម្រះសាលាដំបូងបានស្នើសុំឲ្យខ្ញុំប្រគល់ ខ្ញុំក៏ប្រគល់ឯកសារទាំងអស់នោះជូនអង្គជំនុំជម្រះ។

ខ្ញុំគិតថា ខ្ញុំប្រហែលជាមិនភ្លេច មិនបាត់ឯកសារទាំងអស់នៅកន្លែងណាមួយទេ ខ្ញុំបានប្រគល់ប្រហែលជា៤៥, ៥០ ឯកសារជូនទៅទាំងអស់នោះ។ ដូច្នេះ អានេះគឺជាឯកសារនយោបាយរបស់

ខ្មែរក្រហម។ ដូច្នេះខ្ញុំគិតថាខ្ញុំអាចរកឯកសារទាំងអស់នោះបាន។

[១០:១០:០៩]

**ស៖** តើនៅពេលណាដែលលោកមានឯកសារហ្នឹងនៅក្នុងដៃរបស់លោក ឯកសារចុងក្រោយហ្នឹងនៅក្នុងដៃរបស់លោក? ឬក៏ចម្លើយសារភាពស-២១នៅក្នុងដៃរបស់លោក? ក៏ដូចជាចំណាររបស់លោក នួន ជា? ខ្ញុំចង់ដឹងថាតើលោកបានឯកសារហ្នឹងមកកាន់ក្នុងដៃហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំបាននាំយកឯកសារហ្នឹងមកប្រទេសកម្ពុជាវិញនៅក្នុងពាក់កណ្ដាលឆ្នាំ២០០៦ ហើយខ្ញុំចាំថាមានការសន្ទនាមួយនៅការិយាល័យសហព្រះរាជអាជ្ញា ហើយថាមានឯកសារហ្នឹងវាមាននៅកន្លែងផ្សេង។ ដូច្នេះគឺថាខ្ញុំអាចទៅស្វែងរកឯកសារហ្នឹងពីកន្លែងផ្សេង។ នៅពេលដែលខ្ញុំមកចូលការិយាល័យសហព្រះរាជអាជ្ញា ខ្ញុំផ្ដល់ឯកសារនេះជូនទៅគេ ប៉ុន្តែគេបដិសេធមិនទទួលយក។ នៅពេលដែលគេចាប់ផ្ដើមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនៅក្នុងពាក់កណ្ដាលឆ្នាំ២០០៧ ប្រហែលជាខែកក្កដា ឆ្នាំ២០០៧ នៅពេលដែលគេចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ខ្ញុំបានស្នើប្រគល់ឲ្យគេម្ដងហើយម្ដងទៀត ប៉ុន្តែពួកគេបដិសេធ។ ហេតុដូច្នេះហើយខ្ញុំយកឯកសារហ្នឹងត្រឡប់មកទីក្រុងឡុងដ៍ ប្រហែលជានៅក្នុងរដូវបុណ្យណូអែលឆ្នាំនោះ គឺនៅចុងឆ្នាំ២០០៧ ខ្ញុំបានវេចខ្ចប់ឯកសារដែលខ្ញុំយកមកភ្នំពេញ ហើយខ្ញុំយកទៅវិញទៅ។ គឺថាខ្ញុំយកត្រឡប់ទៅផ្ទះខ្ញុំនៅទីក្រុងឡុងដ៍ ហើយខ្ញុំទុកនៅក្នុងឯកសារខ្ញុំវិញ។

[១០:១២:០៣]

**ស៖** លោកក៏បានឆ្លើយផងដែរថា លោកបានធ្វើការសិក្សាស្រាវជ្រាវយ៉ាងលម្អិតទៅលើចម្លើយសារភាពនៅមន្ទីរស-២១។ ដូច្នេះខ្ញុំចង់សួរលោកថា ផ្អែកទៅលើមូលដ្ឋាននៃការសិក្សាស្រាវជ្រាវរបស់លោកនោះ ថាតើចម្លើយសារភាពដែលមានហត្ថលេខា ឬក៏មាន ហត្ថលេខាដែលគេថាជារបស់លោក នួន ជា ហ្នឹងតើវាមានលក្ខណៈបែបណាដែរ?

**ឆ៖** ខ្ញុំគិតថាអត់ទេ ចម្លើយរបស់ខ្ញុំគឺថាអត់ទេ។ គឺថាផ្អែកទៅលើចម្លើយដើមរបស់លោក គឺឯកសារហ្នឹង គឺខ្ញុំមានឯកសារហ្នឹងមានតិចតួចទេ គឺមានតិចតួចបំផុត ដែលជាឯកសារច្បាប់ដើមយកមកពីខាងស-២១។ ឯកសារទាំងអស់ហ្នឹងគឺគេទុកនៅក្នុងបណ្ណសារ ប៉ុន្តែមានប្រហែលជាប្រាំមួយ-ប្រាំពីរប៉ុណ្ណោះ ប៉ុន្តែគេឲ្យខ្ញុំឯកសារចម្លងតែមួយទេ។ ហើយឯកសារជាង៩៩ភាគរយទៀត គឺចម្លើយសារភាព៩៩ភាគរយជាងទៀត ដែលខ្ញុំមាននោះគឺជាឯកសារចម្លងតែប៉ុណ្ណោះ។ ដូច្នេះអាចថាខ្ញុំមិនដែលឃើញដោយផ្ទាល់ ឬមួយក៏ខ្ញុំមិនដឹងថាឯកសារច្បាប់ដើមនៅទីណានោះទេ។ ខ្ញុំឃើញថាវាមាន

តិចតួចបំផុត។

[១០:១៣:៣៧]

ខ្ញុំធ្លាប់ឃើញឯកសារច្បាប់ដើម ដែលគេទុកនៅបណ្ណសារនៅក្នុងសារមន្ទីរឧក្រិដ្ឋប្រល័យពូជសាសន៍ទួលស្លែង។ ខ្ញុំធ្លាប់ឃើញ ប៉ុន្តែអ្វីដែលខ្ញុំធ្លាប់ឃើញហ្នឹងគឺឯកសារដែលមិនមានចំណាររបស់លោក នួន ជា នោះទេ។ ប៉ុន្តែឯកសារដែលមានចំណារ គឺជាឯកសារកូពីនោះទេ។ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំធ្លាប់ឃើញឯកសារច្បាប់ដើម នៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង។

**ស៖** ដើម្បីឲ្យយល់ច្បាស់អំពីអ្វីដែលលោកចង់និយាយ ខ្ញុំចង់សួរលោកអ៊ីចេះ ថាមានចម្លើយប្រហែលជា១៥ទៅ២០មានហត្ថលេខា ដែលគេថាជារបស់លោក នួន ជា។ ប៉ុន្តែចំនួនពិតប្រាកដប៉ុន្មាននោះលោកអត់ដឹងទេ តើអ៊ីចឹងមែនទេ?

**ឆ៖** ខ្ញុំគិតម្តងទៀត ប្រសិនបើខ្ញុំចាំមិនខុសទេនៅក្នុងសំណុំរឿងមានឯកសារថតចម្លងពណ៌ធម្មជាតិ ហើយតាមដែលខ្ញុំចាំ គឺថាខ្ញុំបានស្កេនពណ៌ធម្មជាតិទៅលើឯកសារទាំងអស់នោះដោយផ្ទាល់ដៃ នៅពេលដែលខ្ញុំធ្វើការនៅការិយាល័យសហចៅក្រមស៊ើបអង្កេត។ ប៉ុន្តែខ្ញុំធ្វើឡើងនៅទីតាំងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជានោះទេ។ ហើយនៅពេលដែលខ្ញុំធ្វើការស្កេនពណ៌ធម្មជាតិនុ៎ង គឺឯកសារច្បាប់ដើមដែលខ្ញុំបានថតស្កេនយកមកនោះ គឺមាននៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា។ វាមិនប្រាកដថាពួកគេទុកនៅទីនោះទេ ឬក៏យ៉ាងណានោះទេ ខ្ញុំអត់ដឹងទេ គ្រាន់តែគេយកមកឲ្យខ្ញុំនៅបន្ទប់ថតចម្លង ហើយខ្ញុំស្កេនឯកសារនុ៎ង ហើយបន្ទាប់មកទៀត គេយកទៅទុកកន្លែងដើមវិញ។ ខ្ញុំមិនដឹងថា ឯកសារដើមហ្នឹងគេយកមកពីណានោះទេ។

[១០:១៥:៤៥]

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ? តើលោកធ្វើយ៉ាងណាអាចសម្រេចបានថា ចម្លើយសារភាពដែលមានហត្ថលេខាហ្នឹង គឺជាឯកសារច្បាប់ដើមដែលមានយថាភាពត្រឹមត្រូវ? តើលោកធ្វើយ៉ាងណាអាចដឹង?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

ខ្ញុំគិតថា ឥឡូវនេះគេកំពុងសួរទស្សនៈរបស់អ្នកជំនាញបាត់ទៅហើយ។

[១០:១៦:២០]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងសួរឡើងវិញ ខ្ញុំនឹងកែសំណួររបស់ខ្ញុំ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅពេលដែលលោកឃើញឯកសារគេប្រគល់ជូនលោកនោះ តើលោកមានសិក្សា ឬក៏មានវាយតម្លៃដើម្បីបង្ហាញពីយថាភាពនៃឯកសារនុ៎ងដែរឬទេ?

**លោក ស្ទីវ ហេឌឌ័រ៖**

**ឆ៖** អត់ទេ។

**ស៖** ខ្ញុំនឹងសួរសំណួរនេះ នៅពេលក្រោយបន្តទៀត ប៉ុន្តែឥឡូវនេះខ្ញុំសូមបន្តទៅប្រធានបទថ្មី។ មុននេះលោកបានផ្តល់ចម្លើយទៅដល់ព្រះរាជអាជ្ញាដែលថាលោកបានធ្វើការសម្ភាសជាមួយនឹង កែ ពក។ ប្រសិនបើខ្ញុំចាំមិនខុសទេ ឯកសារនៃការសម្ភាសនុ៎ង គឺថាអាចប្រគល់បាននៅពេលដែលលោក កែ ពក ស្លាប់។

[១០:១៧:៣៧]

ហេតុដូច្នេះហើយទើបលោកស្នើសុំប្រគល់ឯកសារហ្នឹង ទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ប៉ុន្តែគេបដិសេធមិនទទួលយក។ ហើយៗឥឡូវនេះគឺថា លោកនិយាយថា លោកទុកឯកសារហ្នឹងនៅក្នុងទូឯកសាររបស់លោកចំនួន៤៥ គឺទូមួយក្នុងចំណោមទូ៤៥ នៅទីក្រុងឡុងដ៍ឯណោះ។ ដូច្នេះ តើលោកចាំដែរឬទេថា តើគេប្រាប់អ្វីមកលោកនៅពេលដែលលោកស្នើសុំប្រគល់ឯកសារនេះជូនទៅគេ? គឺថាឯកសារចម្លើយរបស់ កែ ពក ហ្នឹងតើគេប្រាប់លោកថាយ៉ាងម៉េចនៅពេលដែលគេបដិសេធនោះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

ខ្ញុំគិតថា ឥឡូវនេះខ្ញុំមានការជំទាស់ពីរ។ ទី១ គឺថាគេកំពុងតែត្រឡប់ទៅសួរសំណួរអំពីថា តើ

ចៅក្រមនិយាយយ៉ាងម៉េច? ខាងព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតនិយាយយ៉ាងម៉េច? ដូច្នេះអានេះ គឺជាចំណុចមួយ។ ចំណុចទី២ ទី២គឺវាអត់មានភាពពាក់ព័ន្ធអីទាស់តែសោះ ដែលថាអ្នកណាម្នាក់និយាយ អ្នកណាម្នាក់ថាស្អីអំពីឯកសារ អំពីអ្វីផ្សេងៗ។ ទាំងអស់នេះគឺវាមិនបានជួយអ្វីសូម្បីតែបន្តិចដល់ការស្វែងរកការពិត។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាខ្ញុំគ្រាន់តែចង់រកឲ្យឃើញ ថាតើមានអ្វីកើតឡើងនៅពេលដែលមានសក្ខីកម្មរបស់លោក កែ ពក។ ដូច្នេះខ្ញុំគិតថា សាក្សីគាត់ធ្លាប់សម្ភាសជាមួយ កែ ពក ទោះបីថាខ្ញុំមិនមានកំណត់ត្រាប្រតិចារឹកក៏ដោយ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងថាតើមានអ្វីកើតឡើង ហើយខ្ញុំចង់រកឲ្យឃើញថា តើសាក្សីគាត់ថា ហេតុអ្វីបានជាគ្មានអ្នកណាម្នាក់ចាប់អារម្មណ៍ជាមួយនឹងសក្ខីកម្មរបស់លោក កែ ពក ទៅវិញ។

*(ចៅក្រមពិភាក្សាគ្នា)*

[១០:២០:៤៨]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារជូនទៅចៅក្រម ហ្សង់ម៉ាក ដើម្បីសម្រេចលើសេចក្តីជំទាស់ក្នុងការតាំងសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក នួន ជា ចំពោះសាក្សី។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍៖**

បាទសូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះចង់កត់សម្គាល់ថា កិច្ចសម្ភាសន៍របស់លោក កែ ពក គឺជាធាតុផ្សំភស្តុតាងដែលដាក់ជូនអង្គជំនុំជម្រះហើយ។ ហើយអង្គជំនុំជម្រះនឹងវាយតម្លៃជាភស្តុតាង ក៏ប៉ុន្តែអ្វីដែលចង់ដឹង គឺថាកិច្ចសម្ភាសន៍ហ្នឹងមិនត្រូវបានដាក់បញ្ចូលនៅពេលដំណាក់កាលកិច្ចស៊ើបសួរនោះទេ។ អ៊ីចឹងយើងឃើញថាមិនមានភាពពាក់ព័ន្ធទេ អ៊ីចឹងសូមឲ្យចូលទៅនិយាយប្រធានបទផ្សេងទៀតទៅ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនបានសួរអំពីទីតាំងអ្វីទេ ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំសួរសំណួរឲ្យបានលម្អិតបន្ថែមតទៅទៀត។

[១០:២១:៥៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ឥឡូវនេះ ខ្ញុំចង់និយាយយោងទៅលើគឺឯកសារ E190.1.398 ដែលមានលេខ ERN គឺ អត្ថបទរបស់លោកដែលនិយាយអំពីមន្ត្រីក្នុងស្រុក ហើយមានជើងទំព័រលេខ១៤ ដូចដែលព្រះរាជអាជ្ញា បានលើកឡើងរួចមកហើយ។ គឺលោកនិយាយអំពីកិច្ចសម្ភាសន៍មួយដែលលោកបានធ្វើជាមួយ កែ ពក។ ឥឡូវនេះខ្ញុំនិយាយអំពីជើងទំព័រមួយនេះ ហើយខ្ញុំសូមដកស្រង់ពីជើងទំព័រនេះដូចតទៅនេះ។

ការសម្ភាសនៅថ្ងៃទី២២ កុម្ភៈ ឆ្នាំ២០០១ នៅក្នុងសៀមរាប ពក បានយល់ស្របពិភាក្សាអំពី ភស្តុតាងប្រឆាំងខ្លួនគាត់ និងអ្នកដទៃ ដោយផ្អែកទៅលើលក្ខខណ្ឌថាមតិរបស់គាត់នឹងមិនត្រូវបង្ហាញ ជាសាធារណៈនៅពេលដែលគាត់នៅរស់ឡើយ។ គាត់បញ្ជាក់ថា "លេខារបស់បក្សកុម្មុយនីស្តកម្ពុជា ភូមិភាគឧត្តរ ក្រោយមកភូមិភាគមជ្ឈិម គឺថាគាត់បានអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្ត កម្ពុជាក្នុងការសម្លាប់មន្ត្រីខ្មែរ -- របបខ្មែរសាធារណរដ្ឋ ដោយចាប់ផ្តើមឡើងជាការចាប់ខ្លួន បន្ទាប់មក បញ្ជាឲ្យមានការសម្លាប់ដោយចោទប្រកាន់ថាជាជនក្បត់នៅក្នុងចំណោមសមាជិកបក្សកុម្មុយនីស្តកម្ពុជា។ ហើយធ្វើតាមបញ្ជាដែលទទួលបានពីលោក នួន ជា ដើម្បីជួយនៅក្នុងការចាប់ខ្លួនពួកជនក្បត់ដទៃទៀត នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា ហើយដែលគាត់ដឹងថានឹងត្រូវបានគេសម្លាប់បន្ទាប់ពីស៊ើបសួរដោយមន្ទីរ សន្តិសុខស-២១ នៅក្នុងទីក្រុងភ្នំពេញ"។

[១០:២៣:៥៤]

ហើយជើងទំព័រនៅក្នុងអត្ថបទរបស់លោកនេះ គឺបានបង្ហាញថាភស្តុតាងដែលលោកប្រើប្រាស់ តែមួយប៉ុណ្ណោះក្នុងការបង្ហាញពីទំនាក់ទំនងរវាងគោលនយោបាយក្នុងការសម្លាប់ ហើយនិងតួនាទីរបស់ នួន ជា។ ថាតើខ្ញុំនិយាយអំពីជើងទំព័រលេខ១៤ បែបនេះត្រឹមត្រូវដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត សេយ៍ន័រ៖**

ពាក្យចុងក្រោយ គឺនិយាយអំពីការសហការ ហើយខ្ញុំគិតថាសំណួរគួរតែលើកឡើងឲ្យបានត្រឹម ត្រូវស្របតាមបរិបទដើម្បីសួរទៅលើ ហេដឌ័រ។ ដូច្នេះខ្ញុំគិតថា នៅកថាខណ្ឌបន្ត គឺមាននិយាយអំពីការ សហការ។ ហើយខ្ញុំគិតថាការសហការហ្នឹង គឺមកពីទីណា ហើយកើតឡើងនៅពេលណា។ ដូច្នេះខ្ញុំគិត

ថា គួរតែសួរអំពីបញ្ហាទាំងអស់នេះផង។ ដូច្នេះវាជាការខុសឆ្គងទាំងស្រុង ដែលពេលដែលលើកឡើងសួរដល់សាក្សីដោយមិនមាននិយាយអំពីការសហការ។

[១០:២៥:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា ប្រហែលជាមានការនិយាយ -- ដូច្នេះចំណុចទី២ គឺខ្ញុំចង់ជម្រាបដល់អង្គជំនុំជម្រះផងដែរថា សហភាតារបស់ខ្ញុំក៏បានដកស្រង់យ៉ាងច្រើនអំពីឃ្លាយ៉ាងច្រើននៅក្នុងការសម្ភាសរបស់លោក ខៀវ សំផន។ ហើយគាត់ទុកមិនដកនូវឃ្លាចុងក្រោយបំផុត ដែលនិយាយឃ្លាចុងក្រោយទាក់ទងទៅនឹងលោក ហេង សំរិន។ ដូច្នេះខ្ញុំគិតថា ឥឡូវនេះដោយគេនិយាយថា ខ្ញុំមិនបានដកស្រង់ឲ្យបាន ពេញលេញនូវជើងទំព័រនោះគឺជាការមិនត្រឹមត្រូវ។ ដូច្នេះនេះគឺជាអត្ថបទដែលបានសរសេរនៅក្នុងសៀវភៅរបស់លោក ហើយខ្ញុំគិតថាអាចជួយដល់អង្គជំនុំជម្រះ ហើយខាងមេធាវីការពារក្តីគ្រាន់តែសួរសំណួរទាក់ទងទៅនឹងសក្ខីកម្មរបស់លោក កែ ពក ដែលសក្ខីកម្មរបស់លោក កែ ពក គឺបង្ហាញអំពីតួនាទី របស់លោក នួន ជា។

**ប្រធានអង្គជំនុំ៖**

បាទ សាក្សីអាចឆ្លើយតបទៅនឹងសំណួរដែលសួរនេះបញ្ចាក់នេះបាន។ ប៉ុន្តែអង្គជំនុំជម្រះសូមរំឭកដល់មេធាវីការពារក្តីលោក នួន ជា ព្រមទាំងភាគីពាក់ព័ន្ធដទៃទៀត អង្គជំនុំជម្រះបានជម្រាបរួចហើយនៅក្នុងកិច្ចពិភាក្សាដេញដោល មិនត្រូវបញ្ចេញឈ្មោះបណ្តាសាក្សីទាំងឡាយដែលអង្គជំនុំជម្រះបានកំណត់នូវរហស្សនាមរួចហើយនោះទេ។ លើកលែងតែសាក្សីទាំងឡាយណាដែលអង្គជំនុំជម្រះ មិនបានកំណត់នូវរហស្សនាម។ នេះជាការកំណត់ទូទៅនៅក្នុងការសួរដេញដោលពាក់ព័ន្ធជាមួយនឹងសាក្សីដែលមានរហស្សនាមត្រូវប្រើប្រាស់រហស្សនាម។

[១០:២៧:០០]

**លោក ស៊ីវ ហេងឌ័រ៖**

**ឆ៖** មេធាវីតើលោកអាចសួរសំណួរមួយសាទៀតបានដែរឬទេ?

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំគ្រាន់តែអាននូវសម្រង់ជើងទំព័រលេខ១៤ នៃអត្ថបទរបស់លោកតែប៉ុណ្ណោះ។ សំណួររបស់ខ្ញុំគឺចង់សួរលោកថា តើលោក កែ ពក គឺជាប្រភពព័ត៌មានតែមួយគាត់ដែលលោកបានដក

ស្រង់ ដែលផ្អែកទៅលើចម្លើយរបស់គាត់ ដែលថាមានទំនាក់ទំនងរវាងគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងការសម្លាប់មន្ត្រី និងទាហានរបប លន់ នល់ ហើយភ្ជាប់ទៅនឹងលោក នួន ជា។ តើនេះជាប្រភពព័ត៌មានតែមួយគត់របស់លោកមែនទេ?

**ឆ៖** ខ្ញុំគិតថាចម្លើយដែលខ្ញុំអាចឆ្លើយបានគឺថា អ្វីដែលបានគេនិយាយនៅក្នុងជើងទំព័រ១៤គឺ វាបានបង្ហាញរួចហើយនៅក្នុងជើងទំព័រទី១៤នេះ។ ដូច្នេះ វាមិនមែនមានន័យថាវាគ្មានភស្តុតាងខាងក្រៅដែលបង្ហាញនៅក្នុងជើងទំព័រនេះទេ។ ដូច្នេះវាអាចមានឯកសារដទៃទៀតដែលខ្ញុំមិនមាន ហើយវាពាក់ព័ន្ធទៅនឹងជើងទំព័រនេះ។

[១០:២៨:៣៦]

**សៈ** ដូច្នេះខ្ញុំអាចនឹងរីករាយក្នុងការអាននូវឃ្លាដែលពាក់ព័ន្ធទៅនឹងជើងទំព័រនេះផងដែរ។

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាននៅពេលដែលខ្ញុំលើកអំពីជើងទំព័រទៅសួរលោក ហេដឌ័រ គឺថាគាត់មានឯកសារពេញទាំងមូលនៅចំពោះមុខរបស់គាត់។ ដូច្នេះខ្ញុំសង្ឃឹមថាប្រហែលជាមេធាវីការពារក្តីអាចផ្តល់ឯកសារទាំងមូលទៅជូនលោក ហេដឌ័រ តែម្តងជាជាងការឲ្យគាត់គ្រាន់តែមើលទៅលើឯកសារនៅលើអេក្រង់។ ដូច្នេះ ខ្ញុំគិតថា គួរតែប្រគល់ឯកសារជាក្រដាសជូនទៅគាត់ដើម្បីឲ្យគាត់ងាយស្រួលក្នុងការតាមដានជាជាងគ្រាន់តែបង្ហាញនៅលើអេក្រង់។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរីករាយនឹងប្រគល់ជូន។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវីយកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១០:៣០:០៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** អ្វីដែលខ្ញុំអាចឆ្លើយបាន គឺថា ខ្ញុំគិតថាខ្ញុំប្រើប្រាស់នេះដោយមិនទូលំទូលាយ ប៉ុន្តែក្នុងលក្ខណៈជាការសិក្សាស្រាវជ្រាវវិញ គឺថាវាអាចផ្អែកទៅលើភស្តុតាងដែលខ្ញុំមាននៅពេលនោះ គឺជាភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ ហើយខ្ញុំអាចឈានទៅដល់ការសន្និដ្ឋាន ដែលខ្ញុំបានបញ្ជាក់នៅ

ក្នុងជើងទំព័រទី១៤នេះ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហេតុដូច្នេះខ្ញុំចង់សួរលោកថា តើលោកចាំដែរឬទេថា មានអ្វី ហេតុអ្វីបានមិនមានបញ្ហាអីកើតឡើងនៅពេលដែលលោកស្នើប្រគល់ឯកសារ?

**លោក វ៉ិចទ័រ កូប៉េ៖**

ប៉ុន្តែយ៉ាងណាក៏ដោយឥឡូវនេះខ្ញុំបន្តទៅមុខទៀតលោកប្រធាន។ ខ្ញុំគិតថា ឥឡូវនេះយើងខ្ញុំមើលទៅម៉ោងទៅ ហើយខ្ញុំគិតថាប្រហែលជាខ្ញុំត្រូវបន្តទៅមុខទៀតយូរ។ ដូច្នេះ តើលោកប្រធានសម្រេចយ៉ាងណាអំពីការបន្ត ព្រោះខ្ញុំត្រូវចូលដល់ប្រធានបទថ្មី?

[១០:៣១:០៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងដប់មួយខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣១ នាទី ដល់ម៉ោង ១០:៥២ នាទី)*

[១០:៥២:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរសាជាថ្មីលោក ហេដឌ័រ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** បាទ ពេលនេះ ខ្ញុំសូមចូលទៅប្រធានបទស្តីអំពីវិធីសាស្ត្រនៃការសរសេរអំពីការសិក្សាស្រាវជ្រាវរបស់លោកនិងសញ្ញាបត្ររបស់លោក។ ហើយទាក់ទងទៅនឹងចម្លើយដែលលោកបានឆ្លើយនៅថ្ងៃនេះ ក៏ដូចជាថ្ងៃមុន។ សក្ខីកម្មរបស់លោក គឺថាបានឆ្លើយច្បាស់ហើយ ដែលលោកបានធ្វើការសិក្សាស្រាវជ្រាវជាន់ខ្ពស់យ៉ាងទូលំទូលាយនៅក្នុងទសវត្សរ៍៨០។ ហើយលោកបានធ្វើការផ្តាច់ខ្លួនទៅធ្វើការជាមួយការិយាល័យសហព្រះរាជអាជ្ញាមួយរយៈ ចេញពីការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយពេលលោកចាកចេញទៅ លោកធ្វើការបោះពុម្ពផ្សាយទាក់ទងទៅនឹងនយោបាយនៅក្នុងប្រទេសកម្ពុជា ជួនកាលយោងទៅលើអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យ។

[១០:៥៣:៤២]

សំណួររបស់ខ្ញុំ ថាតើនៅពេលដែលលោកឆ្លើយទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា ហើយនៅពេលដែលគេសួរឱ្យលោកផ្តល់ភស្តុតាង ក៏ដូចជាប្រភពព័ត៌មាន តើលោកអាចញែកដាច់ពីគ្នាបានទេរវាងការដឹងឮ ដែលលោកបានប្រមូលនៅក្នុងពេលសិក្សាស្រាវជ្រាវរបស់លោក និងក្នុងពេលដែលលោកធ្វើការជាអ្នកស៊ើបអង្កេត តើលោកញែកឱ្យដាច់ពីគ្នាបានទេ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** និយាយរួម ខ្ញុំ បាទ ខ្ញុំព្យាយាមញែកវាឱ្យដាច់ពីគ្នា និយាយដោយសុទិដ្ឋិនិយមទៅ គឺថានៅដើមដំបូងនៃ*ខេស-មេប* ក៏ដូចជា*ហ្សាយឡេប*នេះ នៅក្នុងការគិតរបស់ខ្ញុំគឺថាខ្ញុំមិនច្បាស់លាស់នោះទេថាតើការដឹងអ្វីខ្លះដែលខ្ញុំបានដឹងនៅឯណា? ដឹងដោយរបៀបណា? លទ្ធផលយ៉ាងម៉េច? ប៉ុន្តែខ្ញុំព្យាយាមហើយខ្ញុំដឹងអំពីការញែកឱ្យដាច់ពីគ្នា ដែលខ្ញុំព្យាយាមញែកឱ្យដាច់ពីគ្នាតាមការដែលខ្ញុំចងចាំ និងតាមសមត្ថភាពរបស់ខ្ញុំទាក់ទងទៅនឹងការដឹងផ្សេងៗ។

**ស៖** ដូច្នេះ ចម្លើយដែលលោកបានឆ្លើយប៉ុន្មានថ្ងៃកន្លងមកនេះ គឺយោងទៅលើមូលដ្ឋាននៃការដឹងឮរបស់លោក ដែលលោកប្រមូលក្នុងពេលលោកធ្វើការបោះពុម្ពផ្សាយការសិក្សាស្រាវជ្រាវរបស់លោកច្រើនជាងអ្វីដែលលោកធ្វើការជាមួយការិយាល័យសហចៅក្រមស៊ើបអង្កេតឬយ៉ាងណា?

[១០:៥៥:៤៨]

**ឆ៖** បាទនេះគឺអ្វីដែលខ្ញុំកំពុងតែមានបំណងធ្វើនោះ។ ទាក់ទងទៅនឹងអំឡុងពេលដែលខ្មែរក្រហមស្ថិតនៅក្នុងអំណាច ប្រហែលជាវាមានសារប្រយោជន៍ក្នុងការញែកឲ្យដាច់ពីគ្នាយ៉ាងដូច្នេះ។ ជាក់ស្ដែងទៅ ខ្ញុំធ្វើកិច្ចការពាក់ព័ន្ធទៅនឹងខ្មែរក្រហមមុនពេលខ្មែរក្រហមស្ថិតនៅក្នុងអំណាចទៅទៀត គឺពី៧៣ ទៅ៧៥។ ហើយខ្ញុំបានបញ្ជាក់រួចមកហើយ គឺថាខ្ញុំព្យាយាមពិនិត្យមើលអង្គការចាត់តាំង រចនាសម្ព័ន្ធនយោបាយ គឺបញ្ហាទាក់ទងទៅនឹងឆ្នាំ៧០ ទៅនឹង ៧៥ -- ៧៣ ទៅនឹង ៧៥។ ខ្ញុំសិក្សាទាំងពីរនៅបណ្ណាល័យជាតិ ក៏ដូចជាការសម្ភាសមួយចំនួន។ ខ្ញុំតាមដានខ្មែរក្រហមពេលស្ថិតនៅក្នុងអំណាចតាមដែលខ្ញុំអាចធ្វើទៅបាន ដូចខ្ញុំបានលើកឡើងហើយ។

ហើយក្រោយមកទៀត ទាក់ទងទៅនឹងសុវត្ថិភាពរបស់ខ្ញុំមួយចំនួន ខ្ញុំអំឡុងពេលក្រោយខ្មែរក្រហមកាន់អំណាច ក៏ដូចក្នុងពេលកាន់អំណាច ដោយខ្ញុំផ្ដោតទៅលើការងាររបស់ខ្ញុំទាក់ទងទៅនឹងអំឡុងពេលដែលខ្មែរក្រហមស្ថិតក្នុងអំណាច ដែលខ្ញុំយល់ឃើញថាវាជាយុត្តាធិការរបស់អង្គជំនុំជម្រះនេះ។ គឺថាវាមានពេលវេលាក្រោយពីខែមករា ៧៩ ម្នាក់ៗយល់ឃើញថា អ្វីៗកើតឡើងនៅក្នុងពេលនោះ។ ដូច្នេះខ្ញុំព្យាយាម គឺថាញែកចំណុចហ្នឹងពីគ្នា។

[១០:៥៧:៥៥]

**ស៖** សំណួរមួយចុងក្រោយ តើលោកអាចញែកដាច់ពីគ្នាបានទេ រវាងការងារសិក្សាស្រាវជ្រាវរបស់លោក ហើយនិងការងារមុនការស៊ើបសួរ និងក្រោយការស៊ើបសួរ បំពេញជាអ្នកស៊ើបអង្កេតនេះជាពិសេសទាក់ទងទៅនឹងខ្មែរក្រហមពី៧៥ ទៅ៧៩ នេះ?

**ឆ៖** បើតាមខ្ញុំចាំ មានសំណេរមួយដែលនិយាយអំពីគោលនយោបាយខ្មែរក្រហម ចាប់តាំងពីខ្ញុំចាកចេញពីឈប់ធ្វើការនៅសាលាក្ដីនេះ នៅក្នុងខែមេសា ឬខែឧសភា ឆ្នាំ២០១១។ ដូច្នេះ មានសំណេរមួយទាក់ទងទៅនឹងគោលនយោបាយខ្មែរក្រហមមិនមែនជាការអនុវត្តជាក់ស្ដែងទេ ភាគច្រើនជាគោលនយោបាយ។ ឯកសារនេះ គឺយោងទៅលើឯកសារទងបដិវត្ត ទង់យុវជន យុវនារីបដិវត្ត យោងទាំងពីរឯកសារដើមក៏ដូចជាឯកសារថតចម្លង រួមទាំងសក្ខីកម្មចាប់តាំងពីពេលចាប់ផ្ដើមសាលាក្ដីនេះមកម្ល៉េះ។ ហើយក៏ដូចជាគម្រោងការងារដែលខ្ញុំរៀបចំឡើង ដែលក្រោយមក គឺថាវាឈានទៅដល់ការសង្ខេបនូវអត្ថបទសិក្សាស្រាវជ្រាវមួយដែលធ្វើការបោះពុម្ពផ្សាយតាំង -- ដោយពេលនោះនិយាយអំពីការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និងកម្មាភិបាលមូលដ្ឋាន។ ចំណុចសំខាន់បំផុត នៃចំហររបស់ខ្ញុំក្នុងនាមជាអ្នកសិក្សាស្រាវជ្រាវ ជានិស្សិតសិក្សាស្រាវជ្រាវ គឺខ្ញុំសិក្សាអំពី ហួឡូខូស គឺនៅសារមន្ទីរសហ

រដ្ឋអាមេរិកដែលស្តីអំពី ហ្វូឡូខូស ការសម្លាប់រង្គាលនេះ។

[១១:០០:០៨]

ប្រហែលជានៅចុងឆ្នាំ២០០១ ឬក៏២០០២ ក្រោយពីព្រឹត្តិការណ៍ថ្ងៃ០៩ វិច្ឆិកា នៅសហរដ្ឋអាមេរិកនោះ។ ដូច្នេះ ខ្ញុំផ្តើមទៅលើអំពីគំនិតផ្តួចផ្តើមនៅថ្នាក់មូលដ្ឋាន អំណាចនៅថ្នាក់មូលដ្ឋាន និងទស្សនៈជារួមដោយផ្តោតទៅលើការសិក្សាអំពីការសម្លាប់រង្គាលក្នុងការសិក្សាទៅលើ ហ្វូឡូខូស ឬការសម្លាប់រង្គាលនោះ។ ដោយខ្ញុំយល់ឃើញថា ដោយខ្ញុំគិតឃើញថា មានន័យថាអ្នកណាម្នាក់ដែលដាក់ខ្លួនស្ថិតនៅក្នុងអំណាចណាមួយ ឬគឺអ្នកណាម្នាក់ដែលបដិសេធចំពោះការសម្លាប់រង្គាល។ ដើម្បីស្វែងរកឲ្យឃើញថាមធ្យោបាយនេះ ដែលខ្ញុំព្យាយាមយល់អំពីរបបខ្មែរក្រហម គឺយោងទៅលើការងារមុនៗរបស់ខ្ញុំ។ វាស្របគ្នាយ៉ាងហោចណាស់ទៅនឹងផ្នែកមួយ នៃការសិក្សាស្រាវជ្រាវអំពីការសម្លាប់រង្គាលដោយមានការផ្តួចផ្តើមអំពីមន្ត្រីថ្នាក់មូលដ្ឋាន អំណាចមូលដ្ឋាន ការបែកបាក់គ្នាថ្នាក់មូលដ្ឋាន ដែលជា -- ថាជាគំរូនៃការគ្រប់គ្រងបែបផ្តាច់ការ ដែលការសិក្សាស្រាវជ្រាវជាន់ខ្ពស់របស់ខ្ញុំ ដើម្បីទទួលបានថាតើរបបនេះ ប្រតិបត្តិការទៅដោយរបៀបណានោះ។

[១១:០២:០៦]

**ស៖** អ៊ីចឹងតាមចម្លើយរបស់លោកនេះ ថាជំហរនៃការសិក្សាស្រាវជ្រាវរបស់លោក គឺដើម្បីវាយតម្លៃឡើងវិញ ទៅលើការទទួលខុសត្រូវ។ ខ្ញុំសូមសួរឲ្យបានទូលំទូលាយជាទូទៅ អំពីការស៊ើបអង្កេតកិច្ចការក្រោយការស៊ើបអង្កេត និងការបោះពុម្ពផ្សាយការសិក្សាស្រាវជ្រាវជាន់ខ្ពស់របស់លោក។ តើវាមានអ្វីពាក់ព័ន្ធទៅនឹងកិច្ចការមុនការស៊ើបអង្កេត និងកិច្ចការក្រោយការស៊ើបអង្កេតរបស់លោកនោះ?

**ឆ៖** បាទខ្ញុំសូមឆ្លើយ ខ្ញុំគិតថាវាជាករណីមួយដែលវាជាទស្សនៈដោយសំអាងទៅលើអង្គហេតុព្រឹត្តិការណ៍ជាក់ស្តែង។ មុននឹងខ្ញុំឈានចូលទៅសិក្សាអំពីការសម្លាប់រង្គាល ក៏ដូចពេលដែលខ្ញុំធ្វើការនៅផ្នែកខាងសិក្សាស្រាវជ្រាវការសម្លាប់រង្គាលនេះ។ ដូចដែលខ្ញុំបានលើកឡើងហើយ វាជាគំនិតមួយដ៏ទូលំទូលាយ ដែលខ្ញុំចង់បានអំពីការសម្លាប់រង្គាលនេះ។ ទស្សនៈនេះអាចថាជាសាក្សីក៏បាន ជាអ្នកជំនាញក៏បាន ផ្នែកហ្នឹង។

[១១:០៣:៥៥]

គឺថាមិនមានអ្វីផ្លាស់ប្តូរជាដុំកំភួនទេទាក់ទងទៅនឹងឯកសារភស្តុតាង សក្ខីកម្មមុនការស៊ើបអង្កេតសក្ខីកម្មក្រោយការស៊ើបអង្កេត ក៏ដូចជាទំនាក់ទំនងរបស់ ក៏ដូចជានៅក្នុងអំឡុងពេលដែលខ្ញុំទទួលបាន

កិច្ចសន្យាដើម្បីជួយដល់អង្គជំនុំជម្រះនេះ។ នេះគឺជាចំណុចតាំងពីមុនបង្កើតតុលាការនេះមកម្ល៉េះ គឺថាមិនមានអ្វី មានការផ្លាស់ប្ដូរដោយសារតែខ្ញុំធ្វើការកុងស៊ុលតង់ពេញម៉ោង ឬមិនពេញម៉ោង។ គឺទោះបីជាក្នុងរូបភាពកិច្ចសន្យាក៏ដោយ គឺមិនមានការផ្លាស់ប្ដូរគំនិតរបស់ខ្ញុំ ឬក៏ការសិក្សាស្រាវជ្រាវនៅតាមមូលដ្ឋាននៅក្នុងឆ្នាំ២០១១ ក្រោយពីខ្ញុំចាកចេញពីតុលាការនេះទៅ។ ប៉ុន្តែមុននឹងខ្ញុំសម្រេចនេះ ខ្ញុំបានសម្រេចហើយថាខ្ញុំត្រូវតែសិក្សាស្រាវជ្រាវអំពីរបបខ្មែរក្រហម។

**ស៖** ដូច្នេះ ដើម្បីសង្ខេបនូវចម្លើយរបស់លោក ហើយក៏ជាសំណួរចុងក្រោយផ្នែកនេះផងដែរ បញ្ហាដែលលោកសរសេរអំពីបុគ្គលទាំងប្រាំពីររូបប្រឈមមុខទៅនឹងការចោទប្រកាន់ ហើយនិងប្រភពដែលកំពុងតែស៊ើបអង្កេតនៅឡើយនូវអ្វីកើតក្នុងអំឡុងខ្មែរក្រហម ៧៥ ទៅ ៧៩ ដែលនិយាយអំពីតួ -- ដែលលោកនិយាយភាគច្រើន គឺថាតួនាទីរបស់ជនជាប់ចោទទាំងពីររូបនេះ អ៊ីចឹងទេ?

[១១:០៥:៣៣]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានខ្ញុំសូមជំទាស់ ខ្ញុំគួរតែធ្វើការជំទាស់លើសំណួរមុនៗដែរ ក៏ប៉ុន្តែគឺថាសួរទៅមនុស្សម្នាក់ ថាតើការគិតឃើញរបស់គាត់ប្រែប្រួល ឬក៏មតិយោបល់របស់គាត់ប្រែប្រួលយ៉ាងម៉េច? ការវិភាគរបស់ខ្លួននោះប្រែប្រួលយ៉ាងម៉េច? គឺជាការចោទសំណួរទៅអ្នកជំនាញទេ មិនអាចសួរទៅសាក្សីទេ។ សហភាតារបស់ខ្ញុំម្ខាង ហើយខាងការពារក្ដីនេះថាប្រាប់ថា ឲ្យពួកយើងខាងនេះ ប្រយ័ត្នកុំឲ្យសំណួរណាដែលខុសពីក្របខ័ណ្ឌនៃការសួរទៅសាក្សី។ អ៊ីចឹងឥឡូវសំណួរនេះសួរថា ឥឡូវគំនិតយោបល់របស់លោកប្រែប្រួលយ៉ាងម៉េចច្រើនឆ្នាំកន្លងទៅនេះ មិនសមស្របទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយតបសំណួរនេះមិនមែនគំនិតយោបល់ទេ និយាយអំពីការវិវត្តន៍នៃគំនិតរបស់គាត់ទាក់ទងទៅនឹងការបោះពុម្ពផ្សាយនូវការសិក្សាស្រាវជ្រាវរបស់គាត់នៅពីមុន និងក្រោយមកទៀត។ យើងខ្ញុំបានសួរអំពីការបោះពុម្ពផ្សាយពីការសិក្សាស្រាវជ្រាវរបស់លោក ហេដឌ័រ ដែលត្រូវសួរសំណួរជាក់លាក់នេះ។ ខ្ញុំមិនសួរឲ្យគាត់ផ្ដល់ជាមតិយោបល់អីទេនិយាយអំពីការវិវត្តន៍នៅក្នុងខ្លួនគាត់

តែម្តង ទាក់ទងទៅនឹងអំឡុងនៃកម្ពុជាប្រជាធិបតេយ្យតែម្តង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:០៨:៤៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសម្អាងហេតុនៃសេចក្តីជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីចំពោះរបៀបតាំងសំណួររបស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះសាក្សី ស្ទីវ ហេដឌ័រ អម្បាញ់មិញនេះ គឺមានមូលហេតុ និងសំអាងហេតុសមស្របពីព្រោះលោក ស្ទីវ ហេដឌ័រ នៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ គឺក្នុងឋានៈជាសាក្សី។ ហេតុដូច្នេះការសួរតាំងសំណួរដេញដោលរបៀបដែលជាចំពោះអ្នកជំនាញ គឺមិនសមស្របទេ។ ដូច្នេះសូមឲ្យមេធាវីការពារក្តីរៀបចំនូវសំណួរសាជាថ្មីឲ្យបានសមស្រប ហើយសំណួរអម្បាញ់មិញនេះសាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំកំពុងតែគិតថាតើត្រូវរៀបសំណួរឡើងវិញដោយរបៀបណានេះ ប្រហែលត្រូវរៀបឲ្យស្រួល។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេដឌ័រ តើទស្សនៈរបស់លោកដែលលោកយកមកសរសេរនៅក្នុងសៀវភៅស្តីអំពីបុគ្គលទាំងប្រាំពីររូបត្រូវប្រឈមមុខនឹងការចោទប្រកាន់ គំនិតយោបល់មកដល់ថ្ងៃហ្នឹងនៅដដែលទេឬ?

[១១:១០:១១]

**លោក ឃីត វេយ៉ន័រ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

ខ្ញុំឮសួរពាក្យថា "*វ្យូ*" គឺទស្សនៈ គឺស្នើសុំឲ្យផ្តល់ជាមតិយោបល់ហើយ វាអាចសួរតាមមធ្យោបាយមួយផ្សេង ប៉ុន្តែខ្ញុំមិនប្រាប់គាត់ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណតំណាងសហព្រះរាជអាជ្ញា។

[១១:១០:៤៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ចំណុចដែលលោកសរសេរនៅក្នុងសៀវភៅរបស់លោកថា បុគ្គលទាំងប្រាំពីររូបដែលត្រូវប្រឈមមុខនឹងការចោទប្រកាន់ តើវានៅតែឆ្លុះបញ្ចាំងការចេះដឹងរបស់លោក ការដឹងឮរបស់លោកក្នុងឋានៈជាអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់រហូតមកដល់សព្វថ្ងៃហ្នឹងឬយ៉ាងម៉េច?

**លោក ស្ទីវ ហេឌឆ័រ៖**

**ឆ៖** និយាយឲ្យបានទូលំទូលាយ បាទត្រឹមត្រូវ។ អ្វីដែលលើកយកមកសរសេរនៅក្នុងសៀវភៅស្តីអំពីបុគ្គលទាំងប្រាំពីររូបហ្នឹង គឺវាយោងទៅលើការវាយតម្លៃឡើងវិញដើម្បីឆ្លុះបញ្ចាំងទៅនឹងកិច្ចសម្ភាសន៍របស់ខ្ញុំ ជាបុគ្គលតាំងពីលើកដំបូង ការដឹងឮក្នុងលក្ខណៈជាបុគ្គលតាំងពីលើកដំបូង។ ប៉ុន្តែវាគ្រាន់តែជាផ្នែកមួយនៃរូបភាពហ្នឹង ឬក៏ជាផ្នែកមួយនៃការសិក្សាស្រាវជ្រាវ។ ដូច្នេះខ្ញុំអាចថាសៀវភៅស្តីពីបុគ្គលទាំងប្រាំពីររូបមិនពេញលេញទៅលើ -- មិនពេញលេញទេដែលនាំឲ្យមានការធ្វើការវាយតម្លៃឡើងវិញ។

[១១:១២:០៤]

បើសិនណាខ្ញុំព្រាងឯកសារវិញ ចែកចាយឡើងវិញ ឬក៏បោះពុម្ពផ្សាយឡើងវិញ ប្រហែលជាត្រូវមានការផ្លាស់ប្តូរ ឬក៏កែប្រែមួយចំនួន។ ប៉ុន្តែប្រហែលជាថ្ងៃណាមួយ នៅពេលដែលបញ្ហានេះវាចប់សព្វគ្រប់ ហើយបើសិនជាមានលទ្ធភាពក្នុងការវាយតម្លៃទៅលើស្ថានភាពឡើងវិញ ដោយយោងទៅលើទិន្នន័យ ឯកសារ ព័ត៌មាន បាទគឺថាខ្ញុំនឹងធ្វើការកែប្រែ។

**ស៖** លោក ហេឌឆ័រ ខ្ញុំដោយសារតែពេលវេលាខ្ញុំសូមបន្តទៅមុខទៀត។ នេះទាក់ទងទៅនឹងវិធីសាស្ត្រដែលលោកបានប្រើប្រាស់នៅក្នុងការបោះពុម្ពផ្សាយការសិក្សាស្រាវជ្រាវរបស់លោក ក៏ដូចជាសៀវភៅនានា ដែលយើងបានសួរសំណួរទៅលោកជាច្រើនមកហើយ។

ទាក់ទងទៅនឹងការប្រើប្រាស់វិធីសាស្ត្រនេះ អនុញ្ញាតឲ្យខ្ញុំដកស្រង់មតិយោបល់របស់លោកមួយចំនួនដែលទាក់ទងទៅនឹងវិធីសាស្ត្រដែលលោក -- ទាក់ទងទៅនឹងវិធីសាស្ត្រដែល ប៊ែន ឃៀរនិន បានប្រើប្រាស់ក្នុងសៀវភៅរបស់គាត់ស្តីអំពី ប៉ុល ពត។ ដើម្បីកំណត់ការជ្រើសរើសមួយចំនួនឲ្យបានឆាប់រហ័សខ្ញុំបានយកមកសរសេរ ដែលថា ប៊ែន ឃៀរនិន ជួនកាលប្រើភស្តុតាងមិនត្រឹមត្រូវ ភស្តុតាងក្លែងក្លាយ ឬក៏ជ្រើសរើសឯកសារ ឬក៏ធ្វើសេចក្តីសន្និដ្ឋាន ជួនកាលមានការឲ្យយល់ច្រឡំខុស ហើយជួន

កាលប្រើពាក្យ "*ស្តេរីអូថាយស៍*" មានន័យថាការយល់ឃើញត្រូវតែមួយជ្រុងណានោះ។ ដូច្នេះដើម្បីឲ្យខ្ញុំសង្ខេបទៅបានល្អ ទាក់ទងទៅនឹងភស្តុតាងមិនត្រឹមត្រូវគឺ ERN 77753 *(ស៊ីក)* ជាគឺ ERN 773744 ដោយយោងទៅលើសេចក្តីសន្និដ្ឋានគឺ 77724 ឬ 7724 *(ស៊ីក)* គឺ ERN 77376, 732 *(ស៊ីក)* គឺថាក្នុង ERN 773736, ERN គឺ--

[១១:១៤:៤៩]

**អ្នកបកប្រែ៖**

លោកប្រធានសូមការអនុញ្ញាត ERN គាត់អានញាប់ពេកលោកប្រធាន។ សូមឲ្យគាត់បញ្ជាក់ ERN ឡើងវិញ។

**ប្រធានអង្គជំនុំ៖**

លោក រ៉ិចទ័រ កូប៉េ អានឯកសារញាប់ពេក អ្នកបកប្រែភាសាលោកមិនទាន់ទេ។ សូមលោកបញ្ជាក់ជាថ្មីម្តងទៀត។

**លោក រ៉ិចទ័រ កូប៉េ៖**

បាទ សូមសួរលោកប្រធាន ឲ្យផ្តល់ ERN ទាំងអស់សាជាថ្មីឡើងវិញ ឬយ៉ាងណា?

[១១:១៥:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ បញ្ហាពីរ។ ទី១ គឺសូមលោកបញ្ជាក់អំពីលេខ ERN សាឡើងវិញ ព្រោះអម្បាញ់មិញនេះបកប្រែភាសាមិនទាន់ទេ។ ទី២ សូមលោកថា ឯកសារដែលលោកលើកមកមានបំណងសួរដេញដោលសាក្សីនាពេលនេះ ថាតើដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ?

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ការជំទាស់របស់ខ្ញុំនេះ គឺវាមានការពាក់ព័ន្ធ។ ថាតើវាពាក់ព័ន្ធដោយរបៀបណាដែលនាំឲ្យលោកទទួលបានយោបល់របស់លោកទៅលើវិធីសាស្ត្ររបស់លោក ប៊ែន ឃៀរនិន ទៅប្រើប្រាស់នៅក្នុងសៀវភៅរបស់គាត់នេះ មិនពាក់ព័ន្ធទាល់តែសោះ។ ទី១ សំណួរបែបនេះ គឺមិនមានការពាក់ព័ន្ធទេ។ មធ្យោបាយដែលសួរទៅលោក ហេដឌ័រ អំពីវិធីសាស្ត្ររបស់គាត់ ដូចខ្ញុំបានលើកឡើងវែងឆ្ងាយមកហើយ។ ដូច្នេះ ខ្ញុំមិនលើកឡើងដដែលៗទៀតទេ។ លោកមិនត្រូវសួរយោបល់របស់លោក

ហេដឌ័រ ទៅលើវិធីសាស្ត្ររបស់ ប៉ែន យៀរនិន ដែល ប៉ែន យៀរនិន ប្រើប្រាស់នោះទេ។ ហេតុដូច្នេះ ខ្ញុំសូមជំទាស់។

[១១:១៦:៤៩]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំព្យាយាមសន្សំសំចៃពេលវេលា។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំគាំទ្រការជំទាស់របស់សហព្រះរាជអាជ្ញា នេះជាចំណុចទី១។ ចំណុចទី២ គឺជាការកត់សម្គាល់ទាក់ទងទៅនឹងរបៀបដកស្រង់ឯកសារដែលលោកមេធាវីចង់ប្រើ។ យើងមិនដែលដឹងថាឯកសារហ្នឹងបានដាក់ចំពោះមុខតុលាការឬក៏អត់ ឬនៅ? ប្រភពជាដើម យោងជាដើម។ បន្ទាប់មកទៀតទាក់ទងនឹងលេខ ERN នេះ យើងតែងតែផ្តល់លេខ ERN ទាំងបីភាសា ក៏ប៉ុន្តែមេធាវីលោក នួន ជា យល់ឃើញថា ខ្លួនមិនចាំបាច់ធ្វើទេ ធ្វើដូច្នេះនោះ។ អ៊ីចឹងសូមឲ្យគាត់គោរពវិធាននេះផង ទាំងអស់គ្នាដើម្បីសម្រួលដល់ការងារយើងទាំងអស់គ្នា។

[១១:១៧:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

មានចំណុចអីដែលត្រូវសន្សំសំចៃពេលវេលា។ ខ្ញុំសូមសួរឃើត១ដោយយោងទៅលើ E313 -- E131/1/13.3។ ខ្ញុំសូមផ្តល់ ERN ជាភាសាអង់គ្លេស ក៏ជាភាសាបារាំង ក៏ដូចជាភាសាខ្មែរដែរ។ លោក ប៉ែន យៀរនិន ជួនកាលប្រើប្រាស់ព័ត៌មានមិនពិត -- គឺERN 773753, បារាំង 00802850, ខ្មែរ 00844591។ ការជ្រើសរើសប្រើប្រាស់ឯកសារគឺ ERN 773744, បារាំង 00802821, ខ្មែរ 00844511 ដល់12។ ERN ទៅលើសេចក្តីសន្និដ្ឋានគឺ 77724, បារាំង 00802811, ខ្មែរ 00844572 ដល់73។ “*មីសលីតឌីង*” – ការធ្វើឲ្យយល់ខុស – គឺថា 773753, បារាំង 00802812, ខ្មែរ 008444574 *(ស៊ីក)*, បារាំង 008280816 *(ស៊ីក)* ដល់17, ខ្មែរ 00844583 ដល់ 84។ សេចក្តីសន្និដ្ឋាន, ERN អង់គ្លេស 0077374 *(ស៊ីក)* បារាំង 00822830 ដល់ 31, ខ្មែរ 00844609 ដល់ 610។ ហើយពាក់ព័ន្ធទៅនឹង “*ស្តេរីអូថាយស៍*” គឺនៅត្រង់ទំព័រដដែលនេះឯង។ បញ្ហាដែលខ្ញុំថា វាមាន

ការពាក់ព័ន្ធគ្នានេះ ពាក់ព័ន្ធទៅនឹងសេចក្តីផ្តើមនៃវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដោយសាក្សីរូបនេះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

[១១:២១:២១]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ខ្ញុំគ្រាន់តែចង់សូមកត់សម្គាល់ថា លេខយោងនោះ គាត់និយាយលឿនពេក ហើយអ្នកបកប្រែចេញជាភាសាបារាំងនោះ មិនបានបកបានទាំងអស់នោះទេ។ ខ្ញុំមិនសូមឲ្យគាត់និយាយម្តងទៀតទេ ក៏ប៉ុន្តែពេលក្រោយៗទៀត សូមឲ្យគាត់ធ្វើយ៉ាងណាឲ្យភាគីទាំងអស់ហ្នឹងយល់អំពីអ្វីដែលគាត់ចង់និយាយផង។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ ល្អណាស់ ហើយការកត់សម្គាល់នេះសមស្របហើយ សូមលោកមេធាវីបញ្ជាក់នូវលេខឯកសារ និងលេខ ERN ឲ្យច្បាស់ ហើយយឺតៗដើម្បីឲ្យអ្នកបកប្រែភាសាបកបានទាំងបីភាសាដែលប្រើប្រាស់នៅក្នុងតុលាការនេះ។ ជៀសវាងមានបញ្ហាដដែលៗកើតឡើងម្តងហើយម្តងទៀត ឃើញថាលោកមានបំណងប្រើប្រាស់ពេលវេលាឲ្យមានប្រសិទ្ធភាពហើយ ប៉ុន្តែបើប្រើប្រព្រឹត្តទៅវិធីនេះ គឺប្រហែលជាខាតបង់ពេលវេលាទៅវិញទេ។ ការប្រើប្រាស់ពេលវេលាអាចមិនមានន័យថា ប្រសិទ្ធភាពទេ ខ្ជះខ្ជាយទៅវិញទេ។

[១១:២២:២៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំសង្ឃឹមថា សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងរកឃើញនូវសេចក្តីសន្និដ្ឋាន ក៏ដូចជាការកត់សម្គាល់របស់លោក ហេដឌ័រ នេះបាន។ ដោយសារគាត់បានទទួលស្គាល់ដោយខ្លួនគាត់ហើយ។ ខ្ញុំសូមទុក ERN ចោលមួយអន្លើសិនដោយសារខ្ញុំគ្មានពេលវេលា ខ្ញុំសូមចូលទៅលើវិធីសាស្ត្រដែលលោក ហេដឌ័រ ប្រើប្រាស់តែម្តង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តាមដែលខ្ញុំយល់សក្ខីកម្មរបស់លោកនោះ នៅពេលដែលលោកសរសេរ បោះពុម្ពផ្សាយការសិក្សាស្រាវជ្រាវរបស់លោក និងកិច្ចសម្ភាសន៍ទៅលើកម្មាភិបាលខ្មែរក្រហម អតីតកម្មាភិបាលខ្មែរក្រហម លោកបានអានឯកសារខ្មែរ ដូចជាទង់បដិវត្ត លោកបានប្រើប្រាស់ព័ត៌មានសម្ងាត់សហរដ្ឋអាមេរិក អត្ថបទសារព័ត៌មានជាដើម។ល។ ក៏ដូចជាការបោះពុម្ពផ្សាយផ្សេងៗទៀត ការបោះពុម្ពផ្សាយរបស់ប្រវត្តិវិទូដទៃៗទៀត និងលោកប្រើប្រាស់ចម្លើយសារភាពរបស់កម្មាភិបាលដែលត្រូវបានសួរចម្លើយនៅស-២១។

[១១:២៣:៤៥]

ខ្ញុំសូមចាប់ផ្ដើមតាំងសំណួររបស់ខ្ញុំទៅលើកិច្ចសម្ភាសន៍ដែលបានផ្ដល់មកឲ្យលោក គឺកិច្ចសម្ភាសន៍ដោយកម្មាភិបាល ឬក៏អតីតមេដឹកនាំខ្មែរក្រហម ដើម្បីកម្រិតសំណួររបស់ខ្ញុំទៅលើកិច្ចសម្ភាសន៍មួយដែលលោកសម្ភាស អៀង សារី។ តំណាងសហព្រះរាជអាជ្ញាបានសួរសំណួរជាច្រើន ទាក់ទងទៅនឹងកិច្ចសម្ភាសន៍នេះ។ លោកតែងតែបញ្ជាក់ថា នេះគឺអ្វីដែលលោក អៀង សារី បានប្រាប់ទៅលោក។ សំណួររបស់ខ្ញុំសួរទៅកាន់លោក បើលោកចាំបាននោះ គឺអ្វីដែលលោកបានរៀបចំក្នុងកិច្ចសម្ភាសន៍នេះ ដើម្បីធានាថាចម្លើយដែលផ្ដល់ពីប្រភពនានាមកឲ្យលោកនេះ គឺថាមិនត្រូវមានការលាក់លៀម ឬក៏មានការត្រួតគ្នា។ ឧទាហរណ៍ថា ទាក់ទងទៅនឹងលោក អៀង សារី គឺអំឡុងពេល -- ពេលដែលគាត់ចូលខ្លួនមកជាមួយរដ្ឋាភិបាលរួចហើយ។ តើលោកធ្វើយ៉ាងម៉េចដើម្បីធានាឲ្យច្បាស់ថា គឺគាត់មិនត្រូវបានផ្ដល់ចម្លើយរបស់លោកហ្នឹង គឺក្នុងលក្ខណៈណាត្រួតគ្នា?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** តើសំណួរនេះ គឺថា--

[១១:២៥:២៩]

**ស៖** សំណួររបស់ខ្ញុំគឺសួរទៅលើគាត់?

**ឆ៖** ប្រសិនណាជាគាត់មាន វាជាសិទ្ធិរបស់គាត់ត្រូវ ថាតើមានរបៀបវារៈបែបណាមួយ ដែលគាត់ត្រូវឆ្លើយជាមួយខ្ញុំ។ គឺខ្ញុំស្មានទេ ថាតើអ្វីដែលវាស្ថិតនៅក្នុង -- មាននៅក្នុងខួរក្បាលរបស់គាត់។ ចំណុចនេះទាក់ទងទៅនឹងសំណួរមុនៗរបស់លោក។ ប៉ែន ឃៀរនិន នៅក្នុងចំណោមអ្នកដទៃទៀតបញ្ជាក់ថា អៀង សារី គឺជាបងទី២។ ប៉ុន្តែខ្ញុំតាមការសិក្សាស្រាវជ្រាវថា មិនត្រឹមត្រូវទេដែលថាគាត់

ជាបងទី២ គឺអ្នកដែលល្បីឈ្មោះនៅក្នុងជួរបក្ស ហើយលេខ២ គឺកូនក្តីរបស់លោកហ្នឹងហើយ។ អ៊ីចឹងទាក់ទងទៅនឹងការបញ្ជាក់អះអាង មេដឹកនាំ ឬក៏ការផ្តាច់ខ្លួនពីរដ្ឋាភិបាល ឬក៏ថារដ្ឋាភិបាលចម្រុះនោះគឺអាស្រ័យទៅដោយការអះអាងរបស់ ប៉ែន យៀវនិន គឺពេលនោះបងធំទី២ លេចខ្លួនមក។ គាត់ថា ប៉ែន យៀវនិន ថាបងធំទី២ លេចខ្លួនមក ប៉ុន្តែខ្ញុំវិញថា នួន ជា គឺជាបងធំទី២។

[១១:២៧:១៤]

អៀង សារី បានអះអាងចង់បញ្ជាក់ថា កិច្ចសម្ភាសន៍នេះគឺឱកាសមួយដើម្បីឲ្យគាត់ ដើម្បីឲ្យខ្ញុំអាចសរសេរបញ្ជាក់ថា មិនមែនគាត់ទេជាបងធំទី២ គឺ នួន ជា ទេជាបងធំទី២។ អ្វីដែលគាត់បញ្ជាក់មកខ្ញុំ ហាក់បីដូចជាស៊ីសង្វាក់ និងបញ្ជាក់អះអាងទៅលើជំហរហ្នឹង។ ដូច្នេះគាត់មានចំណាប់អារម្មណ៍ក្នុងការបរិច្ចាគ ក៏ដូចជាបញ្ជាក់ពាក់ព័ន្ធទៅនឹងកិត្តិយស ឬក៏សញ្ញាណ ដែលឥឡូវនេះគឺថាម្នាក់ៗ ជាពិសេសគឺម្នាក់ៗគឺបានបះបង់ចោលហើយដែលអ្នកណាជាបងធំទី២អីហ្នឹង គឺមិនមានសញ្ញាណាថា អៀង សារី ជាបងធំទី២ទេ។ ហើយក្រោយពីហ្នឹងមកគឺថា ហាក់បីដូចជាត្រឹមត្រូវហើយឈ្មោះនេះ។

**ស៖** សូមសួរ ខ្ញុំសូមសួរជាទូទៅតែម្តង។ ហ្វីលីព ស្សូត បានសរសេរសៀវភៅរបស់គាត់ ដែលថា -- នៅពេលដែលលោកសម្ភាស អៀង សារី តើលោកមានពួចម្លើយរបស់គាត់នេះដែរឬទេ ឬក៏មុនលោកទៅធ្វើការសម្ភាសហ្នឹង លោកមានការប្រុងប្រយ័ត្នទាក់ទងទៅនឹងការចោទប្រកាន់អំពីការមានការកលល្បិចរបស់គាត់ ទាក់ទងទៅនឹងបុគ្គលិកលក្ខណៈរបស់គាត់ ឬយ៉ាងណា?

[១១:២៩:០០]

**ឆ៖** ចម្លើយដែលទូលំទូលាយនេះ គឺថា គាត់គឺជាអតីតកម្មាភិបាលខ្មែរក្រហមចុងក្រោយដែលមានអំណាច ដែលខ្ញុំបាននិយាយ ដែលមានអំណាចជាចុងក្រោយប៉ុន្មានទសវត្សរ៍មកនេះ។ ហាក់បីដូចជាទាក់ទាញ ឬខ្ញុំ ថាគាត់នោះមិនទទួលខុសត្រូវរាល់អំពើគួរឲ្យភ័យរន្ធត់ដែលបានកើតឡើងនោះ។ គឺថាឱកាសដ៏កម្រប៉ែបនេះ កម្រនឹងទទួលបានចំពោះការទទួលសារភាពទៅនឹងការទទួលខុសត្រូវនូវអ្វីដែលបានកើតឡើងនោះណាស់។ នេះគឺជាបទពិសោធន៍ដូចគ្នា បើខ្ញុំមិនចាំមិនច្រឡំទេ គឺ យុ ឆាំង ពីមជ្ឈមណ្ឌលកម្ពុជាក៏បញ្ជាក់យ៉ាងដូច្នេះ គឺថាស្ទើរតែដូចអ្នកដទៃទៀតហើយ ម្នាក់ៗគឺថា គាត់ហាក់មានរូបភាពមួយអូសទាញខ្ញុំ បញ្ជាក់ថាគាត់មិនទទួលខុសត្រូវទៅលើបញ្ហាទាំងអស់នោះ ឬក៏មិនទទួលខុសត្រូវដោយផ្ទាល់ ដែលអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ដទៃទៀត ឬក៏មេធាវីផ្នែកព្រហ្មទណ្ឌណាមួយបានលាបពណ៌មកលើរឿងហ្នឹង។ ខ្ញុំអត់មាន-- ដូច្នេះការសន្ទនានេះគឺធ្វើឡើងនៅក្នុងកម្រិតមួយផ្សេងនោះ។

E1/224.1

[១១:៣០:៤៥]

**ស៖** តើលោកអាចបញ្ជាក់ឬក៏អាចនិយាយបានទេថា កិច្ចសម្ភាសន៍ដែលលោកធ្វើជាមួយលោក អៀង សារី នោះគឺនៅក្នុងឆ្នាំ៩៦ គឺជាការសម្ភាសដែលថាតើលោកអាចបញ្ជាក់ថា ផ្នែកណាជាផ្នែកត្រឹមត្រូវ? ផ្នែកណាជាផ្នែកមិនត្រឹមត្រូវដែរឬទេ? គឺខ្ញុំចង់ដឹងថាតើប្រភពព័ត៌មានណាខ្លះដែលមាន អ្នកដទៃទៀតជួយគាំទ្រថាត្រឹមត្រូវ ផ្នែកណាខ្លះដែលមិនត្រឹមត្រូវ?

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំទុកឱ្យសំណួរមុននឹងសួរឆ្លើយបាន ប៉ុន្តែសំណួរនេះដាច់ខាតមិនឱ្យទៅមុខបានទេ។ ដូច្នេះខ្ញុំគិតថាសូម្បីតែលោក ហេដឌ័រ គាត់ជាសាក្សី ឬក៏អ៊ីចឹងក៏ដោយ គាត់មិនអាចសម្រេចបាន ឬក៏មិនអាចឆ្លើយបាន ថាតើផ្នែកណាមួយដែលលោក អៀង សារី និយាយពិត ផ្នែកណាមួយដែលលោក អៀង សារី និយាយកុហកនោះទេ វាមិនអាចទេ។ ទោះបីថាលោក អៀង សារី និយាយពិតឬមិនពិតក៏ ដោយវាជាបញ្ហារបស់អង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច មិនមែនជាសិទ្ធិ ឬក៏ជាកាតព្វកិច្ចរបស់លោក ស្ទីវ ហេដឌ័រ ដែលត្រូវឱ្យគេមកសួរឆ្លើយបែបនេះនោះទេ។

[១១:៣២:០៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថា សហភាតារបស់ខ្ញុំ គឺខាងព្រះរាជអាជ្ញាយល់ខុសពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំចង់និយាយការពិតដែលខ្ញុំចង់និយាយនៅពេលនេះគឺថា តើជាការពិតអង្គហេតុ ឬក៏ជាការពិតអង្គច្បាប់នោះ។ ដូច្នេះនៅក្នុងការសន្ទនាគ្នាជាទូទៅ គឺយើងអាចវាយតម្លៃបាន គឺផ្អែកទៅលើលក្ខណៈរបស់មនុស្ស ផ្អែកទៅលើធម្មជាតិរបស់មនុស្ស ដែលយើងជជែកជាមួយគ្នាហ្នឹង គឺគ្រាន់តែថាគាត់មើលទៅថាតើគាត់យល់ថាអាមួយណាពិត មួយណាមិនពិតអាហ្នឹងជាការសម្រេចរបស់គាត់។ ដូច្នេះ ខ្ញុំមិនមែនចង់និយាយអំពីការពិតនៅក្នុងផ្នែកអង្គច្បាប់អ្វីនោះទេ។ ហើយខ្ញុំក៏បានសួរសាក្សីផងដែរថាតើអ្វីដែលលោក អៀង សារី បានឆ្លើយនៅក្នុងការសម្ភាសហ្នឹងគឺវាស្រប ឬវាស៊ីសង្វាក់ទៅនឹងអ្វីដែលប្រភពព័ត៌មានដទៃទៀត បានប្រាប់បានជម្រាបដល់គាត់ដែរឬទេ។ ដូច្នេះ ខ្ញុំគិតថាសំណួររបស់ខ្ញុំ គឺជាសំណួរដែលត្រឹមត្រូវក្នុងការសួរសាក្សីនេះទាក់ទងទៅនឹងការសម្ភាសដែលគាត់បានធ្វើឡើង។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៣៣:៤០]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះសាក្សី ស្ទីវ ហេដឌ័រ គឺមានសំអាងហេតុសមស្រប។ ដូច្នេះសេចក្តីជំទាស់នេះមានប្រសិទ្ធភាព សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា នេះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងបន្តទៅមុខទៀតលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេដឌ័រ លោកបានសរសេរសៀវភៅជាច្រើន អត្ថបទជាច្រើនពាក់ព័ន្ធទៅនឹងរបបកម្ពុជាប្រជាធិបតេយ្យពី ៧៥ដល់ ៧៩ និងបក្សកុម្មុយនីស្តកម្ពុជា ក៏ដូចជាគោលនយោបាយ ព្រមទាំងទស្សនៈអំពីកុម្មុយនីស្តផងដែរ។ ហើយខ្ញុំក៏ដឹងដែរថា លោកមិនដែលធ្លាប់ជួបសម្ភាសជាមួយនឹងមេដឹកនាំជាន់ខ្ពស់របស់របបកម្ពុជាប្រជាធិបតេយ្យច្រើននោះទេ។ លោកមិនដែលធ្លាប់ជួប ប៉ុល ពត, នួន ជា មិនដែលសម្ភាស តាម៉ុក ហើយមិនដែលសម្ភាស សុន សេន, វន វ៉េត ហើយលោកក៏មិនដែលធ្លាប់ជួបសម្ភាស សោ ភឹម, រស់ ញឹម ផងដែរ។ ខ្ញុំចង់សួរថាតើលោកអាចប្រាប់យើងបានដែរទេ ថាវិធីសាស្ត្រក្នុងការស្រាវជ្រាវរបស់លោកហ្នឹងវាមានបញ្ហាអ្វីនៅក្នុងការសរសេរអត្ថបទ ក៏ដូចជាសៀវភៅដែលលោកបានបោះពុម្ពផ្សាយជាលក្ខណៈស្រាវជ្រាវហ្នឹង? តើវាមានបញ្ហាអ្វីទេ?

[១១:៣៥:៣៣]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំសូមឆ្លើយថា ជាការមិនត្រឹមត្រូវទេ ដែលថាខ្ញុំមិនដែលធ្លាប់ជួប សុន សេន, នួន ជា ហ្នឹង គឺខ្ញុំធ្លាប់ជួប សុន សេន, នួន ជា។ ខ្ញុំធ្លាប់ជួប តាម៉ុក ទៀត។ ពិតហើយថាខ្ញុំមិនដែលជួបសម្ភាសគាត់ឲ្យបានលម្អិតលម្អន់ ប៉ុន្តែខ្ញុំធ្លាប់ជួប នួន ជា នៅខេត្តបាត់ដំបង នៅក្នុងផ្ទះរបស់គាត់នៅក្នុងខេត្តបាត់ដំបងនោះឯង។ ហើយតាមពិតទៅគឺថា វាជាការពិតដែលយើងនិយាយ ប្រសិនបើយើងបានប្រភពព័ត៌មានកាន់តែច្រើនកាន់តែល្អ។ ប៉ុន្តែយ៉ាងណាក៏ដោយ យើងគួរតែគិតអំពីចន្លោះ ឬក៏គម្លាតនៃប្រភពព័ត៌មានដែលយើងអាចលើកយកមកស្រាវជ្រាវ អាចយកមកធ្វើការសរសេរជាសៀវភៅនោះបាន។ វាប្រហែលជាមិនមានភាពម៉ឺងម៉ាត់ជាក់ជាក់លាក់មែន ក៏ប៉ុន្តែយ៉ាងណាក៏ដោយអ្នកសិក្សាស្រាវជ្រាវ អ្នកសិក្សា

ទាំងអស់ហ្នឹង គឺផ្អែកទៅលើបញ្ហាទាំងអស់នេះ។ យើងតែងតែជួបបញ្ហា ហើយយើងប្រឈមជាមួយនឹងបញ្ហា។

[១១:៣៦:៣៨]

ដូច្នេះប្រសិនបើអាច ខ្ញុំចង់បញ្ជាក់ថាជាការពិតប្រសិនបើយើងធ្វើការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រនយោបាយហ្នឹង គឺបែបសិក្សាស្រាវជ្រាវបែបអ្នកប្រវត្តិវិទូហ្នឹង គឺថាទិន្នន័យហ្នឹងអាចទុកចិត្តបាន។ ទោះបីថាទិន្នន័យហ្នឹងវាមានតម្លៃភស្តុតាង ឬក៏អត់ក៏ដោយ ប៉ុន្តែពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហមហ្នឹង គឺថាព័ត៌មានហ្នឹងវាមានចំនួនតិច ប៉ុន្តែវាមានគុណភាពខ្ពស់។ វាដូចគ្នានឹងករណីអតីតសហភាពសូវៀត ឬក៏អតីតប្រទេសអាល្លឺម៉ង់ ឬក៏ចិន វៀតណាម ដូចគ្នាដែរ។ គឺយើងតែងតែមាននូវការខ្វះចន្លោះតែងតែមាននូវការបាត់បង់ព័ត៌មាន អាហ្នឹងវាជាបញ្ហាជាក់ស្តែងរបស់អ្នកស្រាវជ្រាវ។ អាហ្នឹងគឺជាលក្ខណៈជាក់ស្តែងរបស់វិទ្យាសាស្ត្រនយោបាយរបស់អ្នកប្រវត្តិវិទូ។

ខ្ញុំគិតថាអាហ្នឹងគឺវាជាបញ្ហា ខ្ញុំបានរិះចង់ដឹងថាតើមានអ្វីកើតឡើង កើតឡើងដោយរបៀបណាកើតឡើងដោយរបៀបណាវាតែងតែមានចន្លោះប្រហោងហើយ។ វាជាការពិតជាក់ស្តែង។

[១១:៣៧:៥១]

**ស៖** នៅក្នុងការងាររបស់លោក នៅក្នុងការបោះពុម្ពផ្សាយរបស់លោក លោក ហេដឌ័រ ពេលខ្លះគឺថាលោកគ្រាន់តែនិយាយយោងទៅលើការបោះពុម្ពផ្សាយរបស់អ្នកនិពន្ធម្នាក់ផ្សេងទៀត។ ពេលខ្លះលោកនិយាយអំពី ប៉ុងសូជ៍ ពេលខ្លះលោកនិយាយអំពី ដូណាល់ យើគ ពេលខ្លះលោកយកអ្នកនិពន្ធដទៃយកមកដាក់។ ដូច្នេះ ខ្ញុំចង់ដឹងថាតើលោកអាចប្រាប់យើងបានទេ តើលោកផ្អែកទៅលើអ្វីដែលលោកធ្វើការជ្រើសរើសសៀវភៅរបស់អ្នកនេះ ឬក៏អត្ថបទរបស់អ្នកនោះ ដែលលោកសម្រេចថាយកមកបោះពុម្ពផ្សាយដោយផ្អែកលើសៀវភៅគេហ្នឹង តើលោកផ្អែកទៅលើមូលដ្ឋានអ្វីដែរ?

**ឆ៖** ផ្នែកចម្លើយហ្នឹងគឺខ្ញុំបានឆ្លើយពីមុនរួចមកហើយ។ ក្នុងនាមជាអ្នកវិភាគរបបខ្មែរក្រហមខ្ញុំបានធ្លាប់ទៅមើលសារមន្ទីរ"ហូឡូខូស" ខ្ញុំបានធ្លាប់ទៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ផ្សេងៗគ្នា គឺខ្ញុំផ្អែកទៅលើព័ត៌មានបន្ទាប់បន្សំនានាក្នុងការស្រាវជ្រាវរបស់ខ្ញុំ។ ហើយខ្ញុំធ្លាប់ទៅបណ្ណាល័យកណ្តាល ឬក៏បណ្ណាល័យនានាខ្ញុំអាចដឹងបាន។

[១១:៣៩:០៩]

ដូច្នេះ យើងមាននូវទិន្នន័យបន្ទាប់បន្សំជាច្រើនដែលយើងអាចមកប្រើប្រាស់បាន។ ដូច្នេះហើយ

ឲ្យតែមានព័ត៌មានដែលខ្ញុំអាចទុកចិត្តបាន ខ្ញុំយកមកប្រើប្រាស់។ វាមានអ្វីដែលកើតឡើងនៅអាល្លឺម៉ង់ អ្វីដែលកើតឡើងនៅសូវៀត អ្វីដែលកើតឡើងនៅក្នុងរបបម៉ៅនៅប្រទេសចិន ហើយនិងអ្វីដែលបានកើតឡើងនៅក្នុងពេលបដិវត្តន៍នៅក្នុងប្រទេសវៀតណាមក្នុងទសវត្សរ៍៦០។ ទាំងអស់ហ្នឹងៗ គឺត្រូវបានគេសរសេររៀបរាប់លម្អិតច្រើន គឺច្រើនជាងអ្វីដែលកើតឡើងនៅប្រទេសកម្ពុជាក្នុងរបបខ្មែរក្រហមទៅទៀត។ ដូច្នេះយើងអាចជ្រើសរើសព័ត៌មានទាំងអស់នោះយកមកប្រើប្រាស់បាន។ គឺថាវាជាករណីមួយដែលខ្ញុំចង់បង្ហាញលោក។ ប៉ុន្តែក្នុងការជ្រើសរើសព័ត៌មានដែលខ្ញុំយកមកប្រើប្រាស់ទាក់ទងទៅនឹងរបបខ្មែរក្រហមហ្នឹង គឺថាខ្ញុំមានភាពលម្អៀងមួយ ដែលថាខ្ញុំផ្អែកទៅលើមូលដ្ឋានដែលខ្ញុំគិតថាទុកចិត្តបាន។ គឺថាខ្ញុំផ្អែកទៅលើប្រភពដែលថាប្រសិនបើគេនៅស្រុកខ្មែរកាន់តែយូរ គេកាន់តែដឹងពីស្រុកខ្មែរ នៅពេលដែលគេជួបជាមួយនឹងប្រជាជនខ្មែរច្រើន គេនឹងដឹង។ នៅពេលដែលគេនៅស្រុកខ្មែរយូរ បានន័យថាមុននឹងចាកចេញពីប្រទេសខ្មែរ គឺគេនៅកាន់តែយូរ គឺកាន់តែយើងអាចទុកចិត្តបាន។ ទាំងអស់ហ្នឹង គឺជាការសរសេរ ឬក៏ខ្ញុំអាចនិយាយបានថា ជាប្រភពព័ត៌មានបន្ទាប់បន្សំដែលខ្ញុំត្រូវដកស្រង់យកមកសរសេរនៅក្នុងសៀវភៅខ្ញុំ។

[១១:៤០:៣៥]

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរលោកបន្តទៅទៀត។ នេះខ្ញុំលើកឧទាហរណ៍មួយអំពីសៀវភៅរបស់ ហ្វ្រង់ស្វ័រ ប៉ុងស្ងដ៍។ ខ្ញុំគិតថា លោកបានអានការរិះគន់យ៉ាងច្រើន ដែលលោក ម៉ៃខល វីកឃើរី សរសេរដែលថាប្រើប្រាស់ការសម្ភាសរបស់ ប៉ុងស្ងដ៍ គឺវាមិនល្អ គឺបន្ទាប់ពីថ្ងៃទី១៧ មេសា ឆ្នាំ៧៥។ ដូច្នេះខ្ញុំចង់ឲ្យលោកប្រាប់យើងថា តើលោកដាក់ -- គិតអំពីការរិះគន់របស់លោក វីកឃើរី ទៅក្នុងសៀវភៅរបស់លោកដែរឬទេ?

**ឆ៖** ខ្ញុំគិតថា វាជាការរិះគន់ ជាការវាយប្រហារ។ ឥឡូវនេះខ្ញុំនិយាយអ៊ីចេះវិញ ក្នុងលក្ខណៈជាទូទៅមួយ។ តាមអ្វីដែលខ្ញុំដឹង គឺថាវាគ្មានបញ្ហាជាមូលដ្ឋាននោះទេ ក្នុងការពឹងផ្អែកទៅលើសក្ខីកម្មរបស់ជនភៀសខ្លួនដដែលៗ ឬក៏ជាន់គ្នា ដើម្បីស្វែងរកការពិត។ អានេះគឺជាពាក្យដែលតុលាការនិយមប្រើប្រាស់ គឺស្វែងរកការពិតនេះឯង។ ដូច្នេះ ប្រសិនបើយើងមើលទៅលើអ្វីដែលគេនិយាយអំពីប្រវត្តិសាស្ត្រ អំពីការយល់ដឹងអំពីរបបកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលរបបកម្ពុជាប្រជាធិបតេយ្យនៅមានអំណាចនៅឡើយហ្នឹង គឺជាគោលជំហរជាសាធារណៈ ហើយវាមានក្រុមអ្នកស្រាវជ្រាវតិចតួចបំផុតដែលគាត់សិក្សាអំពីរបបកម្ពុជាប្រជាធិបតេយ្យនេះ។

[១១:៤២:២៧]

ដូច្នេះទោះបីជាយ៉ាងណាក៏ដោយ ខ្ញុំយល់ថាពួកគាត់យល់អំពីរបបកម្ពុជាប្រជាធិបតេយ្យ ហើយពួកគាត់ភាគច្រើនហ្នឹង គឺថាខ្ញុំយល់ថា ពួកគាត់ភាគច្រើនអាចធ្វើការសន្និដ្ឋានបានត្រឹមត្រូវ។ នៅពេលដែលពួកគាត់បានជួបជាមួយមនុស្សកាន់តែច្រើន គឺថាអ្នកដែលមានបទពិសោធន៍ផ្ទាល់នៅក្នុងរបបហ្នឹងគឺកាន់តែច្រើន។ ដូច្នេះគឺថាពួកគាត់អាចពឹងផ្អែកបាន អាចទុកចិត្តបាន។ និយាយជាទូទៅ គឺថាវាមិនមានបញ្ហាក្នុងការសិក្សាស្រាវជ្រាវច្រើននោះទេ។ ប្រសិនបើយើងនិយាយអំពីសើចចំអក ការរិះគន់ដែលលោក វីកឃើរី គាត់និយាយទាក់ទងទៅនឹងការសម្ភាស ឬក៏សក្ខីកម្ម គឺយើងអាចចាត់ទុកថា ការសម្ភាសជាមួយជនភៀសខ្លួន គឺថាវាមានករណីជាច្រើនដែលថាការសម្ភាសហ្នឹង ត្រូវបានធ្វើឡើងដោយខ្ញុំផ្ទាល់។ ហើយការសម្ភាសរបស់ខ្ញុំហ្នឹងហើយ ដែលខ្ញុំអាចប្រគល់ទៅឲ្យ ម៉ៃខល។ ម៉ៃខល គាត់បានដឹង ហើយវាមានករណីជាច្រើននៅក្នុងពេលសម័យនោះតែម្តង។ ហើយការបកស្រាយរបស់គាត់ផ្សេងពីការបកស្រាយរបស់ខ្ញុំ។ ដូច្នេះហើយយ៉ាងណាក៏ដោយ វាមានការរិះគន់ទៅលើការសើចចំអកហ្នឹងតទៅទៀត។

[១១:៤៤:00]

ដូច្នេះហើយ គឺថាវាមានភាពជាច្រើនដែលខ្ញុំចង់និយាយ ដែលវាពាក់ព័ន្ធ ក៏ដូចជាការឆ្លើយតបទៅវិញទៅមក ទាក់ទងទៅនឹងអ្វីដែល ម៉ៃខល វីកឃើរី គាត់បាននិយាយអំពីរបបខ្មែរក្រហម។ ដូច្នេះភាពខុសគ្នា គឺថាវាមានភាពខុសគ្នា ក៏ដូចវាមានវាភាពដូចគ្នាផងដែរ។ នៅពេលដែលយើងនិយាយអំពីការចាប់ផ្តើម ទស្សនៈដំបូង ឬក៏ការគិតដំបូង ភាពខុសគ្នាសំខាន់ គឺថាវាជាលក្ខណៈរបស់កុម្មុយនីស្តហើយនិងរបបបែបនេះ។ ហើយ ម៉ៃខល គាត់ព្យាយាមនិយាយផ្សេងដោយគាត់លើកអំពី ប៉ែន ឃៀវនិនហើយគាត់ថា វាអត់មានអីពាក់ព័ន្ធជាមួយនឹងរបបកុម្មុយនីស្ត អត់មានទាក់ទងទៅនឹង ម៉ៅនិយម ឬក៏ស្អីទាំងអស់ ទាក់ទងទៅនឹងរបបកុម្មុយនីស្តនោះទេ។ ដូច្នេះអាហ្នឹង គឺថាវាជា -- វាគឺជាការយល់ឃើញរបស់ វីកឃើរី របស់ ហេដឌ័រ គឺផ្សេងៗគ្នា។ ហេដឌ័រ យល់អ៊ីចេះ វីកឃើរី យល់អ៊ីចុះអ៊ីចឹងទៅ។ អាហ្នឹងហើយជាការសន្និដ្ឋាន ឬក៏ការយល់របស់អ្នកជំនាញ ហើយអ្នកជំនាញគាត់ផ្អែកទៅលើព័ត៌មានគឺព័ត៌មានដែលជាការពណ៌នា។ ដូច្នេះណាក៏ដោយ គឺយើងមានព័ត៌មានប្រហាក់ប្រហែលគ្នា វាមិនមានអ្វីដែលខុសគ្នាខ្លាំងក្លានោះទេ ហើយគាត់ផ្អែកទៅលើព័ត៌មានមួយចំនួនដែលខ្ញុំផ្តល់ឲ្យគាត់ផងដែរ។

[១១:៤៥:៣០]

**ស៖** ខ្ញុំកំពុងតែតាមដានចម្លើយរបស់លោក ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំចង់ឲ្យវាច្បាស់ ឲ្យវាមានឧទាហរណ៍លម្អិតផងដែរ អំពីការវាយតម្លៃរបស់លោក។ គឺនៅក្នុងអត្ថបទរបស់លោក លោកនិយាយថា ឯកសាររបស់បក្សកុម្មុយនីស្ត ដូចជាទស្សនាវដ្តីទង់បដិវត្ត ទស្សនាវដ្តីផ្សេងៗហ្នឹង គឺជាឯកសារដែលមានគោលនយោបាយ ដែលគេបង្ហាញថា ជាង៩៥ភាគរយនៃប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងគឺល្អ។ ចំណែកប្រាំភាគរយទៀត គឺយោងទៅតាមកម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជាថាមិនល្អ។ តើយ៉ាងម៉េចដែរបញ្ហានេះ?ឥឡូវនេះយើងសន្មតអ៊ីចេះវិញ ដើម្បីឲ្យវាច្បាស់លាស់ទាំងអស់គ្នា តើលោកធ្វើយ៉ាងណាដើម្បីឲ្យប្រាកដថាលោកមិននិយាយជាមួយនឹងមនុស្សប្រាំភាគរយដែលអាក្រក់ហ្នឹង គឺថាលោកនិយាយជាមួយមនុស្សដែលល្អផងដែរ។ បានន័យថា លោកធ្វើម៉េចឲ្យច្បាស់ថាលោកសួរទាំងអស់អាក្រក់ អ្នកល្អ អ្នកដែលត្រឹមត្រូវ អ្នកដែលខុស។ ដូច្នេះខ្ញុំចង់ដឹងថាតើលោកធ្វើយ៉ាងណាដើម្បីឲ្យប្រាកដក្នុងខ្លួនថា អ្នកដែលលោកបាននិយាយហ្នឹង គឺជាមនុស្សដែលមកពីគ្រប់ផ្នែកទាំងអស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១១:៤៧:០៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត រេយ៍នីរ៖**

ខ្ញុំសូមធ្វើការជំទាស់។ ជាដំបូងការនិយាយដោយលើកឧទាហរណ៍ ដោយមិនមានឯកសារវែងបែបហ្នឹង គឺគ្មានយោងទៅលើឯកសារ មិនមានទំព័រ មិនមានជើងទំព័រ មិនមានលេខ ERN អីទាល់តែសោះ។ ទី២ គឺនិយាយយោងទៅលើស្ថិតិដែលវាពាក់ព័ន្ធទៅនឹងអ្នកជំនាញទៅវិញទេ។ ទី៣ ការស្នើសុំឲ្យសាក្សីធ្វើការសន្មតថាមាន ៩៥ភាគរយ ប្រាំភាគត្រឹមត្រូវ មិនត្រូវ អាហ្នឹងវាជាការសន្មតទាំងស្រុង។ ទី៤ ការស្នើសួរសាក្សី ថាតើសាក្សីធ្វើយ៉ាងម៉េច ដឹងថាអ្នកដែលគាត់និយាយនៅក្នុងក្រុមនេះនៅក្នុងក្រុមនោះ នៅតំណាងក្រុមនេះ តំណាងក្រុមនោះ គឺប្រាកដតែម្តង គឺប្រាកដជាការច្របូកច្របល់ហើយជាសំណួរដែលធំ រញ៉េរញ៉ៃ។

ដូច្នេះតាមការយល់ឃើញរបស់ខ្ញុំ តាមការគិតរបស់ខ្ញុំ គឺថាគឺជាសំណួររបស់អ្នកជំនាញ ហើយម្យ៉ាងទៀតវាជាសំណួរដែលច្របូកច្របល់មិនអាចទទួលយកបានទេ។ ដូច្នេះ ខ្ញុំជំទាស់ទាំងស្រុងទៅលើ

សំណួរទាំងអស់នេះ ដោយផ្អែកទៅលើមូលដ្ឋានដែលខ្ញុំលើកឡើងអម្បាញ់មិញ។

[១១:៤៨:៣៩]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឆ្លើយលោកប្រធាន ខ្ញុំគ្រាន់តែចង់ធ្វើឲ្យវាច្បាស់លាស់ដែលខ្ញុំប្រើប្រាស់ភាគរយ ហើយខ្ញុំមិនមែនចង់និយាយថា ភាគរយហ្នឹងត្រឹមត្រូវទេ ខ្ញុំគ្រាន់តែចង់ឲ្យមានការពិចារណាទាំងអស់គ្នា។ ខ្ញុំគ្រាន់តែចង់ដឹងថា សាក្សីនៅពេលដែលគាត់សរសេរសៀវភៅហ្នឹង តើគាត់បាននិយាយ បានសម្ភាសជាមួយនឹងគ្រប់ផ្នែកទាំងអស់នៃប្រជាជន។ បានន័យថា ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងគាត់មកពីគ្រប់កន្លែងទាំងអស់ ឬមួយក៏យ៉ាងណា? ព្រោះថាប្រជាជនដែលរស់នៅតាមតំបន់ព្រំដែនថៃគឺគាត់អាចផ្ដល់នូវចម្លើយផ្សេងគ្នា ឬក៏អ្នកដែលមកក្នុងអំឡុងពេលខុសៗគ្នា គាត់ឲ្យចម្លើយផ្សេងៗគ្នា គឺអ្នកដែលរត់គេចខ្លួនពីរបប។

ឥឡូវនេះ យើងកុំគិតអារឿង ៩៥ភាគរយ ប្រាំភាគរយ អ្វីហ្នឹងទេ។ ខ្ញុំគិតថា លោក ហេដឌ័រ គាត់យល់ពីសំណួរខ្ញុំច្បាស់ហើយ គាត់ចង់ដឹងថាខ្ញុំសួរអ្វីហើយ។ ហេតុដូច្នេះ ខ្ញុំគ្រាន់តែចង់សួរថាតើគាត់ធ្វើយ៉ាងណាដើម្បីជ្រើសរើសសាក -- ជ្រើសរើសអ្នកដែលគាត់ត្រូវសម្ភាស។ ខ្ញុំគិតថាលោក ហេដឌ័រ គាត់យល់ថា ខ្ញុំចង់និយាយពីអ្វី។

[១១:៥០:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[១១:៥៣:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីសម្រេចលើសេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ចំពោះសំណួរដេញដោលរបស់មេធាវីការពារក្ដីលោក នួន ជា ចំពោះសាក្សីលោក ស្ទីវ ហេដឌ័រ ចុងក្រោយអម្បាញ់មិញនេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទសូមអរគុណលោកប្រធាន។ ជាបឋមអង្គជំនុំជម្រះសូមកត់សម្គាល់ថា ទៅកាន់ខាងការពារក្ដីថានៅក្នុងអំឡុងពេលសួរសាក្សីរូបនេះ ដោយសហព្រះរាជអាជ្ញា ឬក៏ដោយមេធាវីដើមបណ្ដឹងរដ្ឋប្ប-

វេណើ ខាងការពារក្តីសុំឲ្យសាក្សីនេះឆ្លើយក្នុងឋានៈជាសាក្សី។ ក៏ប៉ុន្តែឥឡូវនេះសំណួរសួរទាក់ទងទៅនឹងវិធីសាស្ត្រដែលលោកសាក្សី ស៊ីវ ហេងឌ័រ នេះបានប្រើប្រាស់នោះ មិនមែនជាវិធីសាស្ត្ររបស់សាក្សីទេ ក៏ប៉ុន្តែវាទៅជាវិធីសាស្ត្ររបស់អ្នកជំនាញ។

[១១:៥៤:៤៦]

អ៊ីចឹង១អ្វីដែលយើងត្រូវសួរ គឺថាសួរថាតើគាត់បានធ្វើការយ៉ាងម៉េច គាត់បានធ្វើការជ្រើសរើសរបៀបម៉េច។ នេះគឺជាសំណួរទាក់ទងទៅនឹងការងាររបស់អ្នកស្រាវជ្រាវ ហើយរបស់អ្នកជំនាញហើយ។ អ៊ីចឹងឃើញថាពុំមានការពាក់ព័ន្ធអ្វីទេក្នុងការចោទសំណួរទៅសាក្សី ស៊ីវ ហេងឌ័រ នេះ។ អ៊ីចឹងអង្គជំនុំជម្រះសូមឲ្យលោមមេធាវីចូលទៅនិយាយអំពីអ្វីផ្សេងទៀត ហើយអ៊ីចឹងការជំទាស់របស់សហព្រះរាជអាជ្ញានេះ យើងទទួលយកការជំទាស់របស់សហព្រះរាជអាជ្ញា គឺថាមានសុពលភាព។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាខ្ញុំយល់អំពីសេចក្តីសម្រេចនេះ គឺថាព្រះរាជអាជ្ញាគាត់សួរសំណួរជាច្រើនអស់រយៈពេល ២ថ្ងៃជាងអំពីអត្ថបទដែលសាក្សីគាត់សរសេរ សួរអំពីជើងទំព័រប្រភពព័ត៌មានជាដើម។ ឥឡូវនេះ ខ្ញុំសួរអំពីវិធីសាស្ត្រក្នុងការស្រាវជ្រាវ ខ្ញុំមិនមែនសួរពីមតិទេ ប៉ុន្តែចុងក្រោយគេកាត់ខ្ញុំមិនឲ្យនិយាយបាន។ ដូច្នេះ ខ្ញុំគិតថាខ្ញុំគួរតែជម្រាបទៅអង្គជំនុំជម្រះថា គួរតែមានការប្រព្រឹត្តដែលប្រហាក់ប្រហែលគ្នាចំពោះខាងមេធាវីការពារក្តីផងដែរ។ ដូច្នេះប្រសិនបើមិនមានការ -- ដូច្នេះខ្ញុំគិតថាគួរតែវាមានភាពស្មើភាពគ្នាទៅនឹងភាគីទាំងសងខាង ប៉ុន្តែយ៉ាងណាក៏ដោយខ្ញុំសូមបន្តទៅមុខទៀតលោកប្រធាន។ វាជាការគួរឲ្យសោកស្តាយមែនទែន។

[១១:៥៦:២៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេងឌ័រ ខ្ញុំមានសំណួរមួយចំនួនទៀតដែលខ្ញុំចង់សួរលោក ទាក់ទងទៅនឹងអត្ថបទរបស់លោក និយាយអំពីការចម្លើយសារភាព។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ? ថាតើលោកប្រើប្រាស់ចម្លើយសារភាពហ្នឹងដោយរបៀបណានៅក្នុងអត្ថបទរបស់លោក?

**លោក ឃីត វេយ៉ន៍ន័រ៖**

លោកប្រធានខ្ញុំសូមជំទាស់។ ខ្ញុំគិតថាប្រហែលជាអង្គជំនុំជម្រះនៅចាំនៅថ្ងៃទី១ នៃការសាកសួររបស់ខ្ញុំ គឺថាវាមានការបញ្ជាក់ច្បាស់ហើយថា គ្មានសំណួរណាមួយដែលត្រូវសួរទាក់ទងទៅនឹងឯកសារ

ចម្លើយសារភាពនោះទេ។ ហើយនៅថ្ងៃទី០១ ខ្ញុំនិយាយថា ខ្ញុំប្រាកដថា ខ្ញុំមិនសួរសំណួរណាមួយដែលផ្អែកទៅលើចម្លើយសារភាពនោះទេ។ ហើយខ្ញុំជំទាស់ជាមួយនឹងមេធាវីការពារក្តីថា សូមជំទាស់ខ្ញុំចុះប្រសិនបើខ្ញុំបានធ្វើបែបនេះមែន ហើយខ្ញុំមិនបានសួរអំពីចម្លើយសារភាពនោះឡើយ។ ហើយក្នុងរយៈពេល២ថ្ងៃកន្លះនោះឡើយ គឺអត់មានដែលមានម្តងណាព្រះរាជអាជ្ញាថា អត់ដែល -- មេធាវីការពារក្តីនិយាយថា ខ្ញុំបានសួរអំពីចម្លើយសារភាព។ ចម្លើយសារភាពគឺយើងបានបញ្ចូលរួចទៅហើយ ក្នុងនោះមានទាំងចំណារ ក៏ដូចជាលិខិតដែលភ្ជាប់ជាមួយចម្លើយសារភាព។

[១១:៥៧:៥៧]

ដូច្នេះ អង្គជំនុំជម្រះនឹងមិនអាចទទួលបានប្រយោជន៍អ្វីឡើយ នៅពេលដែលលោក ហេដឌ័រ គាត់ឆ្លើយចម្លើយទាក់ទងទៅនឹងចម្លើយសារភាព ព្រោះចម្លើយសារភាពមិនបានដាក់បញ្ចូលទៅក្នុងសំណុំរឿងនោះទេ។ ហើយចៅក្រម ឡាវែន៍ គាត់បានសម្រេចរួចទៅហើយថា នេះគឺជាប្រធានបទដែលមិនត្រឹមត្រូវដែលលោក ហេដឌ័រ មិនអាចឆ្លើយតបបាន។ ហើយខ្ញុំខាងព្រះរាជអាជ្ញាក៏មិនបានសួរទាក់ទងទៅនឹងចម្លើយសារភាព។ ដូច្នេះ ខាងមេធាវីការពារក្តីក៏មិនគួរសួរដូច្នេះដែរ លុះត្រាតែវាមានហេតុផលដែលជាក់លាក់ណាមួយ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំគិតថាវាមានភាពខុសគ្នារវាងការសួរ ថាតើយើងអាចប្រើប្រាស់ចម្លើយសារ-ភាពហ្នឹងដើម្បីវាយតម្លៃទៅលើតម្លៃនៃភស្តុតាងនៃឯកសារណាមួយផ្សេងទៀត។ ខ្ញុំបានសួរអ្នកនិពន្ធរបស់អត្ថបទរបស់អ្នកសរសេរសៀវភៅជាច្រើន អំពីការប្រើប្រាស់ចម្លើយសារភាពរបស់គាត់ក្នុងការសៀវភៅរបស់គាត់។ ប៉ុន្តែខ្ញុំគិតថាវាមានភាពខុសគ្នាយ៉ាងខ្លាំង ថាតើអង្គជំនុំជម្រះដែលជាអង្គជំនុំជម្រះអាចប្រើប្រាស់ គឺអង្គជំនុំជម្រះអាចប្រើប្រាស់ចម្លើយសារភាព ដើម្បីចេញជាសាលក្រម គឺវាខុសពីការដែលអ្នកនិពន្ធគាត់ប្រើប្រាស់ចម្លើយសារភាពដើម្បីសរសេរសៀវភៅ។ ព្រោះថាអ្នកនិពន្ធគាត់ប្រើប្រាស់ចម្លើយសារភាពយ៉ាងច្រើន ហើយដោយផ្អែកលើចម្លើយសារភាពហ្នឹងគាត់បានសន្និដ្ឋាន។ ប៉ុន្តែខ្ញុំមិនសួរអំពីការសន្និដ្ឋាននោះទេ។ ខ្ញុំគ្រាន់តែចង់សួរថា តើគាត់ប្រើប្រាស់ចម្លើយសារភាពហ្នឹងប្រើប្រាស់របៀបណាប្រើប្រាស់ដោយលក្ខណៈបែបណាខ្លះ?

[១១:៥៩:៤៥]

គួរឲ្យសោកស្តាយដែរដែលលោក ហេដឌ័រ គាត់មានអត្ថបទ ខ្លះដែលមិនបានដាក់ទៅក្នុងសំណុំ

រឿង។ ហើយម្យ៉ាងទៀត គឺគេមិនអនុញ្ញាតឲ្យខ្ញុំប្រើប្រាស់ -- ឧទាហរណ៍អត្ថបទដែលថា “ខ្មែរក្រហមគោលជំហររបស់ ប៉ុល ពត ថាតើគាំទ្រខាងវៀតណាម ឬក៏ខាងចិន”។ ហើយខ្ញុំគិតថា នេះជាអត្ថបទដ៏គួរឲ្យចាប់អារម្មណ៍របស់លោក ហេដឌ័រ ទាក់ទងទៅនឹងការប្រើប្រាស់ចម្លើយសារភាពរបស់គាត់ ក៏ដូចជាគ្រោះថ្នាក់ដែលកើតមានឡើងនៅពេលដែលយើងធ្វើការបកស្រាយទៅលើចម្លើយសារទាំងអស់នេះ។ ខ្ញុំគិតថា លោក ហេដឌ័រ គាត់មានសមត្ថភាព មានលទ្ធភាពពេញលេញក្នុងការបញ្ចេញមតិយោបល់ទាក់ទងទៅនឹងវិធីស្រាវជ្រាវរបស់គាត់ ក្នុងការជ្រើសរើសយកចម្លើយសារភាពមកប្រើប្រាស់នៅក្នុងការសរសេរសៀវភៅរបស់គាត់។

**លោក ឃីត រេយ៍ន័រ៖**

យើងគិតបែបនេះ យើងគិតទៅលើអ្វីដែលគាត់បានសរសេរ គិតទៅលើអ្វីដែលគាត់បានប្រើប្រាស់នៅក្នុងជើងទំព័រ ដកស្រង់នៅជើងទំព័រ។ ហើយយើងនឹងអាចយកមកប្រើប្រាស់បាននៅក្នុងឯកសារទាំងអស់នេះ។ គឺថាយើងមិនអាចជួយនោះទេ ដែលយើងមើលទៅលើផ្នែកនេះគឺវាមានចម្លើយសារភាព ១៦ មិនពាក់ព័ន្ធ។ ខ្ញុំចង់សួរថាតើវាមានន័យអ្វីដែលយើងមកស្តាប់លោក ហេដឌ័រ បង្ហាញថាចម្លើយសារភាព១៦វាមិនអាចពាក់ព័ន្ធទៅជើងទំព័រមួយ។ អាចថាបង្ហាញនូវការសារភាពទាំងអស់ ហើយមេធាវីការពារក្តីក៏គួរតែធ្វើដូចគ្នាដែរ។ ដូច្នេះគឺថាវាអត់មានប្រយោជន៍អីទេ ដែលយើងត្រូវមកនាំគ្នាស្តាប់ថាចម្លើយសារភាពដែលមិនអាចប្រើប្រាស់បាន ត្រូវបានគេយកមកសរសេរនៅក្នុងសៀវភៅ។

[១២:០១:៤១]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធានខ្ញុំសូមឆ្លើយបន្តទៅលើចំណុចទាំងអស់នេះ។ យើងទាំងអស់គ្នាបានស្តាប់អស់រយៈពេលរាប់ថ្ងៃ ដែលថាគាត់ធ្លាប់ការ សាក្សីនេះធ្លាប់ធ្វើការនៅខាងព្រះរាជអាជ្ញា ធ្លាប់ធ្វើការជាមួយសហចៅក្រមស៊ើបអង្កេត។ ឥឡូវនេះ ខ្ញុំគ្រាន់តែចង់សួរអំពីវិធីសាស្ត្រក្នុងការសិក្សាស្រាវជ្រាវរបស់គាត់តែប៉ុណ្ណោះ។

[១២:០២:០៥]

ប្រសិនបើខ្ញុំទទួលបាននូវសិទ្ធិ និងអភ័យឯកសិទ្ធដូចដែលព្រះរាជអាជ្ញាបានទទួលនោះវាជាការល្អ។ ដូច្នេះហើយខ្ញុំគ្រាន់តែចង់ដឹងថា សមត្ថភាពរបស់សាក្សីហ្នឹងគឺគ្រាន់តែចង់សួរគាត់ ថាគាត់ធ្វើយ៉ាងណាក្នុងការប្រើប្រាស់ចម្លើយសារភាពហ្នឹង? តើគាត់យកចម្លើយសារភាពនុ៎ងមកប្រើប្រាស់ដោយរបៀប

ណា? គាត់គិតថាចម្លើយសារភាពណាត្រឹមត្រូវ ចម្លើយសារភាពណាមិនត្រឹមត្រូវយកមកប្រើប្រាស់។ ខ្ញុំគិតថានេះជាសំណួរសំណួរដ៏ត្រឹមត្រូវ។ ខ្ញុំមិនមែនចង់ឲ្យគាត់បង្ហាញអំពីទស្សនៈអ្នកជំនាញអ្វីនោះទេ គ្រាន់តែចង់ដឹងថាតើគាត់ប្រើប្រាស់ការសម្ភាសដោយរបៀបណា? ចម្លើយសារភាពដោយណា? អត្ថបទព័ត៌មានដោយរបៀបណា? ឬក៏ព័ត៌មានផ្សេងៗដោយរបៀបណា? គ្រាន់តែចង់សួរបែបនេះទេ។

[១២:០២:៤៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១២:០៥:២២]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់ពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះលើសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ចំពោះសំណួរដែលសួរដេញដោលដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះសាក្សីនូវសំណួរចុងក្រោយអម្បាញ់មិញនេះ។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះយល់ឃើញថា តាមរយៈសំណួរដែលចោទទៅកាន់សាក្សី ស្ទីវ ហេដឌ័រ នេះ គឺជាថ្មីម្តងទៀតហើយ គឺថាមេធាវីលោក នួន ជា កំពុងតែវាយតម្លៃគុណភាពការងារជាអ្នកជំនាញរបស់លោក ស្ទីវ ហេដឌ័រ។ ក៏ប៉ុន្តែត្រូវតែគោរពដូចការលក្ខខណ្ឌតម្រូវដែលក្រុម នួន ជា ទាមទារនោះ គឺថាសូមឲ្យលោក ស្ទីវ ហេដឌ័រ ត្រូវតែមានឋានៈជាអ្នកជាសាក្សីទេ អ៊ីចឹងខ្លួនឯងអ្នកស្នើនោះគួរតែគោរពផងដែរសំណើរបស់ខ្លួន។

អ៊ីចឹងសំណួរដែលលោកទាំងអម្បាលម៉ាននេះមិនត្រូវបានអនុញ្ញាតឲ្យសួរទៀតទេ។ អ៊ីចឹង សូមឲ្យសួរបែបផ្សេងវិញ។ ទៅប្រធានបទផ្សេងទៀតទៅ។

[១២:០៦:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី អរគុណសាក្សី ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅមន្ទប់រង់ចាំសម្រាប់សាក្សី ឬក៏កន្លែងណាមួយនៅសមស្របដែលនៅជិតសាលសវនាការនេះ នៅក្នុងអំឡុងពេលឈប់សម្រាកថ្ងៃត្រង់ ហើយនិងឱ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលារសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

ហើយនិងបង្គាប់ឲ្យមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់សម្រាកនៅខាងក្រោមសាលសវនាការនេះ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅក្នុងបន្ទប់សវនាការនេះនៅរសៀលនេះនៅវេលាម៉ោង ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:០៧នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:៣៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនក្រុមមេធាវីការពារលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស្ទីវ ហេដឌ័រ។

សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សួស្តីលោក ហេដឌ័រ។ ខ្ញុំនឹងធ្វើការផ្លាស់ប្តូរនូវវិធីដែលខ្ញុំសួរសំណួរទៅកាន់លោក។ អ្វីដែលខ្ញុំនឹងធ្វើឡើង គឺខ្ញុំអានចំណុចដកស្រង់ចេញពីអត្ថបទដែលលោកបានសរសេរឡើង គឺអត្ថបទរបស់លោក "ការរើសពូជសាសន៍ និងមាក្ស-ស៊ីស្សឹម"។ ហើយដូចដែលសហព្រះរាជអាជ្ញា ខ្ញុំនឹងផ្តល់ឯកសារនេះមួយច្បាប់ទៅកាន់លោក។

[១៣:៣៣:៤៩]

ខ្ញុំអាន និងអានចេញមកពីអត្ថបទនេះ បន្ទាប់ពីខ្ញុំបញ្ជាក់លេខ ERN ប្រាប់ៗជូនលោក។ មាន

អត្ថបទចំនួន១១ ដែលខ្ញុំនឹងយកមកសួរលោក ហើយខ្ញុំនឹងសួរសំណួរដែលចាប់អារម្មណ៍ ដែលលោកបានសរសេរឡើង។ តើលោកមានព័ត៌មានការពិតណាមួយដែរឬទេ ចេញមកពីអ្វីដែលលោកបានរៀបចំឡើង ដោយកុំឱ្យផ្តល់ជាមតិយោបល់ ឬក៏ទាយស្មាន? តើលោកយល់ទេ ចំពោះអ្វីដែលខ្ញុំលើកឡើង លោក ហេដឌ័រ?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវី យកជូនសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកជូនសាក្សី)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងដកចេញពីឯកសារទី១ គឺឯកសារ E131/1/13.3 គឺឯកសារ “រ៉េស៊ីស្សឹម, ម៉ាក្ស-ស៊ីស្សឹម និងការដាក់ស្លាកប្រល័យពូជសាសន៍នៅក្នុងរបប ប៉ុល ពត”។ ចាប់ផ្តើមពីទំព័រ៤ ERN ជាភាសាអង់គ្លេស 00773703, បារាំងមានលេខ 00802801, ខ្មែរមានលេខ 00884553 ទៅដល់ 554 ហើយក៏មាននៅលើអេក្រង់ផង នឹងដាក់ជូនលោក។

[១៣:៣៥:៤២]

លោកបានសរសេរដូចតទៅ ខ្ញុំសូមដកស្រង់ “ក្នុងពេលដែលតវ៉ាទៅលើទ្រឹស្តី និងប្រភេទដែលគាត់លើកឡើង ចំណុចនេះក៏ចេញមកពីការសន្និដ្ឋានរបស់លោក ឃៀរនិន និងប្រភពជាច្រើនទៀត និងប្រភពដែលគាត់ប្រើប្រាស់។ យើងបានសម្ភាសប្រជាជនកម្ពុជា ដែលស្ថិតនៅក្នុងកម្ពុជាប្រជាធិបតេយ្យនៅពេលដែលពួកគេកាន់អំណាច ហើយក៏យើងផ្អែកទៅលើកិច្ចសម្ភាសន៍របស់លោក ឃៀរនិន ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យនោះបានដួលរំលំក្រោយមកផងដែរ។ នៅក្នុងនោះក៏រួមមានចម្លើយសារភាពយកចេញមកពីកម្មាភិបាល ដែលជាប់នៅមន្ទីរសន្តិសុខ ដូចជា ស-២១ ទួលស្លែង។ ហើយឯកសារចម្លើយសារភាពទាំងអស់នោះមាននៅសារមន្ទីរទួលស្លែង។ ហើយលោក ឃៀរនិន បានធ្វើការស្រាវជ្រាវបញ្ហាទាំងអស់នេះ តាំងពីទសវត្សរ៍ឆ្នាំ១៩៨០។ ក្រោយពិនិត្យមើលប្រភពទាំងអស់នេះ បានបង្ហាញថា ឃៀរនិន យល់ឃើញថាចម្លើយទាំងអស់នោះ គឺគាត់បានជ្រើសរើសយកមកធ្វើជាមូលដ្ឋាន។ ឯកសារគាត់មួយចំនួនពេលខ្លះត្រូវបានច្របាច់បញ្ចូលគ្នា។ ដូច្នេះហើយក៏វាចោទជាបញ្ហាអំពីការជ្រើសរើសរបស់លោក ឃៀរនិន ទៅលើឯកសារដែលមិនមែនជាចម្លើយសារភាព ហើយនិងឯកសារដែលពាក់ព័ន្ធនឹងការបកប្រែ។ ដូច្នេះហើយយើងត្រូវតែធ្វើការពិនិត្យឱ្យបានប្រុងប្រយ័ត្ន មិនត្រឹមតែអ្វីដែល

លោក ឃៀវនិន យកមកធ្វើជាមូលដ្ឋាននោះទេ រួមទាំងចំណុចដែលគាត់កត់សម្គាល់សង្កត់ធ្ងន់នៅលើចំណុចទាំងអស់នោះ"។ តើលោកពិតជាបានសរសេរចំណុចទាំងអស់នេះដែរឬទេ?

[១៣:៣៧:២៨]

**លោក ស៊្មីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំបាន ពិតជាបានសរសេរមែន។

**ស៖** តើលោកអាចជួយពន្យល់បានដែរឬទេ ដែលថាជាការជ្រើសរើសចោះៗនៅក្នុងហ្នឹង។ បាទ បើសិនអត់បញ្ហាទេ ខ្ញុំសូមបន្តទៅមុខទៀត--

**លោក ឃឹត វេយ៍ន័រ៖**

*(គ្មានការបកប្រែ)*

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំមិនសួរសំណួរទេ ខ្ញុំបន្តទៅមុខទៀត។ ផ្អែកទៅលើព័ត៌មានការពិតដោយផ្ទាល់ ដោយមិនឲ្យលោកទាយស្មាន និងបញ្ចេញយោបល់ទេ តើៗលោកបានផ្អែកទៅលើមូលដ្ឋានអ្វីដែលពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំទើបតែអាចជូនលោកអម្បាញ់មិញនេះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៣:៣៨:១២]

**លោក ឃឹត វេយ៍ន័រ៖**

លោកប្រធាន នេះជាសៀវភៅរបស់លោក ហេដឌ័រ ឬយ៉ាងហោចថា អត្ថបទដែលគាត់ផ្ដល់អត្ថាធិប្បាយលើសៀវភៅរបស់លោក ឃៀវនិន។ ដូច្នេះ ក្នុងសេចក្ដីសន្និដ្ឋានរបស់ខ្ញុំ គឺយើងគ្មានប្រយោជន៍អ្វីដែលថា យើងស្ដាប់នូវលោក ហេដឌ័រ សេចក្ដីអត្ថាធិប្បាយរបស់គាត់ចំពោះសៀវភៅរបស់លោក ឃៀវនិន នោះទេ។ ចំណុចនេះ គឺដូចគ្នាដែលលោកចៅក្រម ឡាវ៉ែន៍ គាត់បានសម្រេចពីរដងរួចមកហើយ។ ២០នាទីមុនពេលដែលយើងឈប់សម្រាកនោះ គាត់បានសម្រេចពីរចំណុច -- ពីរដងរួចមកហើយ។ ចំណុចដែលដកស្រង់អម្បាញ់មិញនេះ គឺមិនមានលេខយោង មិនមានគាំទ្រនៅក្នុងលេខយោងនោះទេ។ ប្រសិនយើងមើលលេខយោងជើងទំព័រលេខ៥ ត្រង់ទំព័រ៥ វិញ យើងឃើញនឹងឃើញលេខយោងនោះ។ ផ្នែកដែលអានអម្បាញ់មិញនេះ គឺមិនអាចទទួលយកបាននោះទេ ហើយមិនមានការ

គាំទ្រទៅ ដោយលេខយោងជើងទំព័រទៀត។ ដូច្នេះ ខ្ញុំជំទាស់ទាំងមូលដ្ឋាននៃការសួរ ប្រសិនបើដកស្រង់ពីចំណុចណាមួយនោះ គួរតែចំណុចនុ៎ងពាក់ព័ន្ធ ហើយឲ្យមានលេខយោងជើងទំព័រផងដែរ។

[១៣:៣៩:៣៤]

យើងនៅពេលនេះ គឺចាចង់ស្តាប់លោក ស៊ីវិន១ ហេងឌ័រ ផ្តល់អត្ថាធិប្បាយទៅលើលោក យៀរនិន នូវអ្វីដែលគាត់សរសេរឡើង ហើយបើសិនធ្វើអ៊ីចេះ គឺសួរក្នុងនាមអ្នកជំនាញហើយ។ ខ្ញុំសូមជំទាស់។

**លោក វ៉ិចទ័រ កូប៉េះ**

ខ្ញុំបានអានចំណុចដកស្រង់ ហើយខ្ញុំបានសួរថា គាត់ជាអ្នកសរសេរ ឬក៏មិនមែនជាអ្នកសរសេរ ហើយខ្ញុំបានដកស្រង់ទៅតាមអ្វីដែលសហព្រះរាជអាជ្ញាបានធ្វើឡើង។ ដូច្នេះខ្ញុំធ្វើទៅតាមនុ៎ងតែប៉ុណ្ណោះ។

[១៣:៤០:០៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៣:៤១:១៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្តីលោក នួន ជា ចំពោះសាក្សី ស៊ីវ ហេងឌ័រ អម្បាញ់មិញនេះគឺមានការត្រឹមត្រូវ។ ដូច្នេះសេចក្តីជំទាស់នេះមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ។ ហើយសូមលោកមេធាវីបន្តទៅសំណួរថ្មីទៀត ពីព្រោះអម្បាញ់មិញនេះ ពុំមានភាពពាក់ព័ន្ធទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** ចំណុចដកស្រង់មួយទៀតចេញពីអត្ថបទរបស់លោក ត្រង់ទំព័រ២៤នៅពេលនេះ។ អង់គ្លេស ERN គឺ 00773723, ខ្មែរមានលេខ 00802810 រហូតទៅដល់ 811, ខ្មែរមានលេខ 00884571។ នៅក្នុងចំណុចនេះ គឺយើងឃើញមានរឿងរ៉ាវជាច្រើនដែលបានបង្ហាញអំពីស្ថានភាពនៅភូមិភាគបូព៌ាដែលវាមានស្ថានភាពអាក្រក់ ហើយមានកាន់តែចុះ កាន់តែអាក្រក់ទៅនៅផ្នែកជាច្រើននៅក្នុងប្រទេសកម្ពុជា។ ហើយវាពាក់ព័ន្ធខុសគ្នាទៅនឹងជួរដឹកនាំ រួមទាំងលេខានៅ សោ ភឹម នៅខាងបូព៌ា ផងដែរ។ ក៏ប៉ុន្តែនៅពេលប្រៀបធៀបភូមិភាគបូព៌ាជាមួយរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជារបស់ខាងភូមិភាគនិរតី តាម៉ុក

ស្ទីវិន គាត់ផ្តែកទៅលើរឿងក្តី ហើយគិតថារចនាសម្ព័ន្ធនោះ គឺវាមិនស៊ីសង្វាក់គ្នាដោយលើកឡើងថាចំណុចនេះគឺគាត់អាចលើកឡើងបញ្ជាក់បាន។ គាត់បានបកស្រាយភូមិភាគបូព៌ាជាតំបន់មួយដែលមានលក្ខណៈម៉ាក្សស៊ីសនិយម ហើយវាអាស្រ័យទៅលើកម្មាភិបាល និងការបែងចែកទៅតាមទីតាំងភូមិសាស្ត្រ--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន! លោកមេធាវីអត់មានការបកប្រែជាភាសាបារាំងទេ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងអង្គភាពបកប្រែភាសា។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំមានបញ្ហាមួយទៀត។ ERN ជាភាសាបារាំង គឺឲ្យមកដូចអត់ត្រូវទេ អ្វីដែលផ្តល់ដោយអ្នកបកប្រែនោះ គឺថាអត់ត្រូវទេ។ បើខ្ញុំពិនិត្យមើលទៅ ខ្ញុំសូមឲ្យលោកមេធាវីការពារក្តីផ្តល់លេខ ERN ជាភាសាបារាំងម្តងទៀត។

[១៣:៤៤:១៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** 00802810 រហូតដល់ 811 បានន័យថាលេខចុងក្រោយ 810 ទៅដល់ 811។ ខ្ញុំនឹងអានសារជាថ្មី។ ពាក់ព័ន្ធនឹងចំណុចហ្នឹងលោក ឃៀវនិន បានប្រមូលឯកសារនាសម័យនោះជាច្រើនដែលបានបង្ហាញថា "រហូតមកដល់ការបោសសម្អាត ស្ថានភាពនៅភូមិភាគបូព៌ា គឺជាទូទៅ គឺមិនសូវមានសភាពអាក្រក់ ហើយនិងមិនដូចផ្នែកផ្សេងទៀតនៅក្នុងប្រទេសកម្ពុជានោះទេ។ វាហាក់ជាខុសក្នុងការដែលលើកឡើងថាជាការដឹកនាំរបស់ជួរមេដឹកនាំ ហើយនិងភ្ជាប់ការដឹកនាំទៅកាន់លោក សោ ភឹម។ ក៏ប៉ុន្តែនៅពេលដែលប្រៀបធៀបជាមួយនឹងរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា និងមេដឹកនាំផ្សេងទៀតជាពិសេសភូមិភាគនីរតីរបស់ តាម៉ុក, ឃៀវនិន បានលើកឡើងករណីនេះ ហើយគិតថារចនាសម្ព័ន្ធនេះគឺវាមានលក្ខណៈពុំស៊ីសង្វាក់គ្នា។ ដោយសារតែគាត់បានលើកឡើងចំណុចនេះដើម្បីធ្វើការផ្ទៀងផ្ទាត់។ ការបកស្រាយភូមិភាគបូព៌ាថាជាតំបន់មួយដែលគាំទ្រខាងវៀតណាម ហើយជាពិសេសមានលក្ខណៈខាងម៉ាក្សនិយមនោះ គឺវាអាស្រ័យទៅលើកម្មាភិបាល និងការបែងចែកទៅតាមភូមិសាស្ត្រ ភូមិភាគបូព៌ាដែលថាភស្តុតាងមួយចំនួនអាចមានមូលដ្ឋាន ដើម្បីផ្តល់ជាការគាំទ្រទៅលើការកំណត់លក្ខណៈបែបនេះ។ គឺក៏មានការផ្តែកទៅលើសក្ខីកម្មមកពីអតីតកម្មាភិបាលភូមិភាគបូព៌ា ហើយនិងកម្មាភិបាល

មកពីភូមិភាគផ្សេងទៀតផងដែរ"។ ដូច្នេះលោក ហេដឌ័រ តើលោកជាអ្នកសរសេរចំណុចហ្នឹងដែរឬទេ លោក?

[១៣:៤៦:២៦]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ជាការពិតដូច្នោះមែន។

**ប្រធានអង្គជំនុំ៖**

ទំនងជាមិនមានការផ្លាស់ប្តូរនូវរបៀបតាំងសំណួរទេលោកមេធាវី សំណួរដូចជានៅតែដដែល។ ហើយការជំទាស់តវ៉ារបស់លោកនៅក្នុងពេលវេលានៃភាគីម្ខាងទៀតសួរដេញដោល គឺលោកបានមានការបង្ហាញនូវការជំទាស់តវ៉ាច្បាស់លាស់ណាស់ ហើយទំនងជាលោកយល់ច្បាស់អំពីឋានៈរបស់សាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអានចំណុចដែលដកស្រង់ចេញពីសៀវភៅរបស់គាត់ ហើយគ្រាន់តែសួរគាត់ គាត់ជាអ្នកសរសេរ ឬក៏យ៉ាងម៉េច? គ្មានសួរអ្វីក្រៅហ្នឹងនោះទេ គាត់បានឆ្លើយទៅនឹងសំណួរនេះរួចហើយ។ នៅពេលនេះខ្ញុំសួរគាត់កុំឲ្យគាត់ផ្តល់យោបល់មតិទៅលើលោក ឃៀរនិន ក៏ប៉ុន្តែគ្រាន់តែឲ្យគាត់នេះ បញ្ជាក់ថាគាត់អាចផ្តល់ព័ត៌មានអង្គហេតុដោយផ្ទាល់ កុំឲ្យគាត់បញ្ចេញជាការទាយស្មាន ឬបញ្ចេញជាមតិយោបល់តែប៉ុណ្ណោះ។ ថាតើគាត់មានព័ត៌មានណាដែរឬទេ ជាមូលដ្ឋានចំពោះការសរសេរអត្ថបទរបស់គាត់នេះ?

[១៣:៤៧:៥៣]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធានខ្ញុំដូចជាមិនដឹងទេនៅពេលនេះ ថាតើខ្ញុំលើកខ្វះចំណុចណាមួយ ឬក៏វាកើតចេញពីការខ្វះនូវបទពិសោធន៍។ អង្គជំនុំជម្រះបានសម្រេចប្តូនដងរួចមកហើយមកត្រឹមពេលនេះ។ ខ្ញុំសូមពន្យល់ដូច្នេះសាជាថ្មី សៀវភៅមួយក្បាលហ្នឹង ឬក៏អត្ថបទមួយហ្នឹងគឺជាការអត្ថាធិប្បាយរបស់លោក ហេដឌ័រ ទៅលើសៀវភៅរបស់លោក ឃៀរនិន។ អត្ថបទដែលបានបញ្ជាក់អម្បាញ់មិញ គឺអំពីការប្រៀបធៀបរបស់លោក ឃៀរនិន ទៅលើរចនាសម្ព័ន្ធពីភូមិភាគមួយទៅភូមិភាគមួយ។ វាជាការបង្ហាញនូវមតិទស្សនៈថា លោក ឃៀរនិន នោះផ្អែកករណីដែលគាត់ធ្វើការប្រៀបធៀបនេះ ដោយគាត់

យោងទៅលើការប្រៀបធៀបដោយយោង និងការផ្តល់មតិយោបល់របស់គាត់ដោយផ្អែកតាមការបកស្រាយ។ ហើយគាត់បានយោងទៅលើចំណុច ដែលថាវានៅមានចំណុចខ្វះខាតនៅក្នុងមតិយោបល់ដែលគេបានលើកឡើង។

ដូច្នេះហើយចំណុចនេះមិនអនុញ្ញាតទេ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះប្អូនដងរួច មកហើយ។ ហេតុដូច្នេះខ្ញុំសូមជំទាស់ និងធ្វើការសង្កេតជាទូទៅតែម្តង។ ខ្ញុំសង្ឃឹមថា ក្រោយពីខ្ញុំធ្វើសេចក្តីសន្និដ្ឋានរួចហើយ សំណួរភាគច្រើនបំផុត ទោះបីមិនទាំងអស់ក៏ដោយមេធាវីការពារក្តីនៅពេល ដែលគាត់ផ្អែកមូលដ្ឋានលើសៀវភៅហ្នឹង គឺចៀសវាងកុំឲ្យផ្តល់មតិយោបល់ទៅលើអ្វីដែលលោក ឃៀវនិនបានសរសេរ។ ការសួរបែបនេះគឺមិនអាចទទួលយកបាននោះទេ។ ហេតុអ្វីបានជាអ្វីដែលខ្ញុំ លើកឡើងនេះមិនយល់ទៅខាងភាគីម្ខាងទៀត?

[១៣:៤៩:៥៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំធ្វើដូចតាមរបៀបដែលសហព្រះរាជអាជ្ញាធ្វើតែប៉ុណ្ណោះ។ អានចំណុចចេញពីអត្ថបទ សួរសាក្សីឲ្យគាត់បញ្ជាក់ថាតើគាត់ជាអ្នកសរសេរ ឬក៏មិនមែនជាអ្នកសរសេរ។ ហើយឲ្យសាក្សីនេះលើកឡើងថាគាត់មានអង្គហេតុមូលដ្ឋានដែរឬទេ? ខ្ញុំមិនមែនឲ្យខាងសាក្សីនោះអានទេ គឺខ្ញុំគ្រាន់តែអាន ហើយឲ្យសាក្សីបញ្ជាក់តែប៉ុណ្ណោះ ដូចដែលសហព្រះរាជអាជ្ញាធ្លាប់ធ្វើពីមុនដូចគ្នា។

**ប្រធានអង្គជំនុំ៖**

បាទអង្គជំនុំជម្រះផ្តល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសម្រេចលើបញ្ហានេះឲ្យបានច្បាស់លាស់។

[១៣:៥០:៣៨]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះទទួលយកការលើកឡើងរបស់សហព្រះរាជអាជ្ញាដែលអង្គជំនុំជម្រះបានសម្រេចលើបញ្ហាហ្នឹងប្អូនប្រាំដងរួចមកហើយ។ បញ្ហានៅត្រង់នេះគឺថា សម្ភារៈឯកសារដែលលោក ហេដឌ័រ ផ្តល់អត្ថាធិប្បាយទៅលើអត្ថបទនោះ គឺវាមិនពាក់ព័ន្ធចំពោះការសួរដេញដោលរបស់យើងនោះទេ។ ហេតុដូច្នេះសូមកុំសួរសំណួរផ្សេងទៀតផ្អែកលើអត្ថបទនេះអី ដែលទោះក្នុងករណីណាក៏ដោយ យើងដឹងថាគាត់ជាអ្នកសរសេរក្នុងនាមជាអ្នកជំនាញ។ ហើយនៅក្នុងថ្ងៃនេះគាត់មិន

មែនជាអ្នកជំនាញទេ គាត់ជាសាក្សីមកផ្តល់សក្ខីកម្ម ថាតើគាត់បានឃើញ ស្តាប់ឮ និងធ្លាប់ឆ្លងកាត់អ្វីខ្លះ គាត់មិនមែនមកក្នុងនាមជាអ្នកជំនាញនោះទេ។

នេះជាចំណុចដែលអង្គជំនុំជម្រះចង់បាន ហើយសូមកុំឲ្យសួរសំណួរផ្សេងទៀតដែលផ្អែកទៅលើអត្ថបទនេះ។ សូមអរគុណលោកប្រធាន។

[១៣:៥២:០៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** លោក ហេងឌ័រ តើលោកបានធ្វើការស្រាវជ្រាវ ឬក៏លោកបានធ្លាប់សរសេរអត្ថបទណាមួយស្តីអំពីហេតុការណ៍ ដែលកើតឡើងនៅក្នុងភូមិភាគបូព៌ានៅក្នុងឆ្នាំ១៩៧៥ ដែរឬទេ?

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** ជាការពិតខ្ញុំមានឯកសារសម្ភារៈសម្ភាសលើបញ្ហាហ្នឹង។ ខ្ញុំមិនបានសរសេរឯកសារណាមួយនោះទេ តែចំណុចនេះខ្ញុំជឿថា នៅក្នុងអត្ថបទដែលបានលើកឡើងអម្បាញ់មិញ គឺវាជាការបង្ហាញអំពីភូមិភាគហ្នឹងពាក់ព័ន្ធទៅនឹងការផ្តោតសំខាន់លើការស្រាវជ្រាវរបស់ខ្ញុំ។ ការស្រាវជ្រាវនៅក្នុងហ្នឹងគឺអត្ថបទហ្នឹង ហើយសៀវភៅហ្នឹងកំពុងតែនៅសរសេរនៅឡើយទេ។

**ស៖** តើលោកបានធ្វើការស្រាវជ្រាវលើបញ្ហាសន្តិសុខនៅភូមិភាគបូព៌ា ឬក៏លោកបានសួរសំណួរណាមួយពាក់ព័ន្ធទៅនឹងសមាជិកកម្មាភិបាលនៅភូមិភាគបូព៌ាដែរឬទេ?

[១៣:៥៣:៣១]

**ឆ៖** បាទ ខ្ញុំបានធ្វើដូច្នោះមែន។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំបានដែរឬទេ តើការស្រាវជ្រាវដែលលោកបានធ្វើឡើងទាំងអស់នោះ គឺបានផ្តល់ជាព័ត៌មានអ្វីខ្លះដែរ?

**ឆ៖** គឺបានផ្តល់ព័ត៌មានអំពីបញ្ហារចនាសម្ព័ន្ធ និងឋានានុក្រមមន្ទីរសន្តិសុខនៅភូមិភាគបូព៌ា ដែលមានលក្ខណៈស្រដៀងគ្នានៅស្ទើរតែគ្រប់ទីកន្លែងផ្សេងទៀត គឺបានន័យថាមន្ទីរសន្តិសុខភូមិភាគបូព៌ា គឺវាដូចទៅនឹងមន្ទីរសន្តិសុខមជ្ឈិមនៅទីក្រុងភ្នំពេញ ស-២១ នោះដែរ។ ហើយមន្ទីសន្តិសុខនោះ គឺថាជាមន្ទីរសន្តិសុខដែលជាស្ថិតនៅក្រោមការគ្រប់គ្រងមូល ជាចម្បងរបស់ខាងសេនាធិការ។ មន្ទីរសន្តិសុខនៅតាមភូមិភាគដែលមានលេខ ស-៧៩ ស្ថិតនៅក្រោមសេនាធិការរបស់ភូមិភាគបូព៌ា ហើយមន្ទីរសន្តិសុខនេះមានទីតាំងនៅខេត្តព្រៃវែង នៅទីរួមខេត្តព្រៃវែងនោះតែម្តង។

[១៣:៥៥:០៤]

ហើយដូចស-២១ ដែលជាមន្ទីរសន្តិសុខមជ្ឈិមនោះផងដែរ មន្ទីរសន្តិសុខ ស-៧៩ ពីដំបូងគឺធ្វើការងារឃុំឃាំងទៅលើកម្មាភិបាលនៅខាងភូមិភាគបូព៌ា ហើយក្រោយមកៗក៏បានធ្វើការងារលើបញ្ហាកម្មាភិបាលភូមិភាគបូព៌ា។ ហើយនៅក្រោមភូមិភាគនោះក៏មានមន្ទីរសន្តិសុខតាមតំបន់ និងស្រុកផងដែរ។ ករណីនេះក៏ដូចគ្នានៅតាមផ្នែកផ្សេងទៀតនៅក្នុងប្រទេស ដែលយើងឃើញថាមន្ទីរសន្តិសុខទាំងអស់នោះវាមានទំនាក់ទំនងគ្នារវាងមន្ទីរសន្តិសុខស្រុក និងមន្ទីរសន្តិសុខតំបន់ រហូតទៅដល់ថ្នាក់លើ។ បានន័យថាវាពាក់ព័ន្ធទៅនឹងយោធាថ្នាក់ស្រុក ថ្នាក់តំបន់ ហើយនៅក្នុងនោះគឺថាក៏មានរចនាសម្ព័ន្ធដែលជាប្រធាននោះ មានប្រធាន ហើយវាមានលក្ខណៈស្រដៀងៗគ្នា។ នៅក្នុងករណីផ្សេងទៀត យើងឃើញថាប្រធានមន្ទីរសន្តិសុខនេះ គឺជាប្រធានដឹកនាំខាងផ្នែកកងការពារ ដែលគាត់ហ្នឹងធ្វើជាប្រធានមន្ទីរសន្តិសុខនេះតែម្តង នៅតាមទូទាំងប្រទេស។

[១៣:៥៦:៥៣]

នៅពេលដែលយើងមើលទៅលើរចនាសម្ព័ន្ធមន្ទីរសន្តិសុខនេះ មន្ទីរសន្តិសុខថ្នាក់ក្រោមនោះ អាចជាមន្ទីរសន្តិសុខធ្វើការងារលើបញ្ហាប្រជាជនសាមញ្ញ។ និយាយជាទូទៅជាងនេះទៅ សេចក្តីសម្រេចអំពីការកាប់សម្លាប់មនុស្ស ឬការឃុំឃាំងមនុស្សជាចម្បង គឺគេធ្វើឡើងនៅក្នុងថ្នាក់ស្រុក ហើយពេលខ្លះទៅវាអាចពាក់ព័ន្ធនឹងថ្នាក់តំបន់។ ហើយនៅខាងក្រោមរចនាសម្ព័ន្ធទាំងអស់ហ្នឹង យើងឃើញមានសហករណ៍នៅតាមឃុំ ឬក៏គេហៅថាកងឈ្លប និងកងខុទ្ទាម។ ដែលករណីទាំងអស់នេះ គឺថាអ្នកទាំងអស់ហ្នឹង នៅថ្នាក់ក្រោមៗហ្នឹងជាអ្នកចាប់មនុស្ស ហើយពេលខ្លះទៅយកមនុស្សទៅសម្លាប់ចោលផងដែរ។

ខ្ញុំនិយាយជារួមទៅ គឺថារចនាសម្ព័ន្ធនេះ វាអាចជារចនាសម្ព័ន្ធជារួម និងទូទៅ ហើយវាកើតមាននៅតំបន់ និងកន្លែងផ្សេងៗផងដែរ។ ហើយយើងឃើញថានៅថ្នាក់ក្រោមនេះ ថ្នាក់ឃុំហ្នឹងវាមានរចនាសម្ព័ន្ធមន្ទីរសន្តិសុខរបស់គេរហូតឡើងទៅដល់លើ ហើយនៅថ្នាក់ស្រុកៗនោះមានគំរូ និងរចនាសម្ព័ន្ធហ្នឹងវាដូច និងស្រដៀងគ្នា។ តែព័ត៌មានទាំងអស់នេះ ខ្ញុំទទួលបានតាមរយៈការសិក្សាស្រាវជ្រាវហ្នឹង។

**ស៖** នៅក្នុងការសិក្សាស្រាវជ្រាវរបស់លោក តើលោកបានរកឃើញព័ត៌មានបង្ហាញការពិតណាមួយដែរឬទេ ដែលក្នុងនោះបានបង្ហាញថាគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្តកម្ពុជាគឺធ្វើ

ការកាប់សម្លាប់ប្រជាជនចោល ហើយតើគោលនយោបាយនេះ វាមានលក្ខណៈដូចគ្នានៅតាមភូមិភាគបូព៌ា និងភូមិភាគផ្សេងទៀតដែរឬទេ?

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមជំទាស់របៀបដែលសួរសំណួរបែបនេះ។ សំណួរនេះ គឺមានលក្ខណៈទូទៅពេក ដោយថាគាត់សួរថា “នៅក្នុងការស្រាវជ្រាវរបស់លោក”។ លោកប្រធានប្រហែលជាចាំហើយ នៅក្នុងពេលដែលខ្ញុំសួរថ្ងៃទី២ គឺខ្ញុំសួរថានៅក្នុងការស្រាវជ្រាវរបស់លោកសាក្សី គឺមានការជំទាស់ចំនួនពីរធ្វើឡើង។ ហើយលោកប្រធានប្រហែលជានៅចាំហើយ នៅពេលដែលខ្ញុំអានកិច្ចសម្ភាសន៍ដែលលោក ស្ទីវ ហេដឌ័រ ធ្វើឡើង ឬក៏ព័ត៌មានអង្គហេតុការពិតដែលគាត់ទទួលបាននោះ នៅក្នុងការស្រាវជ្រាវរបស់លោកនោះ ខ្ញុំសួរអ៊ីចឹងគឺមានការជំទាស់។ ដូច្នេះ ការដែលសួរដោយមេធាវីការពារក្ដីសួរទូទៅពេក ហើយខ្ញុំសូមជំទាស់ទៅនឹងការសួរបែបនេះ។

[១៣:៥៩:៤៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំរៀបចំសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នៅក្នុងកិច្ចសម្ភាសន៍ដែលលោកបានធ្វើឡើង និងក្រោយពីលោកបានពិនិត្យមើលឯកសារទាំងឡាយរួចមក តើលោកមានព័ត៌មានបង្ហាញការពិតចង្អុលបញ្ជាក់ថា ការកាប់សម្លាប់គឺជាគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្ដកម្ពុជា ហើយគោលនយោបាយកាប់សម្លាប់នៅភូមិភាគបូព៌ាហ្នឹងក៏ដូចជាគោលនយោបាយផ្សេងទៀត នៅតាមកន្លែងផ្សេងទៀតដែរឬទេ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំជឿថា ចម្លើយគឺដូចនៅលើអាវយឺតអ៊ីចឹង បានន័យថា ដូចគ្នាៗ។ ពាក់ព័ន្ធនឹងការអនុវត្តគោលនយោបាយនៅក្នុងលក្ខណៈមួយដែលវាស្របទៅនឹងគោលនយោបាយរបស់មជ្ឈិម។ ដូច្នេះ សាច់ញាតិ ដូចដែលខ្ញុំបានលើកឡើងនៅក្នុងអត្ថបទដែលខ្ញុំបានពិនិត្យមើលសិក្សាស្រាវជ្រាវនោះ សាច់ញាតិហ្នឹង គឺអាចវាជាប់ -- គឺវាអាចមានទំនាក់ទំនងជាប់គ្នាទៅនឹងគោលនយោបាយទូទៅរបស់បក្សកុម្មុយនីស្ដកម្ពុជា ក៏ប៉ុន្ដែវាអាចងាកចេញបន្តិចបន្តួច។ ក៏ប៉ុន្តែវាមានលក្ខខណ្ឌខ្លះ ទោះបីយ៉ាងនេះក៏ដោយ ចម្លើយនោះ គឺថាវាដូចៗគ្នា មានការកាប់សម្លាប់ជាទូទៅ ក៏ប៉ុន្តែកន្លែងផ្សេងទៀតនោះ ក៏មិនមាន

លក្ខណៈធំធេងទូទៅនោះឡើយ។ ការកាប់សម្លាប់នោះ គឺធ្វើឡើងដោយសារហេតុផលដូចគ្នា ហើយមានដំណើរការដូចគ្នា កើតឡើងនៅតាមកន្លែងផ្សេងទៀតនៅក្នុងប្រទេសនេះ។

[១៤:០១:៥៥]

**ស៖** កិច្ចសម្ភាសន៍ដែលលោកមាន ឯកសារដែលលោកបានពិនិត្យមើល តើបានផ្ដល់ព័ត៌មានការពិតដល់លោកដែរឬទេ? នៅខាងភូមិភាគបូព៌ាចំពោះការកាប់សម្លាប់នេះ អ្នកណាជាអ្នកទទួលខុសត្រូវដែរ?

**ឆ៖** ការទទួលខុសត្រូវនេះ ពាក្យហ្នឹងគឺវាធំណាស់ វាធំធេងពេក។ ការពិត ខ្ញុំមានទិន្នន័យក្រោយពីការដែលខ្ញុំធ្វើសម្ភាសជាច្រើនឆ្នាំកន្លងមក។ ហើយទិន្នន័យទាំងអស់នោះ គឺថាបានលើកឡើងឈ្មោះសមាជិករបស់គណៈកម្មាធិការសេនាធិការនៅកម្រិតថ្នាក់ភូមិភាគបូព៌ា។ ឈ្មោះមានក្នុងនោះមានឈ្មោះប្រធាន តំបន់ ស្រុក និងឈ្មោះប្រធានមន្ទីរ ថ្នាក់ស្រុក ថ្នាក់តំបន់។ ទិន្នន័យនោះបានបង្ហាញនៅក្នុងកិច្ចសម្ភាសន៍ ហើយនៅក្នុងករណីឧទាហរណ៍មួយចំនួននោះ បានលើកឡើងថាមានតួនាទីនៅទីនោះផ្លូវការ រួមទាំងនៅទីនោះ មេៗហ្នឹង គឺថាមានអំណាចជាក់ស្ដែង ដោយសារពួកគេហ្នឹងគឺមានតួនាទីផ្លូវការ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ ឆ្លងតាមការកិច្ចសម្ភាសន៍ដែលលោកបានធ្វើឡើង និងឯកសារដែលលោកបានពិនិត្យមើល តើ សោ ភឹម ហ្នឹង បើសិនជាគាត់កាន់តួនាទីនោះ គឺកាន់តួនាទីអីដែរ នៅក្នុងភូមិភាគនុ៎ង?

[១៤:០៣:៣៦]

**ឆ៖** ខ្ញុំគិតថា សញ្ញាណផ្លូវការ រួមមាននៅក្នុងភូមិភាគបូព៌ា គឺគាត់ទទួលខុសត្រូវរួមនៅក្នុងភូមិភាគនោះ។ តាមរយៈកិច្ចសម្ភាសន៍ និងព័ត៌មានទាំងឡាយ និងចម្លើយដែលមិនមែនជាចម្លើយសារភាព ឬឯកសារ យើងនិយាយថាឯកសារទូទៅនោះបានបង្ហាញទៅលើចំណុចនេះ ថាគាត់ទទួលខុសត្រូវរួម។ ពាក់ព័ន្ធទៅនឹងករណីនេះ ក្នុងពាក្យដែលយើងប្រើប្រាស់ទូទៅ គាត់ទំនងជាមានអំណាចកាន់កាប់ថ្នាក់ភូមិភាគ ដោយពាក់ព័ន្ធទៅនឹងបញ្ហាសន្តិសុខ ហើយគាត់ក៏កាន់តួនាទីក្រៅផ្លូវការដែរ នៅថ្នាក់មន្ទីរសន្តិសុខ នៅថ្នាក់មូលដ្ឋាន។ ចម្លើយទាំងឡាយដែលក្រៅ -- ឯកសារទាំងឡាយដែលក្រៅពីចម្លើយសារភាព រួមមានទិន្នន័យ និងសម្ភារៈឯកសារផ្សេងៗ គឺនៅមានបានបង្ហាញចំណុចទាំងអស់នេះ។ ហើយជួនកាលថាគាត់មិនកាន់តួនាទីដូចដែលខ្ញុំលើកឡើងអម្បាញ់មិញនោះទេ។ ការកាប់សម្លាប់ទាំង

ឡាយពីថ្នាក់លើរហូតទៅដល់ថ្នាក់ក្រោម បានន័យថា ការកាប់សម្លាប់ពីកម្មាភិបាលទៅដល់ប្រជាជនសាមញ្ញៗ ការកាប់សម្លាប់ទាំងអស់នោះត្រូវបានសម្រេចដោយគណ:អចិន្ត្រៃយ៍នៅក្នុងភូមិភាគ។ ហើយករណីហ្នឹង គឺវាមិនមែនអ៊ីចឹងទេ នៅភូមិភាគបូព៌ា ហើយនៅតាមភូមិភាគផ្សេងទៀតក៏មិនមែនថា ករណីអ៊ីចឹងវាកើតឡើងដូចគ្នា នូវអ្វីដែលខ្ញុំបានលើកឡើងនោះឡើយ។

[១៤:០៥:៣៦]

**ស៖** តើលោកមានព័ត៌មានអង្គហេតុណាមួយដែរទេ តាមរយ:កិច្ចសម្ភាសន៍ ឬក៏ឯកសារសិក្សាស្រាវជ្រាវទាក់ទងទៅនឹងតួនាទីរបស់កងទ័ពភូមិភាគបូព៌ាក្នុងអំឡុងនៃការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក ឃីត វេយ៉ន័រ៖**

លោកប្រធានខ្ញុំសូមចូលទៅភស្តុតាងរបស់លោក ស្ទីវ ហេដឌ័រ ទាក់ទងទៅនឹងអនុស្សរណ:ដែលអង្គជំនុំជម្រះបានចែងផ្សព្វផ្សាយ ហើយលោកស្រីចៅក្រម ខាតវ៉ាយថ៍ ក៏បានបញ្ជាក់ចំណុចនេះហើយ។

[១៤:០៦:២៨]

ចំណុចអ៊ីម៉ែលចុះថ្ងៃទី៣ ខែកក្កដា សំណួរត្រូវតែសួរស្វែងរកភស្តុតាងពីសាក្សី ឬក៏ភស្តុតាងដែលទទួលបានក្នុងពេលធ្វើការសិក្សាស្រាវជ្រាវ។ នេះគឺបង្កើតបានជាមូលដ្ឋាន ឬបង្កើត ដែលនាំឱ្យសរសេរចេញជាសៀវភៅ ឬផ្សាយជាអត្ថបទផ្សេងៗ។ ខ្ញុំគិតថា សំណួរបួនចុងក្រោយអត់មានយោងទៅលើផ្នែកណាមួយនៃសៀវភៅណាមួយ គឺមិនមានយោងទៅលើសៀវភៅ ឬក៏សម្រង់ណាមួយដែលនិពន្ធឡើងដោយលោក ហេដឌ័រ នោះឡើយ។

តាមរយ:ចម្លើយចុងក្រោយ គឺថាលោក ហេដឌ័រ បាននិយាយអំពីឯកសារ មិនមែនជាឯកសារសារចម្លើយសារភាព។ ហេតុដូច្នេះឯង បានជាសំណួរនេះ គឺថាត្រូវតែរៀបចំឡើងឱ្យបានល្អិតល្អន់។ ទាក់ទងទៅនឹង សោ ភឹម យើងមើលទៅឃើញថា គាត់អនុវត្តអំណាចទូទៅ កាលណាយើងប្រើឃ្លាថា បើនិយាយជារួម គឺហាក់បីដូចជាភស្តុតាងនេះបានឡើងតាមរយ:គំនិតយោបល់យល់ឃើញរបស់គាត់។

ដូច្នេះខ្ញុំសូមជំទាស់ទៅនឹងការយោង ឬកិច្ចសម្ភាសន៍ណាដោយមិនមានការយោងជាក់លាក់ទៅឯកសារណាមួយដែលនិពន្ធឡើងដោយលោក ស្ទីវ ហេដឌ័រ។

[១៤:០៨:២០]

ហេតុផលរបស់ខ្ញុំ គឺខ្ញុំមានការពិនិត្យពិច័យណាស់ថា រាល់សំណួរដែលខ្ញុំសួរទៅហ្នឹង គឺថាមានការផ្ដើមដោយយោងទៅលើសម្រង់នៃសៀវភៅដែលលោក ស្ទីវ ហេដឌ័រ គាត់បាននិពន្ធ។ ហេតុដូច្នេះហើយ -- បន្ទាប់មកទើបខ្ញុំសួរសំណួរបន្ថែម តើមានឯកសារបានមកពីការសម្ភាស ឬក៏ព័ត៌មានអង្គ-ហេតុណាមួយ គឺថាត្រូវតែសួរចាប់ផ្ដើមពាក់ព័ន្ធទៅនឹងភស្តុតាងដែលទទួលបានតាមរយៈកិច្ចសម្ភាសន៍របស់គាត់។

ខ្ញុំយល់ថា ហេតុដូចម្ដេច ខ្ញុំមិនបន្ទោសមេធាវីការពារក្ដីចំណុចនេះ។ ប៉ុន្តែនៅចំណុចចាប់ផ្ដើមនេះ គឺត្រូវតែសួរទៅដល់លោក ស្ទីវ ហេដឌ័រ គឺបើមិនដូច្នេះទេ គឺថានឹងទទួលបាននូវព័ត៌មានជាគំនិតយោបល់របស់គាត់ដែលជាហានិភ័យមួយគួរជៀសវាង។ ពេលណាយើងយោងទៅលើឯកសារជាក់លាក់ណាមួយសំដៅទៅលើសៀវភៅរបស់គាត់ បើមិនដូច្នេះទេគឺថា លោកគឺកំពុងតែគឺថា ហាក់ដូចជាច្របាច់លោក ស្ទីវ ហេដឌ័រ តាមរយៈការណែនាំរបស់លោកផ្ទាល់ចំពោះសៀវភៅដែលគាត់និពន្ធនេះ។

[១៤:០៩:៤៦]

ប៉ុន្តែសម្រាប់មួយសៀលនេះតែម្ដង ដើម្បីឲ្យការតាំងសំណួរទៅជឿនលឿននោះ គឺថាគួរតែជៀសវាង បើសិនណាជាការតាំងសំណួរទាំងឡាយណាដោយមិនមានការយោងទៅលើឯកសារណាមួយ។ បើពុំនោះទេ គឺថាវានឹងជាការសួរយកព័ត៌មានតាមរយៈគំនិតយោបល់។ ដូច្នេះ ខ្ញុំស្នើសុំឲ្យលោក វ៉ិចទ័រ កូប៉េ ធានាឲ្យប្រាកដថាការតាំងសំណួររបស់គាត់ត្រូវតែភ្ជាប់ទៅនឹងសម្រង់ទៅនឹងសៀវភៅដែលលោក ស្ទីវ ហេដឌ័រ ជាអ្នកនិពន្ធឡើងនេះ ឬក៏ឯកសារទាំងឡាយណាដែលគាត់ប្រមូលបាន។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សៀវភៅរបស់លោក ស្ទីវ ហេដឌ័រ ទេ។ ប៉ុន្តែយើងបកស្រាយជូនសាធារណជនថាតើមានអ្វីកំពុងតែកើតឡើងនេះ តាមរយៈការជំទាស់របស់សហព្រះរាជអាជ្ញានេះ សហព្រះរាជអាជ្ញាគឺថាខ្ញុំស្នើសុំថា ឲ្យជៀសវាងការជំទាស់តាមរយៈ បើអាចធ្វើទៅបានឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ យើងកំពុងតែនិយាយពីបញ្ហាកើតឡើងពី៧៥ ទៅ ៧៩ គឺកើតឡើងនៅភូមិភាគបូព៌ា។

[១៤:១១:០៧]

ខ្ញុំសួរសំណួរទាក់ទងទៅនឹងការសិក្សាឯកសារ និងកិច្ចសម្ភាសន៍ដែលសាក្សីបានធ្វើឡើងសួរអំពីអ្វី ដែលគាត់អាចជម្រាបមកយើងបានក្នុងឋានៈគាត់ជាសាក្សី។ ដូច្នេះការជំទាស់នេះ មិនមែនជាបញ្ហាបច្ចេកទេសអ្វីនោះទេ គឺខ្ញុំកំពុងតែសាកសួរចំពោះអ្វីដែលកើតមានឡើងនៅភូមិភាគបូព៌ា។

**លោក ឃីត វេយ៍ន័រ៖**

លោកប្រធាន ខ្ញុំសូមឆ្លើយទៅវិញយ៉ាងសង្ខេបទេ។ មេធាវីការពារក្ដីបាន -- មិនបានបង្ហាញទៅដល់សាធារណជនហ្នឹង។ យើងមិននិយាយពីរឿងនយោបាយទេ យើងកំពុងតែនិយាយអំពីភស្តុតាង។ តើកំពុងតែនិយាយកម្មវត្ថុ បើសិនណានិយាយកម្មវត្ថុផ្សេងគ្នា ខ្ញុំនឹងជំទាស់ទៀត។ ប៉ុន្តែមេធាវីការពារក្ដីត្រូវបញ្ជាក់ឲ្យច្បាស់ថា មិនត្រូវកំណត់សេចក្ដីណែនាំណាមួយ សេចក្ដីសម្រេចណាមួយដាក់ចេញយ៉ាងបែបនេះឲ្យសាធារណជនស្ដាប់ឮ ធ្វើខ្លួនគាត់ជាអ្នកសម្រេចនោះទេ។

[១៤:១២:២៣]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៥:១៣]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបញ្ជាក់ពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះលើវិធាននៃការពិភាក្សាដេញដោលនាពេលនេះ ដែលកើតមានបញ្ហាម្ដង ហើយម្ដងទៀត។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសូមលើកឡើងវិញជាម្ដងទៀតចំពោះសេចក្ដីសម្រេចជាច្រើនទៅលើប្រធានបទនេះ។ ហើយលោក កូប៉េ លោកបញ្ជាក់ថា សេចក្ដីសម្រេចនេះគឺវាពាក់ព័ន្ធទៅនឹងការធានាថា សាក្សីរូបនេះផ្ដល់សក្ខីកម្មក្នុងឋានៈជាសាក្សី មិនមែនក្នុងឋានៈជាអ្នកជំនាញទេ។ លោកគឺថាតែងតែដឹកសាកសួរអំពីបញ្ហានេះនៅពេលដែលលោក ហេដឌ័រ ចាប់ផ្ដើមផ្ដល់សក្ខីកម្មរបស់គាត់ ហើយអង្គជំនុំជម្រះបានយល់ស្របជាមួយលោកចំពោះប្រធានបទនេះ។

សូមអនុវត្តឲ្យស្របទៅនឹងសេចក្ដីសម្រេច ដែលអង្គជំនុំជម្រះធ្វើឡើងតាមរយៈអ្វីដែលសហព្រះរាជអាជ្ញាទើបលើកឡើងអម្បាញ់មិញនេះ។ ប្រសិនណាបើលោកមិនអាចធ្វើដូច្នេះទេ ហើយបញ្ហា

នេះលោកប្រធានស្នើសុំឲ្យខ្ញុំបញ្ជាក់ថា ដោយសារតែសំណួរជាច្រើនមិនមានការពាក់ព័ន្ធ បើលោកសួរសំណួរមិនពាក់ព័ន្ធបន្តទៅទៀតនោះ គឺថានឹងបញ្ជូនតួនាទីនេះទៅមេធាវីលោក ខៀវ សំផន ហើយ។

[១៤:១៧:១៦]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំព្យាយាមសួរម្តងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំយោងទៅលើអត្ថបទមួយដែលលោកសរសេរនេះគឺ "ការវាយតម្លៃឡើងវិញអំពីតួនាទីរបស់មេដឹកនាំខ្មែរក្រហម និងកម្មាភិបាលនៅថ្នាក់មូលដ្ឋានអំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម"។ ទស្សនៈបែបប្រៀបធៀបនៅកម្ពុជា។ ខ្ញុំគិតឃើញថាលោកមានឯកសារហើយគឺ--

**អ្នកបកប្រែ៖**

លោកប្រធានសូមឲ្យគាត់បញ្ជាក់លេខ ERN ម្តងទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទលោក ហេដឌ័រ ខ្ញុំយោងទៅទំព័រក្នុងសៀវភៅរបស់លោក។ ERN ជាភាសាអង់គ្លេស 00661990 ជាពិសេសខ្ញុំយោងទៅលើលេខជើងទំព័រ ERN ជាភាសាបារាំង 00792948, ខ្មែរ 00830815 ដល់ 16 ទាំងអស់នេះគឺទាក់ទងទៅនឹងលេខជើងទំព័រ២០៧។ បាទ ខ្ញុំសូមអានឲ្យលោកស្តាប់តែម្តងចំពោះជើងទំព័រ២០៧ ខ្ញុំជឿជាក់ថាមិនមានការជំទាស់ទេ គឺខ្ញុំសូមអានលេខជើងទំព័រ២០៧។ ខ្ញុំសូមរំឭកទៅដល់អង្គជំនុំជម្រះថា ខ្ញុំយោងទៅលើឯកសារដែលដាក់ជាសាធារណៈហ្នឹងគឺឯកសារនេះមានជាសាធារណៈហើយ។ "ភស្តុតាងផ្សេងៗជាប់ពាក់ព័ន្ធទៅនឹង ហេង សំរិន ហើយនិងឧក្រិដ្ឋកម្មសង្គ្រាម ក្នុងការសម្លាប់ជនស៊ីវិលប៉ុណ្ណឹង ដែលប្រព្រឹត្តឡើងដោយក្រោមការបញ្ជារបស់គាត់ក្នុងពេលឆ្លងព្រំដែនចូលទៅកាន់ប្រទេសវៀតណាមនៅក្នុងឆ្នាំ១៩៧៧"។ តើលោកយោងទៅសៀវភៅផ្សេងទៀត ឬក៏យ៉ាងណា នៅទំព័រ១៤២, ១៤៣ហ្នឹង? តើលោកជាអ្នកសរសេរលេខជើងទំព័រនេះឬក៏យ៉ាងណា?

**ឆ៖** បាទ ។

[១៤:២០:០១]

**ស៖** តើលោកអាចពន្យល់បាន ពន្យល់បន្ថែមបានទេចំពោះលេខជើងទំព័រនេះ?

**ផ៖** បើខ្ញុំចាំមិនច្រឡំទេ នៅពេលនុ៎ង គឺខ្ញុំយោងទៅលើឯកសារសម្ភាសមួយចំនួនហើយប្រហែលជាយោងទៅលើឯកសារចម្លើយសារភាពខ្លះផងដែរ។

**ស៖** លោកដឹងថាឯកសារចម្លើយសារភាពមួយណា ឬក៏ឯកសារសម្ភាសមួយណាដែរ?

**ផ៖** *(មីក្រូហ្វូនមិនទាន់ដំណើរ)*

**ស៖** *(គ្មានការបកប្រែ)*

**ផ៖** ខ្ញុំគិតថា ឯកសារដែលពិនិត្យឡើងវិញនេះគឺត្រូវការវាយអក្សរពុម្ពសាជាថ្មីម្តងទៀត។ ដូច្នេះខ្ញុំទុកមួយអន្លើសិន ហើយខ្ញុំព្យាយាមគិតមើល តើខ្ញុំយោងទៅលើអត្ថបទមួយណាចំពោះលេខយោងជើងទំព័រនេះ។

**ស៖** ដូច្នេះ ពេលនេះគឺថាលោកមិនអាចបញ្ជាក់បានថា តើកិច្ចសម្ភាសន៍ជាក់លាក់មួយណា ឯកសារជាក់លាក់មួយណាទេ ដែលលោកយោងនៅត្រង់ហ្វូតណូតនេះ អ៊ីចឹងមែនទេ?

[១៤:២២:០៩]

**ផ៖** បើសិនណាជាយើងមើលលេខហ្វូតណូតហ្នឹងតាមលំដាប់លំដោយហ្នឹងមក មើលថយមកក្រោយបន្តិចមក វាអាចបង្ហាញបាន។

**ស៖** លោក ហេដឌ័រ ខ្ញុំស្នើសុំឲ្យលោកពិនិត្យមើលនៅពេលយើងឈប់សម្រាកបានទេ?

**ផ៖** ខ្ញុំគិតថា គឺទំព័រ៥៣ និង៥៤ នៃឯកសារដែលបានពិនិត្យឡើងវិញនេះ។ ចំណុចនេះគឺជាផ្នែកនៃឯកសារទាក់ទងទៅនឹងវៀតណាម អង្គភាពដែលពាក់ព័ន្ធទៅនឹងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ទៅលើជនជាតិវៀតណាម ហើយនិងទិន្នន័យពិនិត្យឡើងវិញដែលបញ្ជាក់ថា ហេង សំរិន គឺជាអ្នកទទួលខុសត្រូវទៅលើអង្គភាពមួយនុ៎ង។ ហើយបើយើងយកអង្គហេតុទាំងអស់ហ្នឹងយកមកដាក់បញ្ចូលគ្នា គឺថាគាត់ជាមេបញ្ជាអង្គភាពដែលបញ្ជាការប្រយុទ្ធនៅពេលនុ៎ង។ ហើយក៏វាមានចម្លើយសារភាព យោងទៅលើចម្លើយសារភាពផងដែរ។

[១៤:២៤:២០]

ហើយបានបន្តទៅទំព័រពីរបីទំព័រខាងមុខទៀត រហូតទៅដល់ទំព័រ៥៨។ អ៊ីចឹងខ្ញុំមិនច្បាស់ទេ មិនអាចបង្ហាញឲ្យច្បាស់ ថាតើឯកសារមួយណាដែលយកមកយោងពិតប្រាកដចំពោះនេះ ឯកសារជំពូកសៀវភៅដែលបានពិនិត្យឡើងវិញក្នុងការ -- ឯកសារដែលបានពិនិត្យឡើងវិញនេះ។ ខ្ញុំយល់ឃើញថា ទិន្នន័យនោះ គឺថាខ្ញុំនៅតែប្រកាន់ភាពអព្យាក្រឹតចំពោះសំណួរនោះ ខ្ញុំមិនដឹងថា គេហៅថាវាជាភស្តុតាង

ឬក៏យ៉ាងណានោះទេចំពោះទិន្នន័យហ្នឹង។ ទិន្នន័យ គឺក៏យើងទទួលបានតាមរយៈការបោះពុម្ពផ្សាយឯកសារវៀតណាម និងកិច្ចសម្ភាសន៍ជាបន្តបន្ទាប់ដែលខ្ញុំធ្វើឡើង។ ដូច្នេះខ្ញុំមិនអាចប្រកាន់ថា ខ្ញុំយោងអ្វីពិតប្រាកដទៅលើទិន្នន័យខាងដើម និងទិន្នន័យខាងក្រោយនោះទេ។

**សៈ** ខ្ញុំសូមឲ្យលោកយកចិត្តទុកដាក់ទៅលើខ្លឹមសារមួយចំនួននៅក្នុងសៀវភៅ ប៉ែន យៀវនិន។ ឯកសារ E3/1593 ខ្ញុំមានឯកសារមួយច្បាប់ជូនទៅលោក ហើយខ្ញុំសូមអានជូនលោកស្តាប់។ ខ្ញុំសូមអានសម្រង់ពីរបីដោយចាប់ផ្តើមឡើងជាមួយនឹង សម្រង់ទី១ ចេញពីសៀវភៅនេះ អង់គ្លេសគឺ 0067 8528 ដល់ 29, បារាំង 00638799, ខ្មែរ 0067460 *(ស៊ីក)* គឺត្រង់ទំព័រ៦៧ នៃសៀវភៅរបស់ ប៉ែន យៀវនិន។

**លោក វ៉ិចទ័រ កូប៉េះ**

បាទ លោកប្រធាន ខ្ញុំសូមបង្ហាញឯកសារនេះជូនទៅសាក្សី--

**ប្រធានអង្គជំនុំ៖**

ផ្អាកបន្តិចសិន១!

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:២៧:៣៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយថា មិនអនុញ្ញាតឲ្យលោកមេធាវី នួន ជា ផ្អែកលើសៀវភៅនិពន្ធរបស់ ប៉ែន យៀវនិន មកសួរដេញដោលសាក្សីរូបនេះទេ។ ហើយបានរំឭកលោកទៀតថា ប្រសិនបើលោកទំនងមិនមានសំណួរសារធាតុសំខាន់ៗឯណា ដែលមានប្រយោជន៍ក្នុងប្រឹងប្រែងដើម្បីការពារកូនក្តីរបស់លោកទេ នោះអង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន ដើម្បីមានឱកាសក្នុងការបន្តការតាំងសំណួរ។ ពីព្រោះលោកមិនបានប្រើប្រាស់ពេលវេលាដ៏មានប្រសិទ្ធភាពនូវពេលវេលាដែលអង្គជំនុំជម្រះចែកឲ្យទេ។ ហើយបញ្ជាក់ច្បាស់ថា ដោយសាររបៀបសួរដេញដោលរបៀបនេះ ដែលប្រើប្រាស់ពេលវេលាខ្ជះខ្ជាយ ហើយដោយមិនមានប្រសិទ្ធភាពនេះ គឺអង្គជំនុំជម្រះមិនផ្តល់ពេលវេលាឲ្យទេ ហើយបើចាំបាច់អង្គជំនុំជម្រះនឹងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន នាពេលឥឡូវនេះ។

**លោក វ៉ិចទ័រ កូប៉េះ**

អ៊ីចឹងមានន័យថាគឺអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យខ្ញុំផ្ញើ -- ប្រើប្រាស់សៀវភៅ ប៉ែន យៀវនិន ដើម្បីសួរបញ្ហាអង្គហេតុមួយចំនួនទៅកាន់សាក្សីរូបនេះទេឬ?

ខ្ញុំដូចជាកំពុងតែច្របូកច្របល់លោកប្រធាន កំពុងច្រឡំ។ នេះជាសៀវភៅរបស់ ប៉ែន យៀវនិន សហព្រះរាជអាជ្ញាសួរសំណួរមួយចំនួនទាក់ទងទៅនឹងសៀវភៅនេះ។ ហើយខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងព័ត៌មានអង្គហេតុដែលចេញពីសៀវភៅនេះ ដើម្បីឲ្យសាក្សីគាត់បញ្ជាក់ថាតើវាស៊ីសង្វាក់ ឬក៏អត់ អំពីព្រឹត្តិការណ៍ដែលកើតឡើងនៅឆ្នាំ១៩៧៥ ចំពោះកិច្ចសម្ភាសន៍របស់គាត់ទាក់ទងទៅនឹងភូមិភាគនានា។ ដូច្នេះមានន័យថាខ្ញុំ គឺមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់សៀវភៅ។ អ៊ីចឹងថាតើខ្ញុំសួរសាក្សីដោយរបៀបណា?

[១៤:២៩:៥២]

តាមខ្ញុំយល់ គឺថាខ្ញុំអាចស្រង់ព្រឹត្តិការណ៍មួយនៅក្នុងខែឧសភា ៧៥ ដើម្បីសួរទៅសាក្សី។ ថាតើសាក្សីខ្លួនគាត់ផ្ទាល់នេះ មានការដឹងឮអំពីព័ត៌មានអង្គហេតុតាមរយៈកិច្ចសម្ភាសន៍ ដែលខ្ញុំយល់ឃើញថាវាស៊ីសង្វាក់គ្នា។ អ៊ីចឹងមានន័យថាមិនត្រូវសួរអំពីគំនិតយោបល់ មិនត្រូវសួរសៀវភៅរបស់ ប៉ែន យៀវនិន មិនអាចប្រើប្រាស់សៀវភៅនេះបានទេ ជាពិសេសខ្ញុំសួរជាក់លាក់ទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥។ សំណួរទាក់ទងទៅនឹងកិច្ចប្រជុំនៅថ្ងៃទី២០ ខែឧសភា ៧៥ ដែលជាកម្មវត្ថុ។ ខ្ញុំគិតឃើញថា សហមេធាវីនាំមុខក៏មានការសួរសំណួរបែបនេះដែរ។ ដូច្នេះឥឡូវនេះ ខ្ញុំកំពុងតែបាត់ដានហើយ លោកប្រធាន ខ្ញុំច្របូកច្របល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៤:៣០:៥៤]

**លោក ឃីត រស្មីន័រ៖**

ខ្ញុំគ្រាន់តែបញ្ជាក់នៅពេលខ្ញុំសួរលោក ស្ទីវ ហេដឌ័រ អំពីឯកសាររបស់លោក ប៉ែន យៀវនិន។ ខ្ញុំយោងថា “តើ ប៉ុល ពត នេះ គាត់មកកាន់អំណាចដោយរបៀបណា?” ហេតុផលដែលខ្ញុំយោងទៅសៀវភៅហ្នឹង គឺលោក ហេដឌ័រ ខ្លួនគាត់ផ្ទាល់គឺបានយោងទៅជើងទំព័រមួយរបស់លោក ប៉ែន យៀវនិន។ ប៉ុន្តែចំពោះមេធាវីការពារក្តី ខ្ញុំទទួលស្គាល់ថាមិនមែនគ្រប់ករណីទាំងអស់នោះទេ។ ខ្ញុំសួរសំណួរទូទៅ

ទៅលើលោក ហេងឆ័រ អំពីក្រចេះ នៅឆ្នាំ១៩៧៣ ដោយយោងទៅលើសៀវភៅរបស់លោក ហេងឆ័រ នេះ គឺជាឧទាហរណ៍តែពីរដែលខ្ញុំបានលើកឡើងនោះ។ ខ្ញុំមិនបានជំទាស់ទាំងស្រុងនោះទេ បើសិនណាមានឧបសម្ព័ន្ធណាមួយដែលលោក កូប៉េ គាត់លើកឡើងបញ្ហាហ្នឹងយកមកសាកសួរ គឺខ្ញុំសម្រាប់ផ្នែករបស់ខ្ញុំ គឺថាសម្រាប់ផ្នែករបស់ខ្ញុំ បើសួរដូចខ្ញុំ គឺមិនជំទាស់ទេ។

[១៤:៣១:៥៨]

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៣:១០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

លោក កូប៉េ អង្គជំនុំជម្រះធ្វើអន្តរាគមន៍ពីមុនរួចមកហើយ។ នេះមិនមែនជាលក្ខណៈមួយដែលលោកសួរសំណួរទៅលោក ហេងឆ័រ នោះទេ។ ប៉ុន្តែវាជាការពន្យល់ជាបន្តបន្ទាប់របស់លោកទៅវិញទេ ដែលវានាំឲ្យមានការកែប្រែនូវមូលដ្ឋានមួយចំនួននៃការតាំងសំណួររបស់លោកនោះ។ លោកមានសិទ្ធិតាំងសំណួរទៅកាន់សាក្សី គឺសំណួរទាក់ទងទៅនឹងអង្គហេតុ មិនឲ្យសួរឲ្យសាក្សីផ្តល់ជាគំនិតយោបល់របស់សាក្សីទៅលើអ្នកដទៃទៀតនោះទេ។ បើសិនណាលោកអាចគ្រប់គ្រងរបស់លោកនៅក្នុងរង្វង់អ៊ីចឹងបាន គឺលោកអាចតាំងសំណួរទៅកាន់លោក ហេងឆ័រ បានហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអត់ទាន់បានសួរសំណួរផង លោកស្រីចៅក្រម។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

ប៉ុន្តែលោកកំពុងតែបាត់បង់ពេលវេលារបស់លោកយ៉ាងច្រើន។ ដូច្នេះលោកធ្វើម៉េចៗឲ្យលោកតាំងសំណួរស្ថិតនៅក្នុងរង្វង់ហ្នឹងទៅ?

[១៤:៣៤:២៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ERN ជាភាសាអង់គ្លេស 00678529, បារាំង 00638799, ខ្មែរ 0063460 *(ស៊ីក)*។ ចំណុចនេះ គឺទាក់ទងទៅនឹង -- លោក ហេងឆ័រ តើលោកមានឯកសារនេះហើយឬនៅ?

បាទខ្ញុំ--

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីលោកមេធាវី យកទៅជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** លោក ហេដឌ័រ គឺទំព័រ៦៧។ "ហេង សំរិន កើតនៅថ្ងៃទី -- កើតនៅឆ្នាំ១៩៣៤"។ បាទ ខាងក្រោមមកទៀតត្រង់កថាខណ្ឌដែល សូមដកស្រង់ "គាត់ជាមេ មុនដំបូងគាត់គឺជាមេបញ្ជាការកង អនុសេនាតូច ក្រោយមកឡើងអនុសេនាធំ នៃកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជា។ គាត់បានមកប្រយុទ្ធនៅ អ្នកលឿង ដែលមិនបាន -- កងទ័ពរបស់គាត់មិនដើរតាមមាគ៌ារបស់ខាងមជ្ឈិម"។

នេះជាព័ត៌មានអង្គហេតុទាក់ទងទៅនឹងសារនេះ។ ដោយមិនត្រូវពន្យល់ថា លោកយល់ឃើញថា អ៊ីចេះ ថាដូច្នោះនោះទេ។ សូមឲ្យបង្ហាញឲ្យបានស៊ីសង្វាក់ទៅនឹងសារនេះ។

[១៤:៣៦:៥៨]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** បាទ ជារួមបាទ។ ខ្ញុំកំពុងតែនឹកឃើញ ខ្ញុំច្បាស់ថា កងវរសេនាធំហ្នឹង គឺត្រឹមត្រូវហើយ។ វាគឺថា ជាកងវរសេនាធំ យើងអាច វាស្ថិតនៅក្នុងរង្វង់រចនាសម្ព័ន្ធរបស់លេខាបក្ស មិនមែនជាប្រធាន អង្គភាពទេ។ តាមធម្មតា គឺអនុប្រធានអង្គភាពដែលជាមេបញ្ជាការ។ បាទ ប៉ុន្តែបើនិយាយរួម គឺវាស្រប គ្នាទៅនឹងអ្វីដែលខ្ញុំបានសម្ភាសទៅ ហើយវាស៊ីសង្វាក់គ្នាទៅនឹងឯកសារដែលមិនមែនជាឯកសារចម្លើយ សារភាពផងដែរ។

**ស៖** បាទ លោក ហេដឌ័រ ខ្ញុំសូមបន្តទៅទំព័រ៣១ នៃសៀវភៅដែលនេះ។ ERN ជាភាសា អង់គ្លេស 00678510, បារាំង 00638758, ខ្មែរ 00637406។ បាទ ខ្ញុំសូមអានខ្លឹមសារត្រង់នេះដូច តទៅ សូមដកស្រង់៖ "ហេង សំរិន ត្រូវបានបញ្ជាឲ្យបញ្ជូនកងទ័ពរបស់គាត់ ដើម្បីវាយប្រយុទ្ធសម្រុក មកកាន់ទីក្រុងភ្នំពេញ។ បាទគាត់ដឹកនាំអង្គភាពកងទ័ពភូមិភាគបូព៌ា គឺមានវរសេនាធំ៣៤, ១៦៤ ដែល ត្រូវពង្រាយនៅទិសខាងកើតនៃទីក្រុងភ្នំពេញ មានកងពលរបស់ ចាន់ ចក្រី។ ចាន់ ចក្រី ជាមេបញ្ជាការ កងពល ហេង សំរិន គឺជាអនុមេបញ្ជាការកងពល ហើយក្នុងនោះក៏មាន ហេង ថាល ក៏វាយប្រយុទ្ធ នៅភាគខាងកើតនៃទន្លេមេគង្គផងដែរ។ ហើយក្នុងនោះក៏មានកងម៉ារីន ដែលស្ថិតនៅក្រោមមេបញ្ជាការ

មួយឈ្មោះ ឈៀន។ មេបញ្ជាការកងភូមិភាគបូព៌ានេះ គឺស្លៀកឯកសណ្ឋានខុសពីកងទ័ពកុម្មុយនីស្តដទៃទៀត ហើយគឺជាអ្នកដែលមាននិន្នាការនិយមស៊ីហានុ"។

សូមដក -- ទាក់ទងទៅនឹងបញ្ហាដែលលោកឡើងនៅក្នុងសម្រង់នេះ តើតាមការសិក្សាស្រាវជ្រាវរបស់លោក កិច្ចសម្ភាសន៍របស់លោក និងឯកសារដែលមានភស្តុតាងព័ត៌មាន តើលោក -- សូមលោកបញ្ជាក់ត្រង់ចំណុចនេះបន្តិច?

[១៤:៤០:០៣]

**ឆ៖** បាទ ខ្ញុំអាចឆ្លើយថា ខ្លះអាចឆ្លើយថា "បាទ" ឯកសារខ្លះអាចឆ្លើយថា "ទេ"។ ខ្ញុំមិនដឹងថាតើព័ត៌មានរបស់ខ្ញុំ វាមិនដឹងថាតើគេ កងពលលេខ១ បានផ្តល់អំណាចហ្នឹងទៅឲ្យកងវរសេនាធំ ឬក៏យ៉ាងណានោះទេ។ លេខាកងវរសេនាធំលេខ១ហ្នឹងគឺ ចាន់ ចក្រី ហើយបងប្រុសរបស់ ហេង សំរិន ធី-អេ-អិល គឺឈ្មោះ ប៉ាល់ *(ស៊ីក)* មិនមែន ថាល់ ទេ។ គាត់មិនមែនជាមេបញ្ជាការកងទ័ពទេ គាត់ជាលេខា ហើយតាមការចាំរបស់ខ្ញុំគឺថា កងពលលេខ៣ ប្រហែលជាអង្គភាពខ្លះនៃកងពល៣ ពាក់ព័ន្ធក្នុងការវាយសម្រុកចូលមកកាន់ទីក្រុងភ្នំពេញ។ ប៉ុន្តែភាគច្រើននៃកងពលលេខ៣ ត្រូវបានចាត់តាំងឲ្យឈរនៅជើងទីរួមខេត្តស្វាយរៀង ដើម្បីទៅឲ្យគឺថារឹបអូសយកទីរួមខេត្តស្វាយរៀងតែម្តង។ ដូច្នេះ និយាយជារួមទូទៅគឺ--

**ស៖** បាទបន្តដកស្រង់ពីរចំណុចទៀត។ ឥឡូវនេះគឺយើងនៅត្រង់ទំព័រ៥៥ និងទំព័រ៥៧--

[១៤:៤២:០២]

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់លោកមេធាវី!

សូមអញ្ជើញលោក ស្ទីវ!

**លោក ស្ទីវ ហេដឌ័រ៖**

--ខ្ញុំកំពុងតែពាក់ព័ន្ធសំណួរទាក់ទងទៅនឹងរចនាសម្ព័ន្ធ ខ្ញុំមិនយល់ស្របទាំងស្រុងទៅលើឃ្លាចុងក្រោយដែលថាកងពលនៃភូមិភាគបូព៌ា គឺបង្ហាញខ្លួនខុសពីអង្គភាពដទៃទៀតដោយសារខ្លួនមានលក្ខណៈ: វាមានអង្គភាពរបស់ភូមិភាគនោះ គឺថាវាមានបញ្ហាចម្រុះគ្នាតែម្តង។ នៅក្នុងចំណោមកងពលដែលវាយចូលមកភ្នំពេញពីភូមិភាគនីមួយៗ គឺទទួលការចាត់តាំងជាក់លាក់ ហើយត្រូវឲ្យគ្រប់គ្រងអង្គភាពជាក់លាក់។ អង្គភាពខ្លះត្រូវបញ្ជាឲ្យសម្លាប់ អង្គភាពខ្លះត្រូវបញ្ជាឲ្យប្រមូលជយភណ្ឌ ហើយអង្គភាពខ្លះត្រូវ

បានចាត់តាំងឲ្យល្បាតចុះឡើងៗ គឺថាវាមានបែបបទខុសៗគ្នា ដោយយោងទៅតាមភូមិភាគនីមួយៗ។ កងពលប្រហែលជាពីរកងពលកន្លះ ឬក៏រហូតទៅដល់បីកងពល គឺត្រូវបញ្ជាឲ្យវាយសម្រុកចូលមកទីក្រុងភ្នំពេញ។ គឺវាមានលក្ខណៈខុសគ្នារវាងអង្គភាពមួយទៅអង្គភាពយ៉ាងដូច្នេះដែរ មិនមែនយោងទៅតាមភូមិភាគ ឬក៏កូនចៅរបស់ខ្លួនទេ គឺអាស្រ័យទៅលើលេខាភូមិភាគជាអ្នកកំណត់ ជាអ្នកប្រគល់ភារកិច្ចនេះឡើង។

[១៤:៤៣:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទីចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបីប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រងចាំសម្រាប់សាក្សី នៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបីនិងប្រាំនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៧ នាទី)*

[១៥:០៧:២៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ស៊ីវ ហេងឆ័រ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ទាក់ទងទៅនឹងសម្រង់ដែលខ្ញុំបានដកស្រង់ជាចុងក្រោយចេញពីសៀវភៅរបស់ប៉ែន ឃៀរនិន។ ខ្ញុំយោងទៅលើទំព័រ៥៥នៃសៀវភៅ -- ពីទំព័រ៥៥ទៅ៥៧ ERN ជាភាសាអង់គ្លេស

00678522, បារាំង 00638784 ដល់ 85, ខ្មែរ 00637441 ដល់ 442។

បាទខ្ញុំសូមអានកថាខណ្ឌទី១ ដូចតទៅ ជំពូកទាក់ទងទៅនឹងសមាជថ្ងៃទី២០ ឧសភា "មន្ត្រីយោធា និងស៊ីវិលទាំងអស់នៃរបបថ្មី ត្រូវបានហៅឲ្យចូលប្រជុំនៅថ្ងៃទី២០ ឧសភា ៧៥ មានតំណាងមកពីទូទាំងប្រទេស ទូទាំងអង្គភាពកងទ័ព មកពីតំបន់ទាំងអស់។ ដូច្នេះ មានរហូតទៅដល់រាប់ពាន់ឯណោះ។ កិច្ចប្រជុំនេះ គឺធ្វើឡើងនៅស្តាតចាស់ ភាគខាងជើងនៃទីក្រុងភ្នំពេញ។ គោលបំណងគឺដើម្បីទទួលផែនការដែលមជ្ឈិមបានដាក់ចុះ។ ហើយក្រោយមកក៏ត្រឡប់ទៅកន្លែងរបស់ខ្លួនវិញ ដើម្បីអនុវត្តផែនការនេះ។ អង្គប្រជុំនេះគឺថាមានរយៈពេល៥ថ្ងៃ"។

[១៥:១០:១៤]

លោក ហេងឌ័រ លោកឃើញហើយ សារនេះគឺយោងទៅលេខយោងទំព័រ១០៦ ហើយលេខយោងជើងទំព័រ១០៦ នេះគឺសរសេរដូចតទៅ -- នៅត្រង់ទំព័រដដែលនេះគឺរឿងរ៉ាវដែលរៀបរាប់ដោយលោក ហេង សំរិន នៅឆ្នាំ១៩៩១ "ជា ស៊ីម គឺថាជា -- ពេលនោះ គាត់រស់នៅក្នុងទីក្រុងគឺថា ជា ស៊ីម ក៏នៅទីនោះផងដែរ នៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពសូវៀត"។

នៅត្រង់ទំព័រ៥៧ ERN ភាសាអង់គ្លេស 00678523, បារាំង 006387 *(ស៊ីក)* ដល់ 87, ហើយខ្មែរ 0063744 *(ស៊ីក)* ដល់ 46។ នៅត្រង់ទំព័រ៥៧នេះ លោក ហេងឌ័រ ខ្ញុំសូមអានសម្រង់ដូចតទៅនៅត្រង់កថាខណ្ឌទី២ "ហេង សំរិន គឺសិក្សាអំពីកិច្ចការយោធា ដែលក្នុងនោះ សុន សេន ក៏ចូលរួមនៅក្នុងកិច្ចប្រជុំនេះដែរ"។

សូមដកស្រង់៖ "គឺថាគេមិនប្រើពាក្យសម្លាប់ទេ គេប្រើពាក្យកម្ចាត់អ្នករបបចាស់។ *ស្មោតផ័រ* មានន័យថា "កម្ចាត់"។ កុំអនុញ្ញាតឲ្យគេស្ថិតនៅក្នុងក្របខ័ណ្ឌការងារ។ គេមិនបានប្រើពាក្យសម្លាប់ទេ ប៉ុន្តែគេប្រើពាក្យទូទៅថា កម្ចាត់។ នួន ជា បានប្រើពាក្យនេះ។ នេះគឺជាចំណុចដែល ស៊ិន សុង បានលើកនៅលើចំណុចទី៥ លក្ខណៈសម្បត្តិរបស់ជនកុម្មុយនីស្តនៅពេលនោះ"។

[១៥:១២:៣៤]

លោក ហេងឌ័រ បានខ្ញុំបានស្រង់សម្រង់ពីរហើយ ទី១និយាយអំពីវត្តមានទូទៅរបស់លោក ហេង សំរិន នូវកិច្ចប្រជុំថ្ងៃទី២០ ឧសភា ១៩៧៥ និងមួយទៀត ដែលគាត់និយាយថា គាត់បានឮអំពីខ្មាំង។

សំណួររបស់ខ្ញុំ គឺថាតើលោកតាមការសម្ភាស ឬក៏អានឯកសារណាមួយ តើមានព័ត៌មានអង្គហេតុណាមួយដែលវាស៊ីសង្វាក់ទៅនឹងចំណុច ដែលខ្ញុំទើបតែស្រង់អានជូនលោកស្តាប់ពីរចំណុចអម្បាញ់មិញទេ?

**លោក ស្មីវ ហេដឌ័រះ**

**ឆ៖** បាទផង ទេផង។ ពីមុននោះ ខ្ញុំបានលើកឡើងហើយថា ឯកសាររបស់ខ្ញុំបញ្ជាក់ថាមានកិច្ចប្រជុំលើសពីមួយលើក។ ហេតុអ្វីបានជាមានអ្នកខ្លះនិយាយប្រជុំនៅកន្លែងមួយនេះ អ្នកខ្លះនិយាយថាមានកិច្ចប្រជុំនៅកន្លែងមួយផ្សេងទៀត។ មិនបញ្ជាក់ថាម្នាក់នេះត្រូវ ម្នាក់នោះខុសទេ ដោយសារថាអ្នកដែលរៀបរាប់ប្រាប់ខ្ញុំហ្នឹង គឺថាចូលប្រជុំលើសពីមួយដង ហើយប្រជុំខុសកន្លែងគ្នា។ គឺមិនមានជាមនុស្សដែលចូលរួមប្រជុំដដែលៗនោះទេ។

[១៥:១៤:១៣]

ការផ្សព្វផ្សាយអំពីមាគ៌ាដើម្បីយកទៅអនុវត្ត គឺនៅក្នុងអំឡុងពេលហ្នឹងគឺចុងខែឧសភា ឬក៏ដោយដើមខែមិថុនា ១៩៧៥។ ហើយតាមការចងចាំរបស់ខ្ញុំ ព័ត៌មានប្រភេទនេះមិនបានមកពីប្រភពដែលមានឋានៈខ្ពស់ដូច ប៉ែន យៀវនិន បានទទួលនេះទេ។ ហើយក៏មិនចាំបាច់អ្នកដែលមានវត្តមានដោយផ្ទាល់ក្នុងកិច្ចប្រជុំដែរ។ ប៉ុន្តែអ្នកដែលមកពីអង្គភាពកងទ័ព មកពីអង្គភាពកងការពារដែលគ្រាន់តែដឹងថាកិច្ចប្រជុំហ្នឹងធ្វើឡើងនៅពេលណា? នៅកន្លែងណា? ប៉ុន្តែកិច្ចប្រជុំមិនផ្ទាល់នោះ គឺថាគេដឹងឡើងតាមរយៈមេៗរបស់គេបានប្រាប់គេ មេៗដែលបានចូលរួមប្រជុំនៅពេលនោះ។ ហើយតាមដែលខ្ញុំចាំហ្នឹង គឺយ៉ាងហោចណាស់ក៏ព័ត៌មានហ្នឹងវាមាន វាជាព័ត៌មានដែលគួរឱ្យទទួលយកបាន។

**ស៖** តើលោកអាចបញ្ជាក់បានទេ ទិន្នន័យដែលលោកទទួលបានពីការ ពីឯកសារសិក្សាក្រោយពីលោកនិយាយទៅកាន់មនុស្សណាម្នាក់ ឬក៏សាកសួរមនុស្សម្នាក់ ថាតើទិន្នន័យហ្នឹងវាស៊ីសង្វាក់គ្នាទៅនឹងឃ្លា ឬក៏ពាក្យពេចន៍ដែល ហេង សំរិន បានប្រើប្រាស់ បានបញ្ជាក់ថា នួន ជា នោះ ជាអ្នកនិយាយនៅក្នុងកិច្ចប្រជុំនេះ នៅក្នុងកិច្ចប្រជុំនោះនោះ?

[១៥:១៦:២០]

**ឆ៖** ខ្ញុំមិនមានបញ្ហាអីទេ។ គឺនៅផ្នែកខាងស្តាំនៃERN ជាភាសាអង់គ្លេស 00678523 ជាទំព័រដើមនោះគឺ៥៧ ត្រង់ទំព័រ៥៧។ នេះគេនិយាយការប្រើប្រាស់ ឬក៏មិនប្រើប្រាស់ ពាក្យថា *"ស្មាស"* គឺកម្ទេច ដែលតាមអ្នកឆ្លើយតែម្តង គឺថាត្រូវបានគេបញ្ជាក់ន័យថា គឺសម្លាប់ហើយពាក្យហ្នឹង។ ប៉ុន្តែខ្ញុំ

មានបញ្ហាចំពោះពាក្យ "កម្ចាត់" នេះ គឺវាមិនស៊ីសង្វាក់គ្នាទៅនឹងទិន្នន័យនៃកិច្ចសម្ភាសន៍របស់ខ្ញុំនោះទេ។ ហើយការបកប្រែពាក្យថា "កម្ចាត់" នេះ *"ស្មេតធ័រ"* – កម្ចាត់ គឺតាមដែលខ្ញុំយល់មិនត្រូវទេ។ ពាក្យនៅក្នុងអាស៊ីអាគ្នេយ៍ហ្នឹង គឺវាមានន័យដូចថា ដូចជាត្រួតគ្នា ហើយពាក្យមួយដែលមានបែបបទរវាងពាក្យ -- ពាក្យដែល មានពាក្យជាប់គ្នាគឺ "កម្ចាត់កម្ចាយ"។ "កម្ចាត់" វាពាក្យនេះ គឺថាធ្ងន់ជាងខ្លាំងជាង មានន័យថា "បំបាត់ចោល"។

ដូច្នេះពាក្យដែលប្រើភ្ជាប់គ្នាថា "កម្ចាត់កម្ចាយ" អាចបកប្រែជាអង់គ្លេសថា *"អេលីមីនេត"* គឺកម្ចាត់ បំបាត់ គឺ "កម្ចាត់" នេះតាមខ្ញុំយល់ គឺមានន័យធ្ងន់។ បាទ ពាក្យនេះធ្ងន់ជាង "កម្ចាយ"។ ហើយវាមានន័យស្ទើរតែដូចគ្នាទាំងស្រុងទៅនឹងពាក្យថា "កម្ទេច"។ ខ្ញុំកំពុងតែគិតថាតើពាក្យនេះ ខ្ញុំកំពុងតែនិយាយពីរឿងរបៀបរបបដែលកិច្ចសម្ភាសន៍ជាទូទៅនោះ បញ្ជាក់ថា តើអត្ថន័យ និងការប្រើប្រាស់ពាក្យពេចន៍នេះវាយ៉ាងណានោះ។

[១៥:១៩:១៣]

**ស៖** តើនៅពេលណាមួយលោកអានកិច្ចសម្ភាសន៍នេះដោយផ្ទាល់ ដូចជាចំណុចដែលលោក ប៊ែន ឃៀរនិន សរសេរនៅក្នុងសៀវភៅរបស់គាត់នេះដែរឬទេ?

**ឆ៖** បាទ នៅក្នុងកម្រិតមួយនោះ លោក ឃៀរនិន គាត់ប្រើប្រាស់ល្អជាងខ្ញុំ ដោយសារថាកំណត់ត្រានៃកិច្ចសម្ភាសន៍ វាខុសពីការកត់ត្រាដោយដៃរបស់ខ្ញុំ សរសេរដោយដៃ។ ប៉ុន្តែតាមដែលខ្ញុំចាំ គឺកំណត់ត្រាដើមនៃកិច្ចសម្ភាសន៍ហ្នឹង ដែលខ្ញុំបានឃើញនៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះគឺគេសរសេរជាភាសាអង់គ្លេស។ អ៊ីចឹងគាត់សរសេរៗឡើងជាភាសាអង់គ្លេស តាមរយៈការបកប្រែឲ្យគាត់ និងក្នុងកិច្ចសម្ភាសន៍មានអ្នកបកប្រែឲ្យគាត់ ឬក៏ការបកប្រែមកពីខ្មែរអាត់ណាមួយ។ ខ្ញុំយល់ឃើញថាគាត់កត់ត្រាចូលនៅក្នុងសៀវភៅកត់ត្រារបស់គាត់តាមរយៈការបកប្រែ។

[១៥:២០:៤២]

**ស៖** ខ្ញុំបង្ហាញ សូមបង្ហាញជូនលោកនៅកិច្ចសម្ភាសន៍ដើម គឺលោក ប៊ែន ឃៀរនិន បានយោងគឺឯកសារ E3/1568។ ERN ជាភាសាអង់គ្លេស 00651884, បារាំង 00743356 ដល់ 57, ខ្មែរ 00713954 - 00713955 ត្រង់ពាក់កណ្ដាលនៃទំព័រនេះ។ ខ្ញុំសូមអានដូចតទៅ-- បាទនេះគឺជាសម្រង់សម្ដីរបស់លោក ហេង សំរិន "គេមិនបានប្រើពាក្យថា សម្លាប់ទេ (ពាក្យខ្មែរមិនច្បាស់) កុំអនុញ្ញាតឲ្យពួកគេស្ថិតនៅក្នុងជួរការងារ មិនមែនន័យថា "កម្ទេច"ទេ។ នួន ជា បានប្រើពាក្យនេះ"។ តើលោកមាន

ប្រតិកម្មយ៉ាងម៉េចដែរចំពោះចំណុចនេះ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:២២:១៧]

**លោក ឃីត រេយ៍ន័រ៖**

លោកប្រធាន មេធាវីការពារក្ដី គឺនៅពេលជំទាស់ចុងក្រោយទៅលើឯកសារនេះ ហើយឥឡូវនេះ គាត់យកឯកសារហ្នឹងមកយោង។ ខ្ញុំសូមធ្វើការជំទាស់ដើម្បីជាកំណត់ត្រានៃប្រតិចារឹក គឺអានសម្រង់ដែលថា “ពាក្យខ្មែរមិនច្បាស់” ដែលបានយោងទៅនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមឆ្លើយតបខ្លីទេ តំណាងសហព្រះរាជអាជ្ញាបានដឹងយ៉ាងច្បាស់ហើយថា យើងបានប្រើប្រាស់សម្រង់នៃពាក្យនេះ ជាច្រើនលើកច្រើនសានៅក្នុងសំណើសុំរបស់យើងដើម្បីឲ្យ -- ហេតុអី -- អ៊ីចឹងហើយបានជាស្នើសុំឲ្យកោះហៅសាក្សីរូបនេះ។ ខ្ញុំមិនដឹងថា តើការជំទាស់នេះមានន័យយ៉ាងម៉េចទេ ពីព្រោះយើងចង់ប្រើខ្លឹមសារជាក់លាក់មួយនេះ ដោយស្រង់ចេញពីឯកសារនេះតែម្ដង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំសូមសួរឲ្យបានជាក់លាក់ទៅកាន់លោកសាក្សី ថាតើលោកយល់ថាយ៉ាងម៉េចដែរចំពោះពាក្យថា កុំអនុញ្ញាតឲ្យពួកគេស្ថិតនៅក្នុងក្របខ័ណ្ឌការងារ ជួរការងារ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាល់ទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីជាតិនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៥:២៣:៥២]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ បែបបទនៃការសួរនេះ គឺជាបែបបទសម្រាប់សួរទៅអ្នកជំនាញលោក ស្ទីវ ហេដឌ័រ គាត់មិនមែនជាអ្នកជំនាញ។ ដូច្នេះសំណួរបែបនេះមិនសមស្របទេ។ សូមជំទាស់។ សូមអរគុណ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយ។ លោក ហេងឌ័រ បានធ្វើការបកស្រាយភាសាសព្ទនេះជាច្រើនលើកច្រើនសា។ ឥឡូវខ្ញុំបាទយកឃ្លាភាសាខ្មែរមកបង្ហាញគាត់ជាច្រើនលើកច្រើនសា ដើម្បីសួរទៅគាត់ចង់ដឹងអំពីសមត្ថភាពរបស់គាត់ក្នុងឋានៈជាសាក្សី។

[១៥:២៤:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:២៧:០៧]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រគល់ភារៈជូនទៅលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ដើម្បីបញ្ជាក់អំពីសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើសេចក្ដីជំទាស់ទៅនឹងតាំងសំណួរចុងក្រោយដែលសួរឡើងដោយមេធាវីអន្តរជាតិការពារក្ដីលោក នួន ជា។ សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះយល់ឃើញថា គួរតែចាត់ទុកសំណួររបស់មេធាវីការពារក្ដីនេះ គឺជាសំណួរដែលព្យាយាមចង់បានការបកស្រាយនូវសំនួនវោហារសព្ទជាភាសាខ្មែរ។ ក៏ប៉ុន្តែការបកស្រាយនេះ គឺវាជាសមត្ថភាពរបស់អ្នកជំនាញទេ មិនមែនរបស់សាក្សីទេ។ លើកលែងតែសាក្សីគាត់មានព័ត៌មានសំខាន់ ដែលអាចផ្ដល់ចម្លើយជាក់លាក់ទៅនឹងសំណួររបស់មេធាវីការពារក្ដីបាន។ អង្គជំនុំជម្រះយល់ថា មិនគួរសួរសំណួរបែបនេះទៅកាន់សាក្សីនោះទេ។ ដូច្នេះ សូមមេធាវីការពារក្ដីកុំសួរបែបនេះ ហើយបន្តសំណួរទៅមុខទៀត លើកលែងតែលោក ស្ទីវ ហេងឌ័រនេះ គាត់មានព័ត៌មានជាក់លាក់ដែលអាចឆ្លើយទៅនឹងលោកបាន។

[១៥:២៨:៤៥]

**លោក ស្ទីវ ហេងឌ័រ៖**

**ឆ៖** បាទ អត់ទេ ដោយសារថានៅក្នុងឧទាហរណ៍នេះ ខ្ញុំមិនអាចនឹកឃើញថា ពាក្យខ្មែរ ពាក្យដើមរបស់ខ្មែរ ប៉ុន្តែជាអង់គ្លេសមិនមានន័យអីសម្រាប់ខ្ញុំទេ។ ប្រហែលជាអាចការបកប្រែខុសក៏មិនដឹង ខ្ញុំកំពុងតែគិតអំពីថាតើអ្នកដទៃប្រាប់ខ្ញុំ ថាតើវាមានន័យយ៉ាងដូចម្ដេចនោះ? ប៉ុន្តែខ្ញុំនឹកមិនទាន់ទេ បើមិនមានពាក្យឯកសារដើមជាភាសាខ្មែរ ឬក៏ប្រតិចារឹក ឬក៏កំណត់ត្រានៃកិច្ចពិភាក្សាហ្នឹងទេ ខ្ញុំមិនអាច

បកស្រាយបានទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ហេដឌ័រ ខ្ញុំសូមបន្តទៅមុខទៀត។ នៅម៉ោងចុងក្រោយយើងនិយាយលម្អិតអំពី ហេង សំរិន យើងពិភាក្សាខ្លះអំពីការចូលរួមបដិវត្តន៍របស់គាត់។ យើងពិភាក្សាទូលំទូលាយអំពីតួនាទីរបស់គាត់ក្នុងពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ហើយយើងក៏បានពិភាក្សាអំពីវត្តមានរបស់គាត់នៅកិច្ចប្រជុំថ្ងៃទី២០ ឧសភា ៧៥ ផងដែរ។ អ្វីដែលយើងមិនទាន់បានពិភាក្សាគ្នានៅឡើយនោះ គឺខ្ញុំសូមសួរថា តើលោកមានព័ត៌មានអង្គហេតុណាមួយដោយយោងទៅលើកិច្ចសម្ភាសន៍របស់លោកជាមួយអ្នកដែលលោកសម្ភាស ដែលអនុញ្ញាតឲ្យលោកបង្ហាញនូវទំនាក់ទំនងអង្គហេតុ ព័ត៌មានពាក់ព័ន្ធទៅនឹងទំនាក់ទំនងរវាង ហេង សំរិន និង នួន ជា បានទេ?

**ឆ៖** តាមដែលខ្ញុំចាំ គឺថាព័ត៌មានបែបនេះៗខ្ញុំអាចចាំបាននោះ គឺថានៅក្នុងសំណុំរឿងនៃកិច្ចសម្ភាសន៍ដែលធ្វើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេត។ ខ្ញុំមិនមាននៅក្នុងឯកសារដែលខ្ញុំធ្វើក្រៅតុលាការនោះទេ។ ចម្លើយថា “អត់ទេ”។

[១៥:៣១:២៩]

**ស៖** ឥឡូវខ្ញុំសួរសំណួរបើក តែ -- ខ្ញុំសួរសំណួរបើក ឥឡូវសួរសំណួរបិទវិញទាក់ទងទៅនឹងទំនាក់ទំនងដែលអាចនឹងមានរវាង នួន ជា និង ហេង សំរិន។ តើលោកមានការដឹងឮដោយយោងទៅលើអង្គហេតុណាមួយតាមរយៈកិច្ចសម្ភាសន៍របស់លោក ឬក៏អានឯកសារណាមួយ ឬក៏ក្នុងព័ត៌មានពីកិច្ចប្រជុំបែបហ្នឹង ដែលអាចបង្ហាញឲ្យឃើញថាតាមពិតទៅ គឺ ហេង សំរិន គឺជានីរសាររបស់ នួន ជា ជាច្រើនឆ្នាំ លោកអាចបញ្ជាក់បានទេ?

**ឆ៖** ខ្ញុំយល់ឃើញថា មកពីប្រភពផ្សេងទៀតក្រៅប្រភពរបស់ខ្ញុំ។ ខ្ញុំដាក់បញ្ចូលប្រភពអាចជាមាននៅក្នុងសំណុំរឿងនៃអំឡុងពេលកិច្ចសម្ភាសន៍នៅពេលដោយការិយាល័យសហចៅក្រមស៊ើបង្កេត។ ខ្ញុំគិតថាខ្ញុំអត់មានទិន្នន័យនេះទេ មិនមានទិន្នន័យនេះ នៅក្នុងកិច្ចការដែលខ្ញុំធ្វើនៅក្រៅតុលាការនោះទេ។ ខ្ញុំអត់បានព័ត៌មាននេះដោយផ្ទាល់ទេ ខ្ញុំបានព័ត៌មាននេះនៅពេលធ្វើការនៅក្នុងតុលាការហ្នឹង ឬក៏ខ្ញុំបានព័ត៌មាននេះពីកិច្ចការរបស់អ្នកដទៃទៅវិញទេ។

[១៥:៣២:៥៥]

**ស៖** ដើម្បីឲ្យច្បាស់ តើលោកមានព័ត៌មានផ្នែកអង្គហេតុតាមរយៈកិច្ចសម្ភាសន៍ ឬក៏ការអាន

ឯកសារណាមួយជាដើម។ល។ ដែលវាស៊ីសង្វាក់គ្នាទៅនឹងអង្គហេតុ ឬទៅនឹងលទ្ធភាពដែលថា នួន ជា និង ហេង សំរិន ស្គាល់គ្នាតាំងពីទសវត្សរ៍១៩៥០ នោះបានទេ?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេលោកសាក្សី! សំណួរនេះគឺជាសំណួរច្រំដែលៗ ហើយបីដងរួចហើយ។

សូមរំឭកលោកមេធាវីថា លោកមិនមានឱកាសក្នុងការបន្ថែមម៉ោងនោះឡើយ ពីព្រោះលោកបានប្រើប្រាស់ពេលវេលាខ្ជះខ្ជាយ ហើយមិនមានប្រសិទ្ធភាព។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរចុងក្រោយនៃប្រធានបទនេះ លោក ហេដឌ័រ ខ្ញុំសូមបង្ហាញលោកទៅលេខជើងទំព័រនៅក្នុងសៀវភៅ ប៉ែន យៀរនិន គឺលេខជើងទំព័រ៩៧ ទំព័រ២០៦។ ERN ជាភាសាអង់គ្លេស 00678598, បារាំង 00638963, ខ្មែរ 00637675 ដល់ 76 គឺ 00639340 គឺនេះលេខ ERN សម្រាប់ជើងទំព័រ។

[១៥:៣៥:០០]

លេខយោងជើងទំព័រ៩៧នេះ គឺខ្ញុំសូមអានពីរបីបន្ទាត់ "ហេដឌ័រ ដំបូងបានបញ្ជាក់ថា ភូមិភាគបូព៌ាដឹកនាំដោយ ហេង សំរិន ដែលបានបញ្ជូនឯកសារសម្ងាត់និយាយអំពីបក្សកុម្មុយនីស្តកម្ពុជាទៅដល់វៀតណាម។ យោងតាមលោក ហេដឌ័រ នៅក្នុងឆ្នាំ១៩៥៩ ហេង សំរិន បានជ្រាបចូលនៅក្នុងតួនាទីបក្សកុម្មុយនីស្តកម្ពុជា តួនាទីនេះដោយវៀតណាម។ ហើយគាត់ក៏បានឡើងឋានៈទៅតាមនោះ។ ហេតុដូច្នេះហើយបានជាគាត់បានភៀសខ្លួនទៅវៀតណាម ដូច គឹម ហ្វឺល *(តាមសូរស័ព្ទ)* ដែលបានភៀសខ្លួនទៅសហរដ្ឋអាមេរិកអ៊ីចឹងដែរ"។

នេះយោងទៅអត្ថបទដែលលោកបានសរសេរ និយាយអំពីអង្គការចាត់តាំងនៃខ្មែរក្រហម នៅថ្ងៃ០៥ មីនា ១៩៧៥។ សំណួររបស់ខ្ញុំសួរថា តើលោកពិតជាបានសរសេរខ្លឹមសារនេះ អំពីបញ្ហា ហេង សំរិន នេះមែនឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

[១៥:៣៦:២៩]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម។ ខ្ញុំបានពិនិត្យទៅលើ អ៊ីម៉ែលដែលមន្ត្រីជាន់ខ្ពស់របស់អង្គជំនុំជម្រះបានផ្ញើទៅយើងខ្ញុំ នៅថ្ងៃទី០៣ ខែ៧ ឆ្នាំ២០១៣នេះ បានបញ្ជាក់ច្បាស់ថា សាក្សីនេះគឺផ្តល់សក្ខីកម្មពាក់ព័ន្ធទៅនឹងសំណុំរឿង០០២/០១។ សំណួរអម្បាញ់មិញ តាមការពិនិត្យទៅ មិនមានពាក់ព័ន្ធអ្វីទៅនឹងសំណុំរឿងដែលយើងកំពុងតែពិនិត្យនេះទេ។ ដូច្នេះ ខ្ញុំគិតថា វាមិនមានការពាក់ព័ន្ធទេ ហើយសំណួរនេះជាសំណួរដែលមិនសមស្រប ហើយសូមជំទាស់។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគ្រាន់តែសួរអំពីលេខជើងទំព័រយោងទៅអ្វីមួយដែលសាក្សីនេះ គាត់បានសរសេរសំណួររបស់ខ្ញុំគ្រាន់តែសួរអ៊ីចឹង ថាតើលោកពិតជាបានសរសេរនូវអ្វីដែលបានដកស្រង់នៅលេខយោងជើងទំព័រនេះដែរឬទេ? នេះគឺសំណួរខ្ញុំសួរតែប៉ុណ្ណោះឯង។

[១៥:៣៧:៤៦]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់មិនមានប្រសិទ្ធភាពទេ។ សាក្សីឆ្លើយតបទៅនឹងសំណួរដែលសួរនេះ។

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំគិតថា ដូចជាខ្ញុំមិនបានសរសេរអាហ្នឹងទេ គឺខ្ញុំដកស្រង់ថា នូវអ្វីដែលគេបាននិយាយ។ គឺមិនបានឆ្លុះបញ្ចាំងទៅនឹងបរិបទនេះតែមួយនោះទេ។ ដូច្នេះ២៩វាអាចជាការពិត ឬក៏យ៉ាងនោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំមិនដឹងថា តើខ្ញុំយល់ចម្លើយរបស់លោកពេញលេញដែរ ឬក៏អត់នោះទេ? សូមលោកបញ្ជាក់បន្តិចមក។

[១៥:៣៨:៣៨]

**ឆ៖** មុននេះ ខ្ញុំលើកឡើងថា ខ្ញុំទាក់ទងជាមួយនឹងក្រុមហ្នឹង។ ហើយតាមខ្ញុំចាំ ខ្ញុំបានជជែកជាមួយនឹងពួកគេ ទាក់ទងទៅនឹងទស្សនកិច្ចរបស់គាត់មកប្រទេសកម្ពុជា ពាក់កណ្តាលឆ្នាំ៧៨ និងនាពេលក្រោយមក។ គឺចំណុចនេះគឺដកស្រង់ដោយពួកគេ នៅក្នុងទិនានុប្បវត្តិនោះ។ ដូច្នេះហើយនេះជា វាមិន

បានផ្ទុះបញ្ហាំងការយល់របស់ខ្ញុំទាំងស្រុងនៅពេលនោះនោះទេ។ ចំណុចនេះ វាអាចមានលទ្ធភាពថាចេញពីហ្នឹងមក។

**ស៖** តើលោកដឹងទេ ថាលោក ហេង សំរិន ដូច គីម ហ្វីល *(តាមសូរស័ព្ទ)* នៅក្នុងប្រទេសកម្ពុជា?

**ឆ៖** --

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយតបទេ បាទ។ មិនមែនអ្នកជំនាញទេ ហើយសំណួរឲ្យសាក្សីធ្វើសេចក្ដីសន្និដ្ឋានត្រូវហាមឃាត់។

[១៥:៣៩:៤៥]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំសូមបន្តទៅមុខទៀត គឺដូរទៅប្រធានបទមួយដោយឡែក គឺសៀវភៅរបស់លោកស្ដីអំពី "កុម្មុយនីស្តនិយម"។ ERN គឺឯកសារ E3/22។ អ្វីដែលខ្ញុំចង់ធ្វើដើម្បីពន្លឿននីតិវិធី គឺខ្ញុំដកស្រង់ចំណុចមួយចំនួនចេញពីសៀវភៅរបស់លោក។ ជាពិសេសនៅបុព្វកថាដែលសរសេរឡើងដោយ ដេវីដ ឆេនដ៍ល័រ។ គាត់ -- ដេវីដ នោះគាត់សង្ខេបៗល្អដែរ ថាតើលោកចង់បង្ហាញអ្វីនៅក្នុងសៀវភៅរបស់លោក? ខ្ញុំនឹងអាចចំណុចនេះ ហើយខ្ញុំចង់ឲ្យលោកបញ្ជាក់ថាតើគាត់បានលើកឡើងត្រឹមត្រូវ សង្ខេបត្រឹមត្រូវដែរឬទេអំពីសៀវភៅរបស់លោក ប្រសិនបើអត់ត្រឹមត្រូវទេលោកអាចពន្យល់បន្ថែមឲ្យខ្ញុំដឹងបាន។

**លោក ឃីត រេយ៍ន័រ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមលោកតំណាងសហព្រះរាជអាជ្ញា!

[១៥:៤១:០៩]

**លោក ឃីត រេយ៍ន័រ៖**

នេះមិនមែនជាការលើកឡើងអ្វីដែលគាត់សរសេរទេ គឺសួរទៅកាន់ ហេដឌ័រ អំពីការសរសេររបស់លោក ដេវីដ ឆេនដ៍ល័រ អំពីលោក ស្ទីវិន ហេដឌ័រ ឲ្យលោក ស្ទីវិន ហេដឌ័រ នេះឆ្លើយ។ ដូច្នេះ

ហើយវាមិនបានផ្ទុះបញ្ចាំងនូវអ្វីដែលសួរទៅកាន់សាក្សីនេះដោយផ្ទាល់នោះទេ។ នេះជាការអញ្ជើញឱ្យសាក្សីនេះផ្តល់ជាមតិយោបល់។ សេចក្តីណែនាំរបស់អង្គជំនុំជម្រះមិនបានលើកឡើងថា អាចសួរទៅកាន់លោក ស្ទីវ ហេដឌ័រ ចំពោះអ្វីដែលគេសរសេរអំពីគាត់នៅក្នុងសៀវភៅរបស់ពួកគេនោះទេ។ ការណែនាំរបស់អង្គជំនុំជម្រះ គឺថាសួរលោក ហេដឌ័រ ចំពោះការសរសេរនៅក្នុងសៀវភៅរបស់គាត់ មិនមែននិយាយអំពីអ្នកផ្សេងសរសេរអំពីសៀវភៅរបស់លោក ស្ទីវិន ហេដឌ័រ នោះទេ។

[១៥:៤២:០៥]

ដូច្នេះខ្ញុំសូមលើកឡើងថា បើសិនយើងត្រឡប់ ដូចដែលយើងត្រឡប់កាក់មកវិញអ៊ីចឹង នៅពេលនេះលោក ស្ទីវិន ហេដឌ័រ គឺសួរ ដូចសួរអំពី១ករណីដែល តើលោក យៀរនិន បានសរសេរអ្វីខ្លះទៅលើសៀវភៅរបស់គាត់? គ្រាន់តែសួរនៅពេលនេះថា តើលោក ដេវីដ ឆេនដ័ល័រ សរសេរអ្វីខ្លះអំពីលោក ស្ទីវិន ហេដឌ័រ។ ដូច្នេះហើយគួរតែសួរតែសៀវភៅដែលសរសេរដោយលោក ស្ទីវិន ហេដឌ័រ ហើយតើលោក ហេដឌ័រ នោះយល់យ៉ាងណាចំពោះអ្វីដែលគាត់សរសេរ? យើងមិនអាចសួរអំពីករណីដែលលោក ដេវីដ ឆេនដ័ល័រ សរសេរ ហើយឱ្យលោក ស្ទីវិិិន ហេដឌ័រ ឆ្លើយនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ចំណុចនេះ មិនមែនវាពាក់ព័ន្ធនឹងវិវាទរវាងលោក ដេវីដ ឆេនដ័ល័រ និងលោក ស្ទីវិន ហេដឌ័រ នោះទេ។ លោក ដេវីដ ឆេនដ័ល័រ គឺគាត់ទំនងជាពេញចិត្តនឹងសៀវភៅសរសេរដោយ ស្ទីវិន ហេដឌ័រ ដែរ។ បុព្វកថានោះ ខ្ញុំលើកឡើងយកមកនេះ ដើម្បីគិតថាវាអាចពន្លឿនកិច្ចដំណើរការនីតិវិធីរបស់យើងតែប៉ុណ្ណោះ។ ក៏ប៉ុន្តែខាងតំណាងសហព្រះរាជអាជ្ញាហាក់ដូចជាគាត់ហ្នឹងអាចមានលក្ខណៈឆ្លល់ទៅនឹងសំណួរដែលខ្ញុំសួរនេះ។

[១៥:៤៣:២៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូច្នេះខ្ញុំសួរបែបនេះវិញ។ នៅក្នុងសៀវភៅរបស់លោក តើលោកបានលើកឡើងអំពីបញ្ហាកុម្មុយនីស្តនៅកម្ពុជាដែរឬទេ? ហើយប្រសិនបើលោកបានសរសេរនោះ តើលោកបានសរសេរអ្វីខ្លះលើបញ្ហានេះ?

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** ខ្ញុំត្រូវតែនឹកឃើញឡើងវិញ មិនដឹងថាលោក -- ប្រហែលជាលោក ដេវីដ ឆេនដ័ល័រ

និយាយអំពីបញ្ហានេះនៅក្នុងសៀវភៅនុ៎ង មិនមែនខ្ញុំទេ ទំនង។

**ប្រធានអង្គជំនុំ៖**

ទំនងជាអស់សំណួរហើយទេដឹងលោកមេធាវី? លោក វ៉ិចទ័រ កូប៉េ? អស់សំណួរនៅ? តាមសំណួរសួរហ្នឹង ដូចជាអស់សំណួរហើយតាមមើល៍!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ មិនត្រឹមត្រូវទេលោកប្រធាន ខ្ញុំមានសំណួរច្រើនទៀត។

[១៥:៤៤:៣៨]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ស្ទីវិន ហេដឌ័រ តើលោកសៀវភៅ -- សរសេរក្នុងសៀវភៅរបស់លោកនិយាយអំពីបញ្ហាកុម្មុយនីស្ត បក្សកុម្មុយនីស្តកម្ពុជា ហើយនិងបញ្ហាកុម្មុយនីស្តនេះដែរឬទេ?

**លោក ឃីត សេយ៍ន័រ៖**

សូមឲ្យលើកទំព័រណា? លេខយោងអីដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំត្រូវបានអនុញ្ញាតឲ្យដកស្រង់ចេញពីសៀវភៅ។ ដូច្នេះមិនបាច់ចាំផ្តល់ជាទំព័រទេ។

**លោក ឃីត សេយ៍ន័រ៖**

នៅក្នុងនេះ នៅក្នុងតុលាការ ឬនៅកន្លែងយើងលេងជាមួយគ្នា ប្រឡែងលេងទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំនឹងលើកឡើងបញ្ហានេះ។

[១៥:៤៥:១៧]

**លោក ឃីត សេយ៍ន័រ៖**

ដូច្នេះហើយនៅពេលនេះខ្ញុំបញ្ជាក់ឲ្យច្បាស់តែម្តង។ សូមឲ្យមេធាវីនេះមិនចាំបាច់សួរសំណួរបន្ថែមទៀតទេ។ នៅក្នុងពេលនេះ គឺហាក់ដូចជាមេធាវីការពារក្តីកំពុងតែមាក់ងាយមកកាន់ភាគីហើយ។ ដូច្នេះគួរតែបញ្ឈប់គាត់ ដើម្បីកុំឲ្យគាត់សួរសំណួរបន្តទៀត។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសួរសំណួរពាក់ព័ន្ធទៅនឹងសៀវភៅ សួរសាក្សីនេះអំពីបញ្ហាកុម្មុយនីស្ត ហើយអ្វីដែលគាត់បាន

សរសេរហើយ។ ហើយតើចំណុចស្នូលនៅក្នុងសៀវភៅរបស់គាត់ហ្នឹង គាត់សរសេរអំពីអ្វីដែរ អំពីកុម្មុយនីស្តកម្ពុជានោះ។ ហើយអ្នកដែលនៅពីជំនាន់មុនរបបកម្ពុជាប្រជាធិបតេយ្យ តើជាពួកកុម្មុយនីស្តដែរឬយ៉ាងម៉េច? អ៊ីចឹងសូមឲ្យគាត់លើកបញ្ជាក់ចំណុចហ្នឹង។

[១៥:៤៦:០៤]

**លោក ឃីត វេយ៍ន័រ៖**

ហេតុអ្វីបានជាយើងធ្វើការអនុគ្រោះទៅដល់មេធាវី? យើងមានការណែនាំ ដូច្នេះខ្ញុំត្រូវគោរពតាមណែនាំ។ អង្គជំនុំជម្រះគួរតែណែនាំទៅដល់មេធាវីការពារក្តី ខ្ញុំមិនអាចណែនាំទេ។ អង្គជំនុំជម្រះគួរតែបង្គាប់ ដោយសារតែខ្ញុំត្រូវទទួលបានការបង្គាប់ពីអង្គជំនុំជម្រះផងដែរ។

**លោក វ៉ិចទ័រ កូប៉េ៖**

នៅពេលនេះ ខ្ញុំគិតថាតំណាងសហព្រះរាជអាជ្ញាហាក់ដូចជាមិនត្រូវលើកឡើងអ្វីជំទាស់ទៅនឹងការដែលខ្ញុំសួរនេះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី លោកអាចប្រព្រឹត្តិទៅដូចអ្វីដែលលោកបានធ្វើ ឬភាគីដទៃទៀតធ្លាប់បានធ្វើដែរទេ? លោកដូចធ្វើការងារដេញដោលនៅតុលាការនេះដូចជាច្រើនរយៈពេលយូរហើយ ក្នុងការដកស្រង់ឬក៏យកផ្នែកលើទំព័រ លើខ្លឹមសារនៃឯកសារណាមួយត្រូវបង្ហាញអំពីលេខនៃឯកសារ ហើយនិងទំព័រនៃឯកសារជាបីភាសា។ មិនមែនយកមកសួររួមៗជាទូទៅដូច្នោះទេ។ ប្រសិនបើលោកមានបំណងសួរគឺសូមលោកសួរឲ្យច្បាស់លាស់ ជាក់លាក់ ហើយដកស្រង់នូវផ្នែកណាមួយ នូវទំព័រណាមួយនៃឯកសារណាច្បាស់លាស់ ដើម្បីមកសួរដេញដោលសាក្សីរូបនេះ។

[១៥:៤៧:៣៣]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ដូចដែលលោកប្រធានបានជ្រាបហើយ ឯកសារនេះមិនបានបកប្រែពេញលេញនោះទេ មានផ្នែកមួយចំនួនតែប៉ុណ្ណោះជាភាសាខ្មែរ អង់គ្លេស។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោក ស្ទីវិន ហេដឌ័រ តើទ្រឹស្តី ឬប្រធានបទចម្បងដែលលោកសរសេរនៅក្នុងសៀវភៅ “កុម្មុយនីស្ត”នេះ គឺអ្វីដែរ? គឺកុម្មុយនីស្តកម្ពុជា និងគំរូខាងវៀតណាម តើលោកសរសេរទ្រឹស្តីចម្បងនៅ

ក្នុងនោះ គឺសរសេរអំពីអ្វីដែរ?

**លោក ស្ទីវ ហេដឌ័រ ៖**

**ឆ៖** គេអាចនិយាយថា សៀវភៅនេះត្រូវបានសរសេរឡើងនៅក្នុងលក្ខណៈសម្រាប់បញ្ញាជននៅក្នុងសម័យអាណានិគម។ ទ្រឹស្តី ឬប្រធានបទចម្បងនៅក្នុងសៀវភៅហ្នឹង គឺប្រឆាំងនឹងអាណានិគម និងសកម្មភាពនយោបាយ និងបទល្មើសប្រឆាំង -- បទល្មើសសកម្មភាពនយោបាយ ដែលខ្ញុំសរសេរនៅក្នុងហ្នឹង។ ក្នុងនោះ គឺវាពាក់ព័ន្ធទៅនឹងការបញ្ចូលនៅក្នុងៗប្រទេស អំពីការអនុវត្តពីអាណានិគមនិយម ហើយត្រូវបានគេយកមកប្រើប្រាស់ ដើម្បីប្រឆាំងនឹងអាណានិគមដោយរបៀបណាវិញ។

ចំណុចហ្នឹងហើយ ដែលសៀវភៅហ្នឹងបានលើកឡើងនៅក្នុងសៀវភៅ ឬក៏ប្រភេទនៃចំណុចដែលខ្ញុំបានសរសេរ។ ខ្ញុំបានសរសេរយោងទៅតាមភស្តុតាងដែលខ្ញុំបានពិនិត្យមើល ឃើញអំពីចលនាកុម្មុយនីស្តកម្ពុជាតាំងពីដើមមក គឺមានឥទ្ធិពលចេញមកពីរចនាសម្ព័ន្ធ និងមនោគមន៍វិជ្ជាកុម្មុយនីស្តរបស់វៀតណាត។ ហើយវាសាមញ្ញទេ ដោយសារតែបញ្ហាកុម្មុយនីស្តនេះវាកើតឡើងនៅក្នុងឥណ្ឌូចិន ហើយពីពេលមួយទៅពេលមួយ ការបញ្ចូលឲ្យទៅជាការអនុវត្តក្នុងប្រទេសនោះ វាក្លាយទៅជាបាតុភាព ហើយបានកើតទៅជាការអនុវត្តប្រឆាំងនឹងវៀតណាមវិញ។

[១៥:៤៩:៤០]

ដូច្នេះបានន័យថា ទម្រង់នៃការគិតរបស់អាណានិគម និងឥរិយាបថរបស់អាណានិគម គឺត្រូវបានគេយកមកអនុវត្តប្រើប្រាស់ប្រឆាំងនឹងអាណានិគមវិញ។ ចំណុចនេះហើយគឺជាបទដ្ឋាន ឬក៏ទម្រង់នៃការវិភាគនៅក្នុងពេលដែលខ្ញុំសរសេរសៀវភៅស្តីអំពីការយល់អំពីអាណានិគមនិយម និងការប្រឆាំងអាណានិគមនិយម។ វាទំនងជាហាក់ដូចជាសៀវភៅរៀបរាប់រឿងរ៉ាវអំពីស្ថានភាពទាំងអស់នោះ។ ហើយក៏ប៉ុន្តែនៅក្នុងហ្នឹងវាមានបទដ្ឋាន ហើយនិងប្រភេទនៃការភ័យខ្លាចផ្នែកនយោបាយដែលខ្ញុំបានដាក់បញ្ចូលក្នុងនោះផងដែរ។

**ស៖** ខ្ញុំសូមឲ្យលោកពិនិត្យមើល សូមឲ្យដាក់សៀវភៅហ្នឹងនៅចំពោះមុខលោកមក បើសិនជាលោកអត់មានទេ ខ្ញុំអាចផ្តល់ជូនលោកបាន។

**លោក វ៉ិចទ័រ កូប៉េះ**

លោកប្រធាន ខ្ញុំសូមផ្តល់ទំព័រដែលពាក់ព័ន្ធទៅកាន់សាក្សី។

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារជាក្រដាសពីមេធាវី យកជូនសាក្សីពិនិត្យ!

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

សូមអញ្ជើញលោក ស្ទីវ!

[១៥:៥១:២៥]

**លោក ស្ទីវ ហេដឌ័រ៖**

**ឆ៖** នៅពេលនេះ ខ្ញុំមើលនៅលេខយោងជើងទំព័ររបស់លោក យៀរនិន អ្វីដែលលោកបានសួរខ្ញុំ។ ខ្ញុំកត់សម្គាល់ឃើញថា នៅក្នុងលេខយោងចំណុចយោងចុះឆ្នាំ១៩៨០ ដែលក្នុងនោះបានចង្អុល គាត់បានចង្អុលបញ្ជាក់អំពីទស្សនទាន ការយល់ឃើញជាក់លាក់អំពីសម្មតិកម្មចំពោះលោក ហេង សំរិន។ ហើយខ្ញុំគិតថាចំណុចដែលសំខាន់នៅក្នុងនេះ គឺថាក្នុងវានៅក្នុងពេលវេលាមួយដែលការពិតទៅនៅពេលនោះ ខ្ញុំក៏ទាយដែរ ទាយស្មានដូចគ្នា។ វាមានលទ្ធភាពមួយចំនួនដែលថាការសរសេរនោះ គឺទាយស្មានចេញពីខ្ញុំ។ ចំណុចនេះជាខ្សោយនៅក្នុងហ្នឹង ហើយយើងនឹងកែប្រែនូវការគិត និងការយល់របស់យើងនៅពេលដែលឯកសារជាច្រើនបានលេចចេញមក កិច្ចសម្ភាសន៍នានាបានធ្វើឡើង។ ដូច្នេះចំណុចហ្នឹងក៏យើងមិនចាត់ទុកថាជាចំណុចខ្សោយទេ យើងចាត់ទុកជាចំណុចខ្លាំងវិញ។ ហើយនៅពេលដែលក្រោយពីយើងយល់ទៅលើបញ្ហាទាំងអស់នេះ យើងអាចសង្ខេបទៅលើការពិត គឺការសង្ខេបការពិតដោយមិនលម្អៀង។ ហើយការពិតនេះ គឺថាវាលេចឡើងចេញឲ្យយើងនាពេលក្រោយ។

[១៥:៥៣:០១]

ដូច្នេះ នៅក្នុងហ្នឹងគាត់បានបន្តនិយាយចំណុចហ្នឹងក្នុងហ្នឹងដែរ ហើយនៅចុងយោងជើងទំព័រគាត់បានចោទសួរថាតើមានអ្វីកើតឡើងនៅក្នុងឆ្នាំ១៩៧៧។ ខ្ញុំអាចមានការកែប្រែគំនិតអំពីស្ថានភាពកើតឡើងឆ្នាំ១៩៧៩ និងឆ្នាំ១៩៨០។ ចំណុចហ្នឹង គឺក្រោយមក ខ្ញុំបានសន្និដ្ឋានក្រោយពីមានភាពសង្ស័យ។ មិនមែនថាខ្ញុំគាំទ្រចំណុចហ្នឹងទេ ខ្ញុំមានការផ្លាស់ប្តូរនូវការយល់របស់ខ្ញុំ។ ហើយខ្ញុំមិនបានធ្វើការវិភាគជាមុន និងក្រោយមកដែរនៅក្នុងចំណុចយោងទាំងអស់នេះ ក្រោយពីយើងបានប្រមូលទិន្នន័យ និងព័ត៌មានឯកសារទាំងអស់។ ហើយខ្ញុំប្រហែលជាយល់ថាចំណុចហ្នឹង គឺខ្ញុំមិនគិតថាវាជាចំណុចដែលខ្ញុំយល់អ៊ីចឹងដូចកាលពីមុននោះទេ មានការកែប្រែទៅលើគំនិតខ្លះ។

[១៥:៥៤:០២]

**សួរដោយលោក វ៉ិចទ័រ កូប៉េះ**

**ស៖** សូមអរគុណ។ នៅពេលនេះ ខ្ញុំសូមឲ្យលោកមើលទំព័រ១២៣ ស្តីអំពី សៀវភៅស្តីអំពី “កុម្មុយនីស្ត” ទំព័រ ជំពូក៧ ឯកសារ E3/22, 00393786 លេខ ERN ជាភាសាអង់គ្លេស ដោយសារមិនមានការបកប្រែជាភាសាបារាំង ខ្ញុំអានតែម្តង អានឲ្យយឺតៗ។ ទំព័រ១២៣: “ក្នុងខែកក្កដា ឆ្នាំ១៩៦៧ វៀតណាមបានអះអាងថា កុម្មុយនីស្តនៅប្រទេសដទៃទៀតគឺអាចជួយពួកគេបានប្រឆាំងចក្រពត្តិអាមេរិក តាមរយៈការតស៊ូហិង្សាប្រឆាំងនឹងចក្រពត្តិ។ ដូច បូសេរិក, ចិន និងបដិវត្តន៍របស់ចិននោះផងដែរ -- ក្នុងបដិវត្តន៍របស់វៀតណាមផងដែរ។ ដូច្នេះនៅចុងក្រោយ ប្រជាជនត្រូវក្រោកឈរឡើង ដើម្បីធ្វើបដិវត្តន៍ប្រដាប់អាវុធ។ នៅពេលដែលធ្វើការវាយសម្រុកខ្លាំង តាមផ្នែកនយោបាយ សេដ្ឋកិច្ច ពួកគេបានសម្រេចថាត្រូវតែធ្វើការតស៊ូផ្នែកប្រដាប់អាវុធនៅក្នុងចំណោមមហាជន”។ បញ្ចប់ចំណុចដកស្រង់។

ខាងក្រោយនេះបន្តិច ទំព័រ មួយទំព័រក្រោយមក លោក ហេដឌ័រ បានន័យថាទំព័រ១២៤ សូមឲ្យលោកមើល ERN 00393787។ “តាមរយៈអំពើហិង្សានេះ កុម្មុយនីស្តអនុញ្ញាតឲ្យបរិវារនៅក្នុងស្រុកធ្វើការវាយកម្ទេចអង្គការរបស់ប្រជាជនមួយចំនួន។ កុម្មុយនីស្តទាំងអស់ត្រូវយល់ថា នៅពេលធ្វើការតស៊ូនយោបាយបានវិវត្តទៅ ហើយមិនគាំទ្រដោយការតស៊ូមហាជននោះ គឺដោយសារមានការបំផ្លាញ និងការដាក់សម្ពាធ”។

ខាងក្រោយនេះបន្តិច ត្រង់ទំព័រដដែល “នៅក្នុងការវិភាគខែតុលា គឺសារព័ត៌មានរបស់វៀតណាម ឡឺ ដ័ន (Le Duan) បានលើកឡើងអំពីបញ្ហារដ្ឋប្រហារនៅក្នុងប្រទេសកម្ពុជាក្រោមការជំរុញដោយអាមេរិក នៅក្នុងស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ច។ ហើយដោយលើកឡើងថារបបសម្តេច សីហនុ គឺមានគ្រោះថ្នាក់”។

[១៥:៥៦:៤៣]

ខាងក្រោមបន្តិច “នៅក្នុងខែតុលា ការវិភាគក៏បានបញ្ជាក់ថា កុម្មុយនីស្តត្រូវសិក្សាអំពីបដិវត្តន៍របស់វៀតណាមដើម្បីបំពេញកាតព្វកិច្ច និងភារកិច្ចរបស់ខ្លួនក្នុងការការពារបដិវត្តន៍នៅក្នុងប្រទេស។ ដើម្បីឲ្យបដិវត្តន៍នេះជាមហាជន គេត្រូវតែយកប្រើប្រាស់កម្លាំងយោធា និងប្រជាជន ដើម្បីធ្វើការវាយសម្រុក ហើយដើម្បីឲ្យប្រជាជនក្រោកឈរឡើងធ្វើបដិវត្ត”។

ទំព័របន្ទាប់ លោក ហេដឌ័រ នៅពាក់កណ្តាល ERN 00393888 “វៀតណាមជាន់ខ្ពស់ ទ្រឿង ជីញ បានលើកឡើងចំណុចដូចគ្នានៅដើមខែវិច្ឆិកា ឆ្នាំ១៩៦៧។ នៅពេលដែលចលនាកុម្មុយនីស្តត្រូវបាន

បង្ក្រាប គឺគេគ្មានផ្លូវណាមួយត្រូវអនុវត្ត ក្រៅពីការធ្វើបដិវត្តហិង្សានោះទេ”។

ហើយចំណុចក្រោយ ទំព័របន្ទាប់មកទៀត ទំព័រ១២៦ ERN 00393889 “អ្វីដែលវៀតណាមបានលើកឡើង គឺផ្តល់ហេតុផលទៅដល់ប្រទេសកម្ពុជា ហេតុអ្វីបានផ្លូវមនោគមន៍វិជ្ជាគឺជាផ្លូវមួយល្អ គឺជាផ្លូវមួយល្អសម្រាប់ប្រទេសតូច និងប្រជាជនតិច។ ទោះបីជាប្រទេសនេះមានដៃទទេក៏ដោយ ហើយមិនថាអាមេរិកនោះ ចក្រពិត្តអាមេរិកនោះខ្លាំងប៉ុនណានោះទេ។ នេះជាវិធីមួយដើម្បីជៀសវាងកុំឲ្យចក្រពត្តិ និងបរិវាររបស់ជួយទៅដល់សង្គ្រាមរបស់វៀតណាម”។

[១៥:៥៨:៣៣]

ទំព័រចុងក្រោយ គឺទំព័រ 00393790 ទំព័រ១២៧ ខាងលើ “មិនលើកឡើងចំណុចខ្លួនឯង វាផ្ទុយទៅនឹងគោលការណ៍ឯករាជ្យភាព ស្វ័យ -- ខ្លួនទីពឹងខ្លួន និងជោគវាសនាខ្លួនឯង។ គេត្រូវអនុវត្តតាមផ្លូវបដិវត្តន៍ទៅតាមច្បាប់ ទៅតាមប្រវត្តិសាស្ត្រ។ ហើយត្រូវគោរពតាមបដិវត្តន៍ នៅក្នុងបដិវត្តន៍ដែលបានអនុវត្តឡើង”។

ខ្ញុំបានអានលោកនូវចំណុចដកស្រង់មួយចំនួន ដែលលើកឡើងដោយអ្នកនយោបាយវៀតណាមនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ តើក្រោយពីលោកអានកិច្ចសម្ភាសន៍ និងឯកសារនានាក្រោយមក ឯកសារទាំងអស់នោះ អាចឲ្យលោកបញ្ជាក់តាមអង្គហេតុថា គឺគោលនយោបាយនោះ គឺចេញពីការណែនាំពីវៀតណាម ថាខ្លួនត្រូវតែធ្វើយ៉ាងម៉េចតាមដែរឬទេ?

**លោក ឃឹត រេយ៉ន័រ៖**

មានបញ្ហាទៀតហើយ។ យើងអត់មានឃើញអាន មេធាវីអានលេខយោងជើងទំព័រនោះទេ។ ការអះអាងមួយចំនួនដែលមេធាវីការពារក្តីគាត់យោងនោះ គឺមានគាំទ្រដោយលេខយោងជើងទំព័រ។ ក៏ប៉ុន្តែមានប្រយោគមួយឃ្លានោះ មិនមាននៅក្នុងជើងទំព័រទេ ដូច្នេះវាជាការអញ្ជើញឲ្យសាក្សីផ្តល់មតិយោបល់។ លើសពីនេះ គឺនាំឲ្យមាន ជំរុញឲ្យមានការធ្វើបដិវត្តន៍ហិង្សា ដែលវាផ្ទុយនឹងច្បាប់ពិភពលោក។ ហើយវាផ្ទុយទៅនឹងបេសកកម្មរបស់កុម្មុយនីស្តដែលត្រូវធ្វើការការពារ។

[១៦:០០:៤០]

គ្មានលេខយោងជើង ទំព័រត្រង់ចំណុចនេះទេ ដូចដែលមេធាវីមេធាវីការពារក្តីបានដកស្រង់។ ហើយនៅពេលនេះ លោក ហេដឌ័រ នេះត្រូវបានមេធាវីការពារក្តីសួរឲ្យផ្តល់ជាមតិយោបល់ផ្អែកទៅលើចំណុចហ្នឹង។ ជាពិសេសអំពីគោលនយោបាយ ដែលមិនពាក់ព័ន្ធនឹងការលើកឡើងរបស់គាត់ ហើយ

គាត់យោងទៅលើចំណុចដកស្រង់ចំនួនប្រាំមួយនៅក្នុងនោះ។ ដូច្នេះខ្ញុំសូមជំទាស់ទៅលើអ្វីដែលគាត់បានសួរនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីជាតិ! មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមអរគុណលោកប្រធាន។ ការពិតខ្ញុំចង់ងើបឡើងដើម្បីលើកមតិដូចតំណាងសហព្រះរាជអាជ្ញាដែរ។ ហើយគ្រាន់តែសូមបញ្ជាក់បន្ថែមទៀត ក្រៅពីអ្វីដែលសហព្រះរាជអាជ្ញាបានលើកថាជាសំណួរសម្រាប់អ្នកជំនាញនោះ គឺការអាននោះមានលក្ខណៈលឿន ហើយដែលការបកប្រែជាភាសាខ្មែរមានការពិបាកស្ដាប់បន្តិច ប្រសិនបើគាត់ត្រូវ -- លោកមេធាវីអន្តរជាតិត្រូវការអានបន្តទៀត សូមឲ្យគាត់អានរាងយឺតៗបន្តិច ដើម្បីងាយស្រួលទៅដល់អ្នកបកប្រែនៅក្នុងការបកប្រែ។ សូមអរគុណលោកប្រធាន។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំអានចំណុចហ្នឹង ហើយខ្ញុំសួរអ្នកដែលសរសេរថា តើគាត់មានព័ត៌មានអង្គហេតុ ដើម្បីគាំទ្រនូវអ្វីដែលគាត់បានលើកឡើង ឬក៏គាត់សរសេរដែរឬទេ ដូចដែលលោក -- ដូចដែលគាត់បានលើកឡើងនៅក្នុងនេះ ខ្ញុំមិនចាប់អារម្មណ៍ទៅលេខយោងជើងទំព័រនោះទេ ខ្ញុំគ្រាន់តែចង់ដឹងថា តើគាត់មានព័ត៌មានអង្គហេតុណាមួយអំពីចំណុចហ្នឹងដែរឬទេ? ហើយថាតើមានអត្ថបទណាផ្សេងដែលវាអាចយកមកផ្ទៀងផ្ទាត់ស៊ីសង្វាក់គ្នាដែរឬទេ? នៅក្នុងនេះ គឺវាហាក់ដូចជាវាបង្ហាញថា វៀតណាមពិតជាអ្នកផ្ដល់គោលនយោបាយទៅដល់បក្សកុម្មុយនីស្តកម្ពុជា។

[១៦:០៣:០២]

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:០៥:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងដែលមានគាំទ្រដោយក្រុមមេធាវីនាំ

មុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការតាំងសំណួរចុងក្រោយដោយក្រុមមេធាវីការពារក្តី នួន ជា ចំពោះសាក្សី ហេដឌ័រ ដែលមានលក្ខណៈជាឲ្យសាក្សីផ្តល់មតិយោបល់ក្នុងឋានៈជាអ្នកជំនាញ ដែលខុសជាមួយនឹងការណែនាំរបស់អង្គជំនុំជម្រះ ដែលសាក្សីរូបនេះចូលខ្លួនមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងនាមជាសាក្សី។ ហេតុដូច្នេះសាក្សីមិនចាំបាច់ឆ្លើយតបទៅនឹងសំណួរនេះទេ សេចក្តីជំទាស់ហ្នឹងគឺត្រឹមត្រូវ គឺមានប្រសិទ្ធភាព។

សូមអញ្ជើញលោក ស្ទីវ ហេដឌ័រ!

**លោក ស្ទីវ ហេដឌ័រ៖**

ខ្ញុំមិនយល់អំពីទំនាក់ទំនងជាមួយនឹងការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា និងការសម្រេចរបស់លោកប្រធាននោះឡើយ។ ក៏ប៉ុន្តែការលើករបស់សហព្រះរាជអាជ្ញា គឺគ្រាន់តែថាចំណុចនៅក្នុងអត្ថបទហ្នឹង គឺមិនមានយោងនៅក្នុងលេខយោងជើងទំព័រ។

[១៦:០៦:៥៤]

ចំណុចហ្នឹង គឺសន្និដ្ឋានដោយសហព្រះរាជអាជ្ញា ឬក៏ដោយអង្គជំនុំជម្រះ។ បានន័យថា បើអ៊ីចឹងគឺជាការផ្តល់មតិយោបល់ ហើយវាពាក់ព័ន្ធភ្ជាប់ទៅនឹងឯកសារមួយទៀត។ អ្វីដែលនៅក្នុងនេះ គឺថាអត្ថបទនេះរៀបចំឡើងជាលក្ខណៈសិក្សាស្រាវជ្រាវ។ ខ្ញុំនិយាយឡើងវិញនៅក្នុងហ្នឹង គឺលេខវាយោងនៅក្នុងលេខយោងជើងទំព័រនៅឯកសារមួយទៀត។ ពាក្យ ការរៀបពាក្យនៅក្នុងហ្នឹងដែលខ្ញុំប្រើប្រាស់គឺវាមិនមែនទៅតាមពាក្យពេចន៍ដើមសុទ្ធសាធនោះទេ គឺតាមពាក្យពេចន៍អ្វីដែលខ្ញុំសរសេរនៅក្នុងសៀវ-ភៅមួយទៀត ក្នុងលេខយោងទំព័រ លេខយោងជើងទំព័រនៅក្នុងឯកសារផ្សេង។

នេះគឺជាបទដ្ឋាន ដែលយើងព្យាយាមកុំឲ្យវាស៊ីទំព័រហ្នឹងច្រើនពេក ទើបសរសេរអ៊ីចឹង។ ដូច្នេះបានន័យថា លេខយោងជើងទំព័រហ្នឹងវាអាចដូចគ្នាទេនៅក្នុងឯកសារមុន។ ហើយសេចក្តីសន្និដ្ឋានហ្នឹងគឺថាវាសន្និដ្ឋានអ៊ីចឹង។ មិនថាអ្នកណាសន្និដ្ឋាននោះទេ គឺជាការសន្និដ្ឋានយោងទៅតាមលេខយោងជើងទំព័រមុនៗ។ ដូច្នេះវាអាចជាចំណុច ដែលបុគ្គលមួយចំនួនគាត់និយាយអ៊ីចឹង ហើយជាការយោងត្រឹមត្រូវនៅក្នុងទំព័រហ្នឹង។ ហើយខ្ញុំគិតថា ខ្ញុំមិនអាចនៅពេលនេះមើលគ្រប់ចំណុចដែលសរសេរនៅក្នុងទំព័រសៀវភៅនេះទាំងអស់នោះទេ។ ក៏ប៉ុន្តែវាមាននៅក្នុងទំព័រលេខយោងផ្សេងទៀត។

[១៦:០៨:២៨]

**លោក វ៉ិចទ័រ កូប៉េ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ សេចក្ដីសន្និដ្ឋានឥឡូវចប់ហើយ។ សវនាការនៅថ្ងៃនេះចប់ហើយ ហើយលោកមេធាវីការពារក្ដីលោក នួន ជា អស់ពេលវេលាសម្រាប់សួរសាក្សីនេះហើយ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយសម្រាប់កិច្ចដំណើរការសវនាការថ្ងៃនេះ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក នៅថ្ងៃពុធ ទី១៧ ខែកក្កដា ឆ្នាំ២០១៣។ ហើយនៅថ្ងៃស្អែកនេះអង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មសាក្សី ស្ទីវ ហេដឌ័រ ដែលនឹងសួរដេញដោលដោយក្រុមមេធាវីការពារក្ដី ខៀវ សំផន។ ហើយសូមភាគីនៃរឿងក្ដី មន្ត្រីបុគ្គលិកគាំទ្រកិច្ចដំណើរការសវនាការរបស់អង្គជំនុំជម្រះ និងសាធារណជនជ្រាប។

លោក ស្ទីវ ហេដឌ័រ ការស្ដាប់សក្ខីកម្មរបស់លោកនៅមិនទាន់ចប់នៅឡើយទេ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តស្ដាប់សក្ខីកម្មរបស់លោកនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅស្អែកទៀត ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីសាក្សី ស្ទីវ ហេដឌ័រ ត្រឡប់ទៅកាន់ទីកន្លែងដែលគាត់ស្នាក់នៅវិញចុះ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក ឲ្យបានត្រឹមម៉ោងប្រាំបួន។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូបគឺ លោក ខៀវ សំផន និងលោក នួន ជា ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ។ ហើយនិងបង្គាប់ឲ្យនាំខ្លួនគាត់មកចូលរួមសវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក នួន ជា បង្គាប់ឲ្យនាំខ្លួនមកនៅត្រឹមបន្ទប់ឃុំខ្លួនខាងក្រោម ដែលរៀបចំនូវឧបករណ៍សោតទស្សន៍ សម្រាប់គាត់អាចចូលនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១០ នាទី)*